100 ហើយបាននិយាយថា "សូមអនុញ្ញាតឲ្យនាងទៅ ព្រោះនាងប្រហែល នឹងទៅភ្លាមៗ។" ហើយនិយាយទៀតថា "គ្រាន់តែអនុញ្ញាតឲ្យនាងទៅ ហើយរស់ នៅដូចធម្មតាដូចដែលនាងអាចធ្វើបាន។ កុំប្រាប់នាងពីរឿងអ្វីទាំង អស់។"

ដូច្នេះស្ត្រីនោះបាននិយាយមកកាន់ខ្ញុំថា"តើខ្ញុំត្រូវធ្វើអ្វី?"

101 ខ្ញុំបាននិយាយថា "ចូរយកនាងឡើងមក ហើយឲ្យនាងឈរ នៅក្នុងជួរនៃ អ្នកដែលត្រូវអធិស្ឋាន។" ហើយខ្ញុំបាននិយាយថា "អ្នកមកជា មួយនាងមក។" ខ្ញុំមានអារម្មណ៍ថាគួរឲ្យអស់សំណើចបន្តិច។

102 ហើយ នៅពេលដែលក្មេងស្រីតូចម្នាក់នោះបានមក នៅព្រឹកនោះ មើលទៅបបូរមាត់ខៀវ ក្រោយបានតុបតែង ដោយសាលាតម្រូវឲ្យធ្វើ។ ហើយ—ហើយក្មេង

តូចនេះបានមក។ ខ្ញុំមិនដឹង ថានាងចង់ បានអ្វីទេហើយនាងចង់ហៅទូរស័ព្ទមកខ្ញុំ។ខ្ញុំបានចាប់ដៃរបស់នាង។ខ្ញុំបាននិយាយថា"អរុណសួស្តីប្អូនស្រី។"នាងនៅទីនោះ។ នោះគឺជានាង។ គ្រាន់តែ នៅក្នុងពេលពីបីនាទី ប៉ុណ្ណោះ ក្រលេកមើលទៅម្តាយរបស់នាង ហើយអ្នកទាំងពីរ រស់នៅ ដោយគ្មានព្រះជាម្ចាស់ និងគ្មានព្រះគ្រីស្ទ។ ខ្ញុំបាននិយាយថា "តើអ្នកអាចរំពឹងថាព្រះនឹងប្រោសអ្នកឲ្យជាយ៉ាងណា? តើអ្នកនឹង ទទួល យកព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះ ដោយខ្លួនរបស់អ្នកផ្ទាល់ទេ?" ខ្ញុំបាននិយាយថា "អ្នកនឹងមកដល់អាងទឹកនេះ នៅទីនេះ ហើយទទួល បុណ្យជ្រមុជទឹកក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ សម្រាប់ការផ្តាច់អំពើ បាបរបស់ អ្នកទេ?"

ពួកគេបាននិយាយថា"យើងនឹងធ្វើដូច្នោះ។"

103 អូ អ្នកដឹងទេពីអ្វីដែលបានកើតឡើង។ ស្រ្តីម្នាក់នេះអាចនឹង ត្រូវបានដាក់ឲ្យនៅទីនេះ នៅព្រឹកនេះ។ មនុស្សជាច្រើនបានដឹងការនេះ។ បងប្រុស មីកអ៊ីហ្គានជាអ្នកតំណាងនៅទីនេះ បានយល់ពីការនេះ។ ប្រហែលបួនឬ ប្រាំឆ្នាំមុននេះ។ ក្មេងស្រីតូចនោះត្រូវបានគេនាំត្រឡប់ទៅ ជួបវេជ្ជបណ្ឌិតវិញ ហើយពិនិត្យទៅគ្មានសូម្បីតែរោគសញ្ញានៃជម្ងឺហូដឃីន(Hodgkind)នៅក្នុងខ្លួនរបស់នាងបន្តិចសោះ។

104 តើមានអ្វីកើតឡើង? អ្នកត្រូវតែទទួលការបញ្ជូននេះ ជាទីមួយ។ អ្នកត្រូវតែមានកងទ័ព ព្រះវិញ្ញាណបរិសុទ្ធបានឈរសមរភូមិមុខ ហើយចំណាយពេលសម្រាប់ព្រះបន្ទូលរបស់ព្រះ។ ទ្រង់គឺជាព្រះបន្ទូល។ ហើយទ្រង់បានគង់នៅទីនោះគ្មានអ្វីនឹងអាចបញ្ឈប់ទ្រង់បានទេ។ គ្មានអ្វីដែលអាច...គ្រប់គ្នានៃបណ្តាញផ្សេងទៀត ត្រូវបានបង្ហាញ ចេញមក។ គ្រាន់តែដូចជាកំសៀវដាំទឹកចាស់មួយ ហើយគ្មានភាយចំហាយចេញមកអ្នកអាចដាក់ភ្លើងឲ្យឆេះនោះវានឹងភាយចំហាយឡើង។ នោះហើយជាអ្វីដែលជាបញ្ហាដែលធ្វើឲ្យពួកគ្រីស្ទាន បានឆេះឆួលឡើង គឺដោយសារតែពួកគេមិនបានសម្អាត ការបញ្ជូនចេញពីខាងក្នុង របស់ពួកគេមក។ អ្នកត្រូវតែសម្អាតមានដូចជា សតិសម្បជញ្ញៈ ការចងចាំ គំនិតដាក់មួយឡែកពីអ្វី គ្រប់យ៉ាងហើយឲ្យចេញមកពីខាងក្នុងវិញនិងទទួលយកព្រះបន្ទូលរបស់ព្រះជា ម្ចាស់ជាសេចក្តីពិត។

105 មិនខ្វល់ថាទោះមានមនុស្សដប់ពាន់នាក់បានស្លាប់នៅខាង*នេះ* ថ្ងៃនេះនៅតែ ទុកចិត្តព្រះឬដប់ពាន់នាក់ស្លាប់នៅខាង*នោះ*នៅថ្ងៃស្អែក គឺនៅតែទុកចិត្តព្រះ គ្មានអ្វីជាកង្វល់សម្រាប់ខ្ញុំទេ។ ខ្ញុំជាបុគ្គលផ្សេងពីគេ។ ខ្ញុំគឺជាម្នាក់ដែលបានទុកចិត្តលើព្រះ។ ខ្ញុំគឺជាម្នាក់ដែលបានជឿជាក់លើទ្រង់។ ហើយយើងនឹងមើលឃើញការបញ្ជូនត្រឡប់មកវិញប្រសិនបើយើងចង់បញ្ជូនការចងចាំរបស់យើងមកវិញប្រសិនបើយើងអាចធ្វើបាននិងមើលឃើញ។ យើងឃើញ *នេះ* មួយ និង *នោះ* មួយ ហើយមួយ *នេះ* និងមួយ *នោះ* រាប់ពាន់នាក់នៃពួកគេជាទីបន្ទាល់។

106 ប៉ុន្តែ វិញ្ញាណអាក្រក់នឹងព្យាយាមដើម្បីចូលមកវិញ។ អ្នកឃើញទេ ប្រសិនបើវាអាចចូលមកក្នុងការនោះវានឹងមានកងទ័ពរបស់អ្នកដែលអ្នកបានបញ្ជូនមក។

107 ប្រសិនបើ អ្នកបានទទួលអារម្មណ៍ថាឃើញ មានរសជាតិ ក្លិន និង ឮ ពួកគេពួកគេមិនអីទេ ប៉ុន្តែកុំទុកចិត្តពួកគេ លុះត្រាតែពួកគេស្របតាមព្រះបន្ទូលព្រះ។ ពួកគេមិនថ្មីទេប៉ុន្តែប្រសិនបើពួកគេមិនស្របតាមព្រះបន្ទូលរបស់ព្រះទេ នោះកុំស្តាប់ពួកគេឡើយ។ ឥឡូវនេះការស្រមើលស្រមៃមនៈសិការ ការចងចាំ ហេតុផល និងសេចក្តីស្រលាញ់ ពួកគេមិនថ្មីទេ ប្រសិនបើវាយល់ស្របតាមព្រះបន្ទូល។ ប៉ុន្តែប្រសិន បើការស្រឡាញ់របស់អ្នកមិនស្របនឹងព្រះបន្ទូលរបស់ព្រះ ចូរចេញពីវា។ អ្នកនឹងចេញភ្លាម។ អ្នកឃើញទេ? ប្រសិនបើហេតុផល របស់អ្នកមិនស្របនឹងព្រះបន្ទូលចេញឲ្យឆ្ងាយពីវាទៅ។ នោះជាការត្រឹមត្រូវ។ ឧបករណ៍...ប្រសិនបើការចងចាំរបស់អ្នក ប្រសិនបើការស្រមើលស្រមៃ ប្រសិនបើមនសិការ និងអ្វីទាំងអស់របស់អ្នកមិនស្របនឹងព្រះបន្ទូលព្រះចូរចេញពីវា។

108 តើមានអ្វីដែលអ្នកទទួលបាននោះ? អ្នកបានទទួលជា ប្រព័ន្ធពន្លឺ។ ហាលេលូយ៉ា! នោះគឺជាការដែលព្រះបានដាក់ផ្កាយ ទៅតាមលំដាប់ ហើយមានព្រះបន្ទូលថា "នៅទីនោះរហូតដល់អញហៅឯង!" ពួកគេបាននៅទីនោះ។ គ្មានអ្វី ដែលនឹងត្រូវផ្លាស់ប្តូរពួកគេបានទេ។ នៅពេល ដែលព្រះបានទទួលមនុស្សនៅក្នុងព្រះហស្តរបស់ទ្រង់រហូតដល់គាត់អាចទទួលបានអារម្មណ៍ និងមនៈសិការ នៃអ្វីគ្រប់យ៉ាងបានបានសម្អាតចេញ រហូតដល់អ្នកអាចឈរជាមួយព្រះបាន ហើយក្នុងវិញ្ញាណគ្មានអារក្សណាអាចនិយាយថាសង្ស័យនៅក្នុងនោះឡើយ។ នោះជាការត្រឹមត្រូវ។

ទ្រង់យាងចូលមកក្បែរហើយមានព្រះបន្ទូលថា "អ្នកគ្មានអារម្មណ៍ប្រសើរជាងនេះទេ។"

109 មនៈសិការរបស់អ្នកត្រូវបានបាត់បង់ទៅ នៅទីនោះ។ សម្លេងមួយបាន ស្រែកឡើងយ៉ាងច្បាស់ថា "ហាលេលូយ៉ា!" សម្លេងមួយបានបន្លឺឡើង "ចូរថ្វាយសិរី ល្អដល់ព្រះ!" វាបានបំភ្លឺចេញមកក្រៅ ជាការពិតណាស់ គ្រាន់តែជាការស្អាត និងច្បាស់លាស់ សម្រាប់ព្រះបន្ទូលរបស់ ព្រះជាម្ចាស់ធ្វើការតាមរយៈអំណាច នៃព្រះ។អ្នកឃើញទេ? នោះជារឿងសំខាន់។

110 នោះជាសមរភូមិរបស់អ្នក។ សមរភូមិរបស់អ្នកគឺ នៅកាលពីដើមដំបូងគឺនៅក្នុងព្រលឹងនិងក្នុងគំនិតរបស់អ្នក ដែលបានបើកចំហរ។ គំនិត—គឺជាទ្វារចូលទៅ កាន់ព្រលឹងជាទ្វារចូលទៅកាន់វិញ្ញាណគ្រាន់តែ។ថាតើគំនិតរបស់អ្នកទទួលយកវិញ្ញាណ ឬបដិសេធវិញ្ញាណនេះ។ អ្នកអាចមានមនៈសិកា និងអារម្មណ៍តិចតួច ក្នុងរឿងទាំងអស់នេះ។ គ្មានអ្វីដែលត្រូវធ្វើ ទៀតទេ។ នោះជាគ្រាន់តែជាអារម្មណ៍តិចតួចក្នុងការគិតរឿងទាំងនោះ។ ប៉ុន្តែនៅពេលដែលវាមកដល់ការពិតចិត្តរបស់អ្នកបើកចំហរឡើង។ ចិត្តរបស់អ្នកនិងរារែកថាទទួលយកវាឬបដិសេធវា។ នោះហើយសម្លាញ់។

ព្រះមិនអនុញ្ញាតឲ្យនរណាម្នាក់ក្នុងចំណោមពួកគេត្រូវបាត់បង់ទេ។

111 អ្នកឃើញទេ វាជាគំនិតរបស់អ្នកដែលបានបើកទ្វារ ឬបិទទ្វារហើយ ស្តាប់តាមមនសិការ ការចងចាំ និងសេចក្តីស្រលាញ់របស់អ្នក។ ប៉ុន្តែនៅពេលដែលចិត្តរបស់អ្នកខិតកាន់តែជិតការទាំងនេះ នោះចូរឲ្យព្រះ ព្រះវិញ្ញាណនៃព្រះបន្ទូលរបស់ទ្រង់ចូលមកក្នុងអ្នកវិញ វានឹងដេញការទាំងអស់ចេញពីអ្នក។ គ្រប់ការសង្ស័យទាំងអស់ត្រូវបានបាត់ទៅ។ គ្រប់ការ ភ័យខ្លាច ត្រូវបានបាត់ទៅ។ គ្រប់អារម្មណ៍នៃការសង្ស័យត្រូវបានបាត់ទៅ។ គ្រប់ទាំងអារម្មណ៍ត្រូវបានបាត់ទៅ។ គ្មានអ្វីដែលឈរនៅទីនោះបានឡើយប៉ុន្តែគឺជាព្រះបន្ទូលនៃព្រះវិញហើយសាតាំងមិនអាចតស៊ូនឹងយើងបានទេ។ ហ្នឹងហើយ។ វាមិនអាចប្រឆាំងនឹងយើងបានទេ។ឥឡូវយើងដឹងថាវាជាការពិត។

112 ការប្រយុទ្ធទាំងនេះត្រូវបានកើតឡើងចាប់ តាំងពីថ្ងៃនៃការបង្កើតសួន អេដែន ការប្រយុទ្ធនោះគឺកើតនៅក្នុងគំនិតរបស់មនុស្ស។ អារក្សសាតាំងជាអ្នកចាប់ផ្តើមវា។ តើវាបានធ្វើអ្វី នៅពេលដែលវាបានជួបនាងអេវ៉ា? វាមិនបានបដិសេធព្រះបន្ទូលរបស់ព្រះទេប៉ុន្តែវាជាមេបោកប្រាស់។ វាបាននៅកន្លែងមួយចំនួននៅទីនេះ។វាបាននិយាយថា"ប៉ុន្តែព្រះដ៏ពិតប្រាកដ..." លោកុប្បត្តិជំពូក៣ ៩១។

អ្នកឃើញទេ? "ពិតណាស់ រឿងទាំងអស់នេះទ្រង់—ទ្រង់—ទ្រង់បានសន្យា..."វាបានដឹងហើយ ថាព្រះបន្ទូលរបស់ព្រះនោះគឺត្រឹមត្រូវ។ ប៉ុន្តែ វាដឹងថាវាអាចគ្រាន់តែចេញមកហើយបំបែកវាតែបន្តិច បច្ឆេះវាបន្តិចទៅប៉ុន្តែ វា—វា—វា ជាអ្នកបញ្ឆោទ។

113 ដូចជាម្តាយបានប្រើថ្នាំហើយនាងនឹងព្យាយាមដាក់ទឹកក្រូចក្នុងប្រេង លាបជើងតុ។ ខ្ញុំគ្រាន់តែយកប្រេងលាបជើងតុ ដោយមិនមានទឹកក្រូច! អ្វីដែលជាការលាក់ពុត! អ្នកឃើញទេ? គាត់...យើងតែងតែប្រើវានៅពេលយប់ ហើយគាត់បានផ្តល់ឲ្យយើងនូវប្រេងធ្យូងថ្មសម្រាប់ព្យាបាល ជម្ងឺកូនក្មេងវិញ។ ហើយនាងបានចាក់ប្រេងធ្យូងថ្មហើយដាក់ស្ករនៅលើវា ឃើញទេ នោះជាប្រភេទនៃការលាក់ពុត។ ប៉ុន្តែវាគ្រាន់តែចង់ ដុតសាច់ បំពង់កររបស់អ្នកនិងជាតិស្ករមានការថយចុះ។

114 មែនហើយ ទាំងអស់គ្នា នោះជាវិធីមួយ។ សាតាំងព្យាយាម ធ្វើជា—លាក់កំពុតអំពីខ្លួនវា។ វាបានព្យាយាមបង្ហាញអ្នកនូវអ្វីមួយ ដែល ល្អប្រសើរជាង វិធីងាយស្រួលបន្ថែមទៀត ដើម្បីសម្រេចផែនការរបស់វា។ ប៉ុន្តែ គ្មានការណា ល្អជាងហើយសមរម្យដូចព្រះបន្ទូលនៃព្រះទេ។ សូមប្រព្រឹត្តតាមព្រះបន្ទូលនោះ។ ទទួលយកនិងប្រព្រឹត្តតាមឲ្យបានខ្ជាប់ខ្ជួន។ សូមឲ្យព្រះបន្ទូលនៅជាប់ នឹងអ្នក។ សូមឲ្យអ្នកនៅជាប់នឹងព្រះបន្ទូល។នោះហើយជាការ—ដែលសំខាន់។

115 ការប្រយុទ្ធគ្នាបានផ្ទុះឡើងពេលដែល អេវ៉ាបានបើកគំនិតរបស់នាង ដើម្បីស្តាប់ហេតុផលរបស់នាង។ នោះហើយជាការមួយដែលបានហូរចូលមក។ នោះហើយជា—ប្រព័ន្ធហេតុផលមួយដល់នាង។ ក្នុងព្រលឹងរបស់នាង នាងបានធ្វើការវែកញែករកហេតុផល។

116 ភ្នែករបស់នាងបានមើលឃើញ។ នាងបានឃើញស៊ីផិន។ វាស្អាតសង្ហាហើយល្អប្រសើរជាងប្តីនាងឆ្ងាយណាស់។ វាមានល្បិចច្រើនលើសជាងសត្វណាៗទាំងអស់ហើយវាជាបុរសដែលមានលក្ខណៈសមរម្យជាងប្តីនាងទៅទៀត។ វាមើលទៅដូចជាសត្វសាហាវអស្ចារ្យឈរនៅទីនោះ។ តើវាអស្ចារ្យប៉ុណ្ណា! ហើយវាបានព្យាយាមដើម្បីប្រាប់នាងនូវអ្វីដែលល្អអំពីខ្លួនវា។

117 ហើយរឿងដំបូងដែលនាងបានធ្វើនោះ គឺនាងបានបើកគំនិតរបស់នាង។ នៅពេលដែលនាងបានបើនោះហេតុផលរបស់មនុស្សក៏បានចាប់យក។ "ហេតុអ្វីតើនោះមិនមែនជាការដែលរំភើបទេឬ?"

118 នោះជារឿងដែលវាបានធ្វើឲ្យស្ត្រីវង្វេងនៅសព្វថ្ងៃនេះ។ ស្ត្រី មួយចំនួនបាន រស់នៅជាមួយប្តីដ៏គួរឲ្យស្រឡាញ់ តែបែរជាស្វែងរកបុរសមាឌធំ។ បុរសម្នាក់នេះ នឹងព្យាយាមពន្យល់ពីហេតុផលនេះ។ ចាំថានោះជាសាតាំងទេ។ នោះហើយ ជាអារក្ស។ ឬផ្ទុយមកវិញ វាអាចក្លែងពីបុរសទៅជាស្ត្រី ហើយ ពីស្ត្រីទៅបុរស វិញបានតាមវិធីណាក៏បានដែរ។ តើវាបានធ្វើអ្វីខ្លះ? វាធ្វើការនៅក្នុងអំណាច ហេតុផលនោះ ឬជាមនះសិការដែលចាប់ផ្តើមផ្លាស់ប្តូរតាមវិធីណាមួយ។

119 ប៉ុន្តែសូមឲ្យព្រះបន្ទូលរបស់ព្រះនៅជាទីមួយវិញ។ មនុស្សមិនអាចមក... គាត់គ្មានបាបទេ...ហាលេលូយ៉ា! វាបញ្ជាក់នៅទីនេះ។ នេះគឺស្រស់ៗតែម្តង។ មនុស្សម្នាក់មិនអាចធ្វើបាបបានទេលុះត្រាតែយកព្រះបន្ទូលចេញពីខ្លួនគេសិន។ គាត់គ្មានអំពើបាបទេ នោះជារឿងដែល មិនគួរឲ្យជឿទេ។ តាំងពីពេលដំបូង ដែលគាត់ បានបោះបង់ព្រះបន្ទូល របស់ព្រះចោល តែដោយសារវត្តមាន នៃព្រះដូច្នេះ គាត់គ្មានបាបទៀតទេ។

120 អេវ៉ា គ្មានបាបទេ លុះត្រាតែនាងបានដាច់ចេញពីព្រះបន្ទូលនៃព្រះ បើនូវប្រព័ន្ធហេតុផលរបស់នាងតាមរយៈព្រលឹងរបស់នាង ហើយចាប់ផ្តើម គិតពីហេតុផលនោះ។ "ហេតុអ្វី ពិតណាស់។ ប្តីរបស់ខ្ញុំមិនដែល ប្រាប់ខ្ញុំនូវរឿងទាំងនេះទេប៉ុន្តែខ្ញុំជឿជាក់អ្នក...គាត់បានប្រាប់ខ្ញុំថា ខ្ញុំមិនគួរធ្វើ បែបនេះទេ ប៉ុន្តែអ្នកដឹងទេអ្នកនិយាយពិតណាស់ ហើយច្បាស់តែម្តង។ ខ្ញុំ—ខ្ញុំជឿថាវាអស្ចារ្យដោយសារតែអ្នកបានប្រាប់យ៉ាងច្បាស់ដល់ខ្ញុំ។" អ្នកឃើញទេនោះ ហើយជាការប្រយុទ្ធលើកដំបូង។ ហើយតាមរយៈការប្រយុទ្ធនោះវា បណ្តាលឲ្យ មាន សង្គ្រាមផ្សេងទៀតបានកើតឡើង។ ហើយរាល់ការបង្ហូរឈាម ដែលមិន ធ្លាប់មានវាបានចូលមក ដល់ក្នុងសួនអេដែន។នាងមិនជឿតាមព្រះបន្ទូលព្រះជាម្ចាស់ទេ។

121 ហើយប្រសិនបើនាងមានជំនឿតែបន្តិចនៃព្រះបន្ទូលរបស់ព្រះ នោះក៏មិនបណ្តាលឲ្យបញ្ហាទាំងអស់នេះកើតឡើងដែរ តើយើងនឹងទទួលបាន អ្វីមកវិញយ៉ាងណាក្នុងការដែលយើងមិនបានធ្វើតាមព្រះបន្ទូលនៃព្រះ? អ្នកមិនអាចធ្វើវាបានទេ។ អ្នកត្រូវតែឈប់គិតពីការទាំងអស់នេះ ហើយ អ្វីផ្សេងទៀត មនសិការ ការចងចាំនិងការនិយាយ...វែកញែកការ ទាំងនេះនិងការផ្សេង ទៀតដែរ។ "ចូរដកយកការសមហេតុសមផលចេញ។"យើងកុំយកហេតុផល គ្មានអីទាំងអស់។

122 យើងគ្រាន់តែទទួលព្រះបន្ទូលជាមូលដ្ឋានប៉ុនោះ "ព្រះមានព្រះបន្ទូលដូច្នោះ" ហើយបានកំណត់ការផ្សះផ្សាវាងអ្នកនិងព្រះ។ គ្រប់ការតភ្ជាប់បានបើកចំហរវាងអ្នកនិងព្រះ។

123 នោះជាសមរភូមិដំបូងបង្អស់។ សូមកុំប្រើកាំភ្លើងម្ភៃពីរគ្រាប់គ្រាន់តែយកគ្រាប់បែកប៉ារមាណូមួយ—មួយគ្រាប់វិញ។ សូមធ្វើការនេះឥឡូវនេះ។ ចូរយើងយកគ្រាប់បែកប៉ារមាណូរបស់ព្រះវិញ។ "តើវាជាអ្វីទៅ បងប្រុស ប្រានហាំ?" ជំ—នឿលើព្រះបន្ទូលរបស់ព្រះ។ នោះហើយ ជាការបំផ្ទុះគ្រាប់បែកប៉ារមាណូរបស់ព្រះ។ វាបំប៉ើងជំងឺនិងវិញ្ញាណអាក្រក់ ហើយរត់ទៅ ស្ពាំទៅ ឆ្វេង។ វា—វាបានបំផ្លាញពួកគេ។ ជាការប្រឆាំង....អូ! វាជា...វាគ្រាន់តែជាការបំផ្លាញ។ វាបានបំបែកអ្វីគ្រប់យ៉ាងដែលមិនគោរពប្រណិប័តដល់ព្រះ។នៅពេលដែលគ្រាប់បែកនៃសេចក្តីជំនឿធ្លាក់ចុះនៅទីនោះហើយព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅពីក្រោយវាហើយបានបំបែកវិញ្ញាណអាក្រក់ជំងឺនឹងការឈឺចាប់ទាំងអស់នោះ។

124 អ្នកនិយាយថា "តើនោះជាការត្រឹមត្រូវទេ បងប្រុសប្រានហាំ? ហេតុអ្វីបាន ជាវាធ្វើបានលើមនុស្សខ្លះនិងមិនអាចធ្វើបានលើមនុស្សខ្លះ?"

125 វាដោយសារតែការបញ្ជូន។ អ្នកអាចមើលទៅ នោះអ្នកនឹង ឃើញវា។ ប៉ុន្តែអ្នកត្រូវមានវានៅ*ទីនេះ* មើលតាមវិធីមួយ *នេះ*។ មិនមែនខាងក្រៅនោះទេ មកក្នុងវិញ អ្នកត្រូវតែនៅខាងក្នុងហើយសម្លឹងទៅក្រៅ។ អ្នកឃើញទេ? អ្នកមិនអាចធ្វើតាមរយៈហេតុផលនោះបានទេ។ អ្នកមិនអាចធ្វើអ្វីតាមរយៈ ការហូរចូលអ្វីផ្សេងទៀតទេ។ អ្នកគួរ តែធ្វើតាមព្រះហឫទ័យនៃព្រះជាម្ចាស់ និងព្រះវិញ្ញាណវិញ។ ហើយតើអ្នកនឹងធ្វើ វាដោយរបៀបណា? អ្វីដែលជាបណ្តាញចុងក្រោយនេះ?

126 វានឹង នៅក្រោយ-...ហើយចុះមក។ អ្នកបាននិយាយដោយញាណ ថា "អូ ខ្ញុំ—ខ្ញុំមានអារម្មណ៍ពីវា។ នៅទីនេះ។ អូ–ហូ។ អូ ខ្ញុំ—ខ្ញុំអាចធុំក្លិនវាឬអ្វីដើម។ ការទាំងនេះមាននៅទីនោះ។បាទ។" រឿងបន្ទាប់គឺហេតុផលដែលថា"មែនហើយវាមើលទៅដូចជាគាត់ដឹងពីអ្វីដែលគាត់ ត្រូវនិយាយ។ គ្រូពេទ្យ បាន និយាយថាខ្ញុំមិនអាចជាសះស្បើយបានទេ។ នោះគួរអាចជាបាន។" អ្នកឃើញទេ បាទ អ្នក—អ្នកគឺគិតខុសហើយ។ នោះហើយ ជាអារក្ស។ នោះគឺជាអារក្សកំពុងល្បួងអ្នក។ តើអ្នកមិនជឿថាជាអារក្សទេ។

127 "ហាលេលូយ៉ា! ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចែងថា ខ្ញុំនឹង...'គ្រប់ការទាំងអស់ខាងលើខ្ញុំចង់អោយអ្នកមានសុខភាពល្អ។' ត្រូវហើយ។"តើអ្នកអាចក្លាយជាទាហានពិតប្រាកដនៅទីនោះដោយរបៀបណា? អ្នកឃើញទេ"'ខ្ញុំចង់ឲ្យអ្នកមានសុខភាពល្អ។'"

128 វាគឺនៅទីនោះ បណ្តាញទាំងនោះ។ អ្នកគ្រាន់តែបើកចិត្តទទួល យកពួកគេ។ មិនមែនគ្រាន់តែដើរហួសពួកគេទេ។

129 បន្ទាប់មក ប្រសិនបើសាតាំងបានឆ្លងកាត់តាមរយៈការនោះ ហើយ ទទួលអ្វីផ្សេងទៀតដោយមនសិការ បន្ទាប់មកវាទទួលយកព្រលឹងវិញ្ញាណ ទុកនៅក្នុងចិត្តរបស់វាវិញ។ ឥឡូវនេះ ប្រសិនបើគាត់គ្រាន់តែទទួលអ្នក...អ្នកនឹងមិនអាច—មិនអាច សម្លឹងមើលទៅពួកគេជាមុនទេ អ្នកគួរតែអនុញ្ញាតឲ្យទ្រង់គង់នៅ *ទីនោះ* ជាទីមួយវិញ។ អ្នកគួរតែអនុញ្ញាតឲ្យទ្រង់គង់នៅ ក្នុងចិត្តរបស់អ្នកសិន។ ហើយនៅពេលដែលទ្រង់បានគង់ក្នុងចិត្តរបស់យើង ទ្រង់បានគ្រប់គ្រងយើង។ បន្ទាប់មកតើទ្រង់ធ្វើអ្វីទៀត? ទ្រង់បានចាប់ផ្តើម ប្រើមនសិការនេះ។ ទ្រង់បានចាប់ផ្តើមប្រើការ *នេះ* ហើយបានចាប់ផ្តើម ប្រើការផ្លាស់ប្តូរនេះ។ តើវាគឺជាអ្វី? អ្នកបានឃើញ ភ្លក់រសជាតិ ដឹងដោយអារម្មណ៍ ហិតក្លិន ឮសម្លេង ការស្រមើលស្រមៃ មនសិការ ការចងចាំ ហេតុផល និងសេចក្តីស្រលាញ់។ ទ្រង់បានចាប់ផ្តើម ប្រើទាំងអស់ផ្សេងៗពីគ្នាតាមបណ្តាញ មិនយូរប៉ុន្មាន ទ្រង់អាចគង់នៅក្នុងការ *នេះ* នៅទីនេះ។ ទ្រង់បានយាង ចុះមកគង់នៅក្នុងគំនិតរបស់អ្នកជាលើកដំបូង ហើយអ្នកគួរតែទទួលយកទ្រង់។ វាអាច...ស្តាប់។ វាអាចប្រសើរជាងការប្រឆាំងនឹងអ្នក ប៉ុន្តែទ្រង់មិនអាចទទួលអ្នកលុះត្រាតែអ្នកទទួលយកទ្រង់សិន។

130 នៅពេលដែលសាតាំងបានដើរទៅក្បែរនាងអេវ៉ាឮហើយបាននិយាយថា "អ្នកដឹងទេថាផ្លែឈើនេះវាធ្វើឲ្យអ្នកមានការសប្បាយរីករាយ"នាងបានឈប់មួយភ្លែត។ អូ នោះហើយជាពេលដែលនាងបានធ្វើឲ្យមានកំហុសនៅពេលដែលនាងបានឈប់ដើម្បីគិតមួយភ្លែត។

131 កុំឈប់ ដើម្បីគិតពីអ្វីទាំងអស់។ អ្នកបានទទួលព្រះបន្ទូល។ ព្រះយេស៊ូវមានព្រះជន្មរស់។ ព្រះជាម្ចាស់ជាអ្នកប្រោសលោះ។ នោះហើយជាព្រះបន្ទូល។កុំឈប់ដើម្បីគិតពីអ្វីដែលគ្មានបានការនេះគ្មានអ្វីត្រូវគិតទេ។

132 ប៉ុន្តែនាងបានឈប់មួយភ្លែត។ នោះហើយ ជាពេលដែលសាតាំង បានដើរតម្រង់ចូលទៅក្នុងគំនិតរបស់នាង។ ហើយបាននិយាយថា "ល្អ វាស្តាប់មើលទៅហាក់ដូចជាសមហេតុផល។" អូ កុំធ្វើដូច្នោះ។ គ្រាន់តែទទួលយកអ្វីដែលព្រះបានបង្គាប់មក។

133 លោកអ័ប្រាហាំ អ្វីនឹងកើតឡើង ប្រសិនបើគាត់ឈប់ ដើម្បីធ្វើការពិចារណា នៅពេលដែលទ្រង់បានប្រាប់គាត់ថា គាត់នឹងមាន កូនម្នាក់ នឹងត្រូវបានបង្កើតដោយនាងសារ៉ាហើយនាងមានអាយុហុកសិបប្រាំឆ្នាំ ហើយគាត់ចិតសិបប្រាំឆ្នាំ? ហើយនៅពេលដែលគាត់មានអាយុមួយរយឆ្នាំ ហើយនាង—ហើយនាងមានអាយុកៅសិបឆ្នាំ គាត់នៅតែ នៅតែ—នៅតែ—នៅតែសារភាពថាព្រះបន្ទូលរបស់ព្រះគឺពិត។ ហើយគាត់បានដឹងថារឿងនេះមិនអាចកើតឡើងដោយពួកគាត់ទេ។អ្នកឃើញទេ? គាត់...គាត់ធ្លាប់គិតថានឹងមានក្តីសង្ឃឹមខ្លះ? លោកមិនដែលមានសង្ឃឹមសូម្បីតែបន្តិច។

134 "ល្អ" អ្នកនិយាយថា "ខ្ញុំសង្ឃឹមថាខ្ញុំមិនអីទេ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងបានសម្រេចក្តីសង្ឃឹមនេះ។ ខ្ញុំសង្ឃឹមថាខ្ញុំនឹងបានទទួលព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងក្លាយជាគ្រីស្ទានដ៏ល្អម្នាក់។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងធ្វើកិច្ចការ*នេះ*។"អ្នកមិនចង់ធ្វើវាទេ។

135 លោកអ័ប្រាហាំ មិនដែលគិតពីរឿងនោះសូម្បីតែបន្តិច។ អាម៉ែន។ "ប្រឆាំងនឹងក្តីសង្ឃឹមរបស់គាត់ តែគាត់នៅតែជឿលើព្រះបន្ទូល នៃព្រះជាម្ចាស់ ដដែល។" សេចក្តីជំនឿគឺច្រើនជាងសេក្តីសង្ឃឹម។ សេចក្តីជំនឿបានមកត្រឡប់ មកពីខាងក្នុង*នេះ*វិញ។សេចក្តីជំនឿបានមកពី*ទីនេះ*។

136 តើគាត់ទទួលបានដោយរបៀបណា? តាមរយៈគំនិតនេះ នេះ—ទ្វារនេះការប្រយុទ្ធនេះគឺនៅចំពោះមុខយើង។

137 ឥឡូវនេះ នៅពេលដែលអ្នកត្រៀមប្រយុទ្ធរួចជាស្រេច! ឥឡូវនេះ អារក្សកំពុងអង្គុយនៅក្នុងចិត្តរបស់យើងម្នាក់ៗ នៅព្រឹកនេះ។ វាបានស្ថិតនៅក្នុងចិត្តរបស់ក្មេងស្រីតូចនេះ។ វាបានស្ថិតនៅក្នុង ចិត្តរបស់អ្នក។ វាមានវត្តមាននៅជុំវិញយើងនៅទីនេះ។ វាបាននិយាយថា "អូ! ខ្ញុំបានឃើញអ្នកព្យាយាមធ្វើការនេះតាំងពីមុនមក។ខ្ញុំបានលឺដូច្នោះតាំងពីមុនមក។"

138 បណ្តេញវាចេញទៅ។ បានហើយ។ បណ្តេញវាចេញទៅ។ ព្រះគម្ពីរ បានមានព្រះបន្ទូលយ៉ាងណានៅក្នុងអត្ថបទរបស់យើងនេះ? "បណ្តេញវាចេញ ទៅ។" នេះជាការត្រឹមត្រូវ។ "បណ្តេញវាចេញទៅ។" យើងបានហ្វឹកហាត់រួចហើយ។

139 ខ្ញុំគិតថា "តើមានបញ្ហាអ្វីសម្រាប់យើងជាអ្នកអធិប្បាយ?" ខ្ញុំឆ្ងល់ថាតើប្រភេទនៃការហ្វឹកហាត់បែបណាដែលយើងមាន។

140 ព្រះជាម្ចាស់ជាគ្រូបង្វឹកសម្រាប់ការប្រយុទ្ធដ៏អស្ចារ្យនេះ។ ម៉ាថាយ ជំពូក២៤ បានឲ្យដឹងនៅទីនោះ ហើយដានីយ៉ែល ១២ ក៏បានចែងផងដែរ ថា "នោះជាពេលវេលានៃបញ្ហាដូចជាមិនធ្លាប់មាននៅលើផែនដីនេះពីមុនមកទេ។" ហើយយើងកំពុងរស់នៅក្នុងពេលវេលានោះ នៅពេលដែលវប្បធម៌ ការអប់រំ និងអ្វីផ្សេងទៀតដែលបានលុបបំបាត់ព្រះបន្ទូលនៃព្រះ ហើយវិលទៅរកហេតុផលជាដើម។ ការប្រយុទ្ធនឹងចាប់ផ្តើមឥឡូវ។ តើនរណា នឹងឈរនៅបាន? ហាលេលូយ៉ា! ការប្រយុទ្ធនេះបានត្រៀមរួចហើយ។ នាងបានរៀបចំរួចហើយ។ មើលតើគូបដិបក្សឯនាយអស្ចារ្យយ៉ាងណា។

141 តើនរណានឹងបានដូចជាដាវីឌ? ហើយបាននិយាយថា "អ្នកឈរហើយអនុញ្ញាតឲ្យទាហានភីលីស្ទីនដែលពុំបានកាត់ស្បែក មកប្រឆាំងនឹង ទ័ពរបស់ព្រះដែលមានជីវិតគង់នៅឬ? ខ្ញុំនឹងទៅប្រយុទ្ធនឹងវា។" អាម៉ែន។ ព្រះចង់ឲ្យបុរសនិងស្ត្រីទាំងអស់ នៅព្រឹកនេះបានលើកដៃឡើង ហើយ និយាយថា "ខ្ញុំនឹងយកព្រះអម្ចាស់នឹងព្រះបន្ទូលរបស់ទ្រង់។" អាម៉ែន។ មិនខ្វល់ថាបរាជ័យយ៉ាងណានោះទេឬក៏កន្លែង*នេះ* ហើយកន្លែង *នោះ* ហើយនឹងអ្វីមួយ ដែលបានធ្វើ។ គ្មានអ្វីត្រូវធ្វើជាមួយវាទេ។ អ្នក ស្តេចសូលនិងអ្នកផ្សេងទៀត ប្រសិនបើអ្នកខ្លាចវា ចូរដកថយទៅកន្លែងដើមវិញ។ ប៉ុន្តែ កងទ័ពរបស់ព្រះត្រូវធ្វើដំណើរទៅមុខអាម៉ែន! មនុស្សក្លាហាន មនុស្សនៃ—នៃ—នៃជំនឿមនុស្សដែលមាន អំណាចមនុស្សដែលមានការយល់ដឹង។ ពួកគេមិនត្រូវការការឆ្លាតពេកទេ។ ពួកគេមិនត្រូវការការអប់រំ។ ពួកគេត្រូវការបណ្តាញ។ព្រះនឹងប្រើបណ្តាញទាំងនោះ។

142 នាងបានឈប់មួយភ្លែត ដើម្បីគិតពីហេតុផល ហើយនិយាយថា "មែនហើយឥឡូវនេះចូរយើងគិតមើល។" ជាការប្រសើរណាស់ គ្រាន់តែប្រសិន បើដូច្នោះ...

143 ព្រឹកនេះក្មេងស្រីតូចម្នាក់នេះគ្មានការសង្ស័យទេថាគ្រូពេទ្យបានប្រាប់នាងថានាងបានដើរដល់ចុងបញ្ចប់នៃផ្លូវនេះ"គ្មានអ្វីអាចនឹងសម្រេចបានទេ។"ល្អឥឡូវនេះ

នោះហើយជាគ្រូពេទ្យ។ ខ្ញុំមិនកាត់ទោសគាត់ទេ។ បុរសម្នាក់នោះជាមនុស្សវិទ្យាសាស្ត្រ។ លោកបានដឹងថាជំងឺនេះបានរីករាល ដាលនៅក្នុងរាងកាយរបស់កុមារនោះ។ វាគ្មានអ្វីនោះទេ។ លោកគ្មានថ្នាំដែលអាចនឹងព្យាបាលវាបានទេ។

144 ដូច្នេះតើមហារីកនឹងគ្រប់គ្រងលើស្ត្រីម្នាក់នោះ ប្រាកដណាស់ ការស្លាប់ វានឹងប៉ះពាល់ដល់ទារកទៀត ប៉ុន្តែមេបញ្ជាការរបស់យើង ហាលេលូយ៉ា ជាមេបម្រើដ៏អស្ចារ្យនៃកងទ័ព ទ្រង់គឺជាការរស់ឡើងវិញ ហើយជាជីវិត។ គ្មានអ្វីដែលអាចយកឈ្នះទ្រង់បានទេ។ហាលេលូយ៉ា!

145 ខួរក្បាលនៃកងទ័ពនេះបានពឹងផ្អែកទៅលើមេទ័ពដ៏ឆ្លាតរបស់ខ្លួន។ រ៉ូមែល(Rommel)ក្នុងប្រទេសអាល្លឺម៉ង់គឺជាខួរក្បាលនៃប្រទេសអាល្លឺម៉ង់ មិនមែនជាខួរក្បាលរបស់លោកហ៊ីត្លែរទេ។ រ៉ូមែល! នោះជាការត្រឹមត្រូវ។ អ៊ីសែនហោវើ! ជាយោធា! ភែថុន! មនុស្សទាំងនោះជាទ័ពជួរមុខរង់ចាំបទបញ្ជាដែលពួកគេឲ្យ។ អ្នក ត្រូវធ្វើតាមមេងកងរបស់អ្នក ប្រសិនបើគាត់ជាឧត្តសេនីយ៍ត្រឹមត្រូវ។ ប្រសិនបើគាត់ជាមេបម្រើប្រសិនបើគាត់ជាឧត្តមសេនីយ៍ផ្កាយបួនប្រសិនបើគាត់បានបង្ហាញអ្វីមួយ ប្រសិនបើលោកបានបញ្ជាក់ថាត្រូវធ្វើដូច្នោះ ចូរធ្វើតាមគាត់។ ទោះបីជាអ្នកគិតថាខុសតែអ្នកត្រូវតែស្តាប់តាម គាត់ដដែល។ធ្វើអ្វីដូចដែលគាត់បានប្រាប់អ្នក។

146 ហាលេលូយ៉ា! យើងមានឧត្តសេនីយ៍ផ្កាយប្រាំប្រកបថា ជេ—អ៊ី—អេស—យូ—អេសទ្រង់បានពាក់ផ្កាយប្រាំដល់យើង គឺសេ—ច—ក្តី—ជំ—នឿ។ ទ្រង់មិនដែលចាញ់ការប្រយុទ្ធមួយណាឡើយ។ ហាលេលូយ៉ា! ទ្រង់បានយកឈ្នះសេចក្តីស្លាប់។ ទ្រង់បានដេញអារក្សចេញពីការនេះ។ ទ្រង់ជាមេបញ្ជាការដ៏អស្ចារ្យ។ ដូច្នេះអារក្សគឺមិនដែលឈ្នះក្នុងការនេះទេ។

147 ការប្រយុទ្ធដ៏ធំបំផុតដែលមិនធ្លាប់ជួបប្រទះត្រូវបាន ត្រូវបានចាប់ផ្តើមត្រៀមខ្លួនក្នុងការប្រយុទ្ធឥឡូវនេះ។ ពិតណាស់។ អូ! ហាលេលូយ៉ា!

148 ពេលដែលខ្ញុំគិតពីវា! ពេលដែលខ្ញុំឈរមើលទ្រង់ធ្វើអ្វីដែលទ្រង់បានបើកសម្តែងហើយមានបន្ទូលថា "វានឹងក្លាយជារបៀប *នេះ* របៀប*នោះ*" នៅទីនោះវាជាការមួយ! អូ មើលមក*ទីនេះ*ហើយមានបន្ទូលថា "តើនរណាជាមេកងដ៏ អស្ចារ្យ?" អូខ្ញុំមិនមើលទៅក្រោយ ថាជាបណ្ឌិត*បែបនេះ—និង—បែបនោះ*ទេ។ ខ្ញុំយល់នូវអ្វីដែលមេកងបាននិយាយ។ "ទ្រង់ជាមេកងនៃសេចក្តីសង្គ្រោះរបស់យើង។" ហា

លេលូយ៉ា! តើអ្វីជាការសង្គ្រោះ? ការរំដោះ! សិរីល្អ! "ទ្រង់ជាមេកងរំដោះ របស់យើង។"

149 វេលាដ៏អស្ចារ្យជិតមកដល់ហើយ។ ហាលេលូយ៉ា! ទាហានជាមួយនឹងគ្រឿងសាស្ត្រាវុធដ៏ភ្លឺចិញ្ចាច មានច្រើនប្រភេទណាស់! សេចក្ដីជំនឿនិងការសង្ស័យ ត្រូវបានកំណត់រៀបចំដោយខ្លួនឯងផ្ទាល់ នៅក្នុងរោងឧបោសថនេះ នៅព្រឹកនេះ! ការសង្ស័យនៅម្ខាង ជំនឿនៅម្ខាង។ ទាហានឈរទៅតាមតួនាទី។ ហាលេ លូយ៉ា! មេកងរបស់យើងជាផ្កាយព្រឹកដែលបម្រើយើង។ ទ្រង់មិនដែលចុះចាញ់ ទេ។ ទ្រង់(មិនដែល)មិនស្គាល់ពាក្យថាដកថយទេ។ ទ្រង់គ្មានការដកថយទេ។ អាម៉ែន។ជាការពិតណាស់។

150 សមរភូមិដ៏ធំបំផុតដែលមិនធ្លាប់ជួប នាងនឹងបានជាសះស្បើយឥឡូវនេះហ្នឹងហើយ វាគឺរវាងជីវិតរស់និងសេចក្ដីស្លាប់ រវាងជម្ងឺនិងសុខភាពល្អ រវាងសេចក្ដីជំនឿនិងការសង្ស័យ អូ ខ្ញុំអើយ ហើយរវាងសេរីភាពនិងការជាប់ឃុំឃាំង។ ការប្រយុទ្ធគ្នានេះគឺត្រូវ ចាប់ផ្ដើម! បញ្ចេញពន្លឺលំពែងរបស់អ្នកពួកទាហានទាំងអស់។ ដុសខាត់សាស្ត្រាវុធនោះឡើង។ ព្រះបានត្រៀមទាហាន ជាស្រេចហើយ។ អាម៉ែន។ព្រះបានចាក់ប្រេងតាំងលើកងទ័ពរបស់ទ្រង់។

151 កងប្រដាប់អាវុធរបស់អាមេរិកគឺល្អបំផុតនៅពេលពួកគេស្លៀកពាក់ គេមានមួកសុវត្ថិភាព ដែកថែបនិងគ្រឿងសឹក និងអ្វីផ្សេងដែលពួកគេមាន មានរថក្រោះពាសដែក នឹងអ្វីជាច្រើនទៀតដែលពួកគេមាន។

152 ព្រះជាម្ចាស់បានប្រដាប់អាវុធដល់ទាហានរបស់ទ្រង់។ ហាលេលូយ៉ា! តើប្រភេទសម្ភារៈអ្វីដែលយើងនឹងប្រើ? ដាវនៃព្រះវិញ្ញាណជា ព្រះបន្ទូល របស់ព្រះជាម្ចាស់! អាម៉ែន! "ព្រះបន្ទូលរបស់ព្រះមុតជាង ដាវមុខពីរទៅទៀត" នៅហេព្រើរ ៤ "ចាក់ទម្លុះដល់ឆ្អឹង ខួរ—ខួរឆ្អឹង ហើយសូម្បីតែគំនិតនៃចិត្តរបស់ពួកគេ។" ព្រះបន្ទូលរបស់ព្រះជាម្ចាស់! ចូរជឿដល់ព្រះបន្ទូលរបស់ទ្រង់ នោះហើយជាគ្រឿងសាស្ត្រាវុធរបស់ព្រះ។

153 នោះហើយជាអ្វី ដែលទ្រង់បានផ្ដល់ឲ្យនាងអេវ៉ា នៅដៃរបស់នាងផ្ទាល់។ នាងបំផ្លាញគ្រឿងសាស្ត្រាវុធរបស់នាង។ ហេតុអ្វីបានជានាងធ្វើដូច្នោះ? ដោយ ការបើកគំនិតរបស់នាងដើម្បីពិចារណារកហេតុផលមួយ។ អ្នកកុំវែកញែក ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាគ្មានមូលហេតុទេ។ អ្នក...នោះគ្រាន់តែជាព្រះបន្ទូលរបស់

ព្រះជាម្ចាស់។ វាគ្មាន—គ្មានការសង្ស័យទេ។ វាគ្មានហេតុផលអ្វីទេ។ នោះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នោះជាការស្រេច។ យល់ទេ។ នោះការស្រេចជារៀងរហូតដែរ។

154 អ្នកយល់ទេអ្វីដែលខ្ញុំមានន័យថា ប្អូនស្រី? [ប្អូនស្រីដែលមានជម្ងឺនោះ បាននិយាយថា "អាម៉ែន។"—Ed។] នោះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបានសន្យាដូច្នោះ។ព្រះជាម្ចាស់បានមានព្រះបន្ទូលដូច្នេះ។

155 ពួកគេបាននិយាយទៅកាន់លោកអប្រាហាំថា "តើអ្នកដឹងយ៉ាងម៉េចបាន ថានឹងមានកូន?"

"ព្រះទ្រង់មានបន្ទូលយ៉ាងដូច្នេះ។" នោះជាការស្រេច។

"ជាការប្រសើរណាស់ហេតុអ្វីបានជាអ្នកមិនបានទទួលវា?"

156 "ខ្ញុំមិនដឹងថានៅពេលណាខ្ញុំនឹងទទួលបានវានោះទេ ប៉ុន្តែខ្ញុំនឹងទទួលបាន។ ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះ។ គ្មានការអីនឹងបញ្ឈប់ខ្ញុំបានទេ"។ ទ្រង់បានហៅ—...

157 "តើហេតុអ្វីបានជាអ្នកមិនត្រឡប់ទៅផ្ទះ ដែលជាកន្លែងដើមរបស់អ្នក?"

158 "ខ្ញុំនឹងជាក្លាយទៅជាពួកបរិសុទ្ធ ហើយជាជនចម្លែក នៅក្នុងស្រុកនេះ" អាម៉ែន...!?..."ព្រះបានប្រទានការសន្យានេះ។ ព្រះនឹងផ្តល់ឲ្យខ្ញុំ មានកូនម្នាក់នៅ ស្រុកនេះដែលជាកន្លែងដែលទ្រង់បានចាត់ខ្ញុំមក។"ហាលេលូយ៉ា!

159 ព្រះនឹងប្រោសអ្នកដោយព្រះវិញ្ញាណបរិសុទ្ធនៅទីនោះ ដែលជាកន្លែង ដែលទ្រង់ បានបញ្ជូនអ្នកមក។ ព្រះនឹងផ្តល់ឲ្យវាទៅអ្នក។ គ្រាន់តែជឿ។ អាម៉ែន។ បើកចិត្តពួកគេឡើងតាមរយៈព្រលឹងវិញ្ញាណ រាងកាយ អារម្មណ៍និងសតិសម្បជញ្ញៈ ហើយគ្រាន់តែអនុញ្ញាតឲ្យព្រះបន្ទូលរបស់ព្រះបានជ្រាបចូលក្នុងចិត្តរបស់អ្នកជាទីមួយ។នោះគឺជាសមរភូមិប្រយុទ្ធ។

160 កុំនិយាយថា "ប្រសិនបើខ្ញុំមានអារម្មណ៍ថា ប្រសិនបើខ្ញុំមានអារម្មណ៍ថាសិរីរុងរឿងរបស់ព្រះជាម្ចាស់ធ្លាក់មក! អូ" នោះគ្មានអ្វីត្រូវធ្វើទៀតទេ! នោះ មិនមែនជារឿងសំខាន់ទេ។

161 ចូរបើកគំនិតនោះ។ នោះជាសមរភូមិប្រយុទ្ធ។ នៅទីនោះគឺជាកន្លែងដែលការប្រយុទ្ធបានចាប់ផ្តើមនៅទីនេះ ក្នុងគំនិតរបស់អ្នក។ ចូរបើកចិត្ត ហើយ និយាយ

ថា"ខ្ញុំ...គ្រប់ការសង្ស័យខ្ញុំមានការសង្ស័យច្រើនណាស់។" អាម៉ែន។ "ខ្ញុំមានការសង្ស័យលើការគិតរបស់ខ្ញុំឥឡូវនេះ។ ខ្ញុំជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សាតាំងយើងនៅទីនេះ។" អ្វីដែលនឹងត្រូវកើតឡើង។ពិតណាស់វានឹងកើតឡើង។ ហ្នឹងហើយ។

162 ទ្រង់បានចាក់ប្រេងតាំងដោយ ព្រះវិញ្ញាណដល់អ្នកបម្រើរបស់ទ្រង់។ ទ្រង់បានបញ្ជូនពួកគេទេវតាមក។ ពេលខ្លះ មនុស្សបានអស់សំណើច ពីការនេះ ថាអ្វីទៅជា "ទេវតា។" សូមឲ្យខ្ញុំ—សូមឲ្យខ្ញុំត្រលប់ទៅរកអ្វីបន្តិច គ្រាន់តែមួយនាទីទេ។ សូមបើកនៅហេព្រើរ គ្រាន់តែមួយនាទីទេ។ ហេព្រើរជំពូក៤ជំពូក៤ ហើយសូម...ខ្ញុំចង់មានន័យថាជំពូកដំបូងនៃ ហេព្រើរខ១៤។

*តើពួកទេវតាទាំងនោះមិនមែនជាវិញ្ញាណបំរើ...បានចាត់មក សំរាប់ការងារជួយ ដល់ពួកដែលត្រូវទទួលសេចក្តីសង្គ្រោះជាមរដកទេឬអី?*

*...តើពួកទេវតាណា បាននិយាយថា...សូម គង់នៅខាងស្តាំដៃរបស់ខ្ញុំ...?...ពួកទេវតាទាំងអស់ជាអ្នកបម្រើរបស់ព្រះជាម្ចាស់...*

163 ឥឡូវនេះ ព្រះគម្ពីរនៅទីនេះបានមានព្រះបន្ទូលមកនឹងបានប្រាប់ពួកយើងថា ព្រះបញ្ជូនទេវតាមក។ សិរីល្អ! តើមានអ្វីខ្លះ? "វិញ្ញាណនៃការបរើ។" សិរីល្អ! វិញ្ញាណបំរើបញ្ជូន(កន្លែងណា)មកពីវត្តមានរបស់ព្រះ។ តើអ្វីដែលត្រូវធ្វើ? ផ្សាយដំណឹងល្អពីព្រះបន្ទូលរបស់ព្រះ។ អាម៉ែន! ពួកគេមិនមែនបម្រើទេវវិទូឬក្រុមនិកាយណាទេ ប៉ុន្តែ មកបំរើព្រះបន្ទូលទ្រង់។ នោះជាគោលបំណង។ "នៃព្រះវិញ្ញាណបញ្ជូនមក។"

164 តើយើងស្គាល់ពួកគេបានយ៉ាងដូចម្តេច? ព្រះគម្ពីរបានចែង ថា "ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានមកដល់ពួកព្យាការី។" តើត្រូវទេ? ពួកទេវតាបំរើព្រះបន្ទូលទ្រង់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ បំរើព្រះបន្ទូល ហើយព្រះវិញ្ញាណនិងព្រះបន្ទូលបាន មកដល់ព្យាការីហើយ ពួកព្យាការីមានព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នោះជាមូលហេតុដែលពួកគេអាចធ្វើការអស្ចារ្យដែលពួកគេបានធ្វើ។ នោះមិនមែនជាមនុស្ស ឡើយ តែជាព្រះវិញ្ញាណនៅក្នុងមនុស្ស។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្ទគង់ក្នុងមនុស្ស សម្រាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តើអ្វីដែល គាត់បានធ្វើ? បោសសម្អាតរាល់បណ្តាញទាំងអស់។ ព្រះជាម្ចាស់បាន ជ្រើសរើសគាត់ហើយទ្រង់បានចាក់ប្រេងអភិសេក ដោយព្រះវិញ្ញាណបរិសុទ្ធដល់គាត់។ ហើយនោះមិនមែនជា

គាត់ទេ។ គាត់មិនដែលបានធ្វើអ្វីនោះទេ រហូតដល់ គាត់ឃើញការនិមិត្តមួយ។ លោកអេលីយ៉ាបានឲ្យដឹងថានៅលើភ្នំកើមែល"ការទាំងអស់គឺខ្ញុំបានធ្វើតាមបញ្ជារបស់ទ្រង់។ ឥឡូវនេះឱព្រះជាម្ចាស់អើយសូមទ្រង់ អនុញ្ញាតឲ្យគេបានស្គាល់ថាទ្រង់ជាព្រះផង។"អូ! ចូរថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់!

165 ខ្ញុំបានឃើញការនោះច្រើនដងមកហើយ នៅពេលដែល អ្នកទទួលព្រះវិញ្ញាណនៃព្រះ គង់នៅកន្លែណាហើយកន្លែងមួយនោះនឹងបានទទួលការចាក់ប្រេងតាំង! បើសិនជា នៅព្រឹកនេះ ក្រុមតូចនេះនៅទីនេះ ហើយគ្រាន់តែយកចិត្តទុកដាក់ស្តាប់ ហើយដករាល់ការសង្ស័យចេញដោយការស្តាប់នេះ! តើអ្នកអាចសង្ស័យបាន ទៀត ទេនៅពេលដែលអ្នកឃើញមនុស្សស្លាប់—ស្លាប់បានរស់ឡើង មនុស្សខ្វិនអាចដើរបានមនុស្សខ្វាក់អាចមើលឃើញមនុស្សថ្លង់អាចស្តាប់ឮ?

166 ទេវតារបស់ព្រះអម្ចាស់ សូម្បីតែរូបភាពរបស់គាត់ដែលព្យួរនៅលើ ជញ្ជាំងនៅទីនេះ អ្នកវិទ្យាសាស្ត្រមិនយល់អ្វីគ្រប់ជ្រុងជ្រោយទេ។ តើគាត់បានឮធ្វើអ្វី? នៅឲ្យជាប់ជាមួយនឹងព្រះបន្ទូលព្រះ។ អាម៉ែន! ព្រះបន្ទូលបានឈ្នះអស់ទាំងអារក្ស។ បាទត្រូវហើយ។ តើវាគឺជាអ្វី? "នេះជាព្រះវិញ្ញាណបម្រើ បញ្ជូនមកពី ប្រះវត្តមានរបស់ព្រះ" ដើម្បីរើសតាំង គ្រូអធិប្បាយ ព្រះបន្ទូលនៅជាប់ជាមួយនឹងព្រះបន្ទូល។ ហើយទ្រង់បញ្ជាក់ព្រះបន្ទូលដោយទីសម្គាល់ នាំមកនូវព្រះយេស៊ូវដូចកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ នោះគឺទ្រង់ហើយ។

167 តើយើងអាចសង្ស័យដូចម្តេចបាន នៅពេលដែលគាត់ទាំងពីរទាំងខាងវិទ្យាសាស្ត្រសម្ភារៈនិងខាងវិញ្ញាណគ្រប់វិធីយើងអាចបង្ហាញបាននោះព្រះបានបង្ហាញនៅ*ទីនេះ*?

168 តើមានបញ្ហាអ្វី? វាគឺនៅក្នុងគំនិតរបស់យើង។ យើងបានបើកគំនិត របស់យើងទៅកាន់ការនោះ ហើយនិយាយថា "ល្អ ឥឡូវនេះខ្ញុំមិនដឹងទេ ថាតើវាអាចឬមិនអាចទៅរួច។ ប្រហែល ប្រសិនបើខ្ញុំមានអារម្មណ៍ល្អ នៅថ្ងៃស្អែក។" អូ គ្មានរឿងអ្វីដែលត្រូវធ្វើទៀតទេ។

169 ដូចខ្ញុំបាននិយាយជាញឹកញាប់លោកអ័ប្រាហាំ អាចនិយាយទៅកាន់សារ៉ាថា...នាងមានអាយុលើសពី—ពីការធ្វើជាស្ត្រីម្នាក់។ អ្នកយល់ពីន័យរបស់ខ្ញុំទេ ពេលវេលានៃជីវិត របស់ថ្ងៃម្តៃប្រាំបីរបស់នាង។ អ្នកឃើញទេនាងមានអាយុហុកសិបប្រាំឆ្នាំហើយ។ នាងបានហួសអាយុប្រហែល ដប់ប្រាំឬម្ភៃឆ្នាំហើយ។

ហើយគាត់បាននិយាយ ទៅកាន់នាងថាប្រហែលជាប៉ុន្មានថ្ងៃខាងមុខនេះហើយ និយាយទៀតថា "តើមានអារម្មណ៍ថាប្លែកខ្លះទេអូនសម្លាញ់?"

"គ្មានខុសប្លែកអីបន្តិចទេ"។

170 "នោះគ្មានអ្វីទេ។ ទោះជាយ៉ាងណាក៏ដោយ យើង នៅតែបន្ត។ មែនហើយ ឥឡូវនេះប្រសិនបើអ្នកចាប់ផ្តើមត្រឡប់ជាស្រ្តីវ័យក្មេង—ម្នាក់ម្តងទៀតយើងនឹងបានដឹងតាមរយៈវដ្តឈាមនៃជីវិត នោះបន្ទាប់មកយើងនឹងបានរក ឃើញថា វាជាការដែលអាចមានទារក ហើយ អ្វីគ្រប់យ៉ាងនឹងត្រឹមត្រូវទាំងអស់។ ឥឡូវនេះ តើអ្នកមានអារម្មណ៍ថាខុសប្លែកទេនៅថ្ងៃនេះ? វាមានរយៈពេលមួយខែចាប់តាំងពីទ្រង់បានសន្យានឹងខ្ញុំ។តើអូនមានអារម្មណ៍ប្លែកខ្លះទេអូនសម្លាញ់?"

171 "គ្មានអ្វីបន្តិចទេអ័ប្រាហាំ។ គ្មានសញ្ញាអ្វីសោះ។ ខ្ញុំ—ខ្ញុំនៅតែមានខ្ញុំ—ខ្ញុំ មានសភាពដូចពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គ្មានការខុសប្លែក បន្តិចទេ។"

"សូមលើកតម្កើងសិរីរុងរឿងដល់ព្រះ! ទោះជាយ៉ាងណាយើងនឹងមានវា។"

172 "តើអ្នកចង់មានន័យថាលោកអ័ប្រាហាំ...គិតមើលបើទ្រង់បានសន្យា យ៉ាងច្បាស់លាស់ថា ទ្រង់នឹងផ្តល់ឲ្យយើងតាមសញ្ញាមួយ *នេះ*។ ពិតណាស់ថាទ្រង់នឹងផ្តល់ឲ្យយើងនូវសញ្ញាមួយ។"អូ! ហាលេលូយ៉ា!

173 "ជំនាន់ទន់ខ្សោយនិងកំផិតនេះនឹងស្វែងរកទីសម្គាល់ជាច្រើន។" ត្រូវហើយ។ គាត់មានទីសំគាល់មួយ។ តើវាជាអ្វី? ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នោះគឺជាទីសម្គាល់។

174 តើព្រះប្រោសក្មេងនេះយ៉ាងដូចម្តេច? ព្រះបន្ទូលរបស់ព្រះបានមានបន្ទូលដូច្នេះថាប្រសិនបើខ្ញុំមានអារម្មណ៍ឬគ្មានអារម្មណ៍ក៏ដោយ។ ប្រសិនបើខ្ញុំ...មិនខ្វល់ថាមានអ្វីកើតឡើងទេព្រះបានមានបន្ទូលដូច្នេះ។ នោះគឺសម្រេចហើយ។

175 លោកអ័ប្រាហាំបាននិយាយទៅទ្រង់ថា "ចូរយកឆ្នូតក្បាល និងអ្វី គ្រប់យ៉ាងទាំងអស់របស់អ្នក យើងនឹងធ្វើដំណើរទៅកាន់ទឹកដី នោះ។"

"តើអ្នកកំពុងទៅណា?"

176 "ខ្ញុំមិនដឹងទេ។" អាម៉ែន។ "ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើង នឹងទៅ។ តោះយើងទៅ!" ស្តាយអីវ៉ាន់មកយើងនឹងទៅ។ ហាលេលូយ៉ា! នោះហើយជា

ព្រះបន្ទូលពិតរបស់ព្រះ។ តើអ្វីដែលនៅជាប់ជាមួយគាត់? សេចក្តីសន្យាព្រះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់។"យើងនឹងទទួលបានវា។"

177 "ចេញពីចំណោមប្រជារាស្ត្ររបស់លោកអ័ប្រាហាំ។ ពួកគេជាផ្នែកមួយនៃការនេះ ពួកគេជាអ្នកសង្ស័យនិងមិនជឿព្រះ។ ពួកគេនឹងទទួលជំនួយពី អ្នកដូចគ្នា។ ចេញមក។ ញែកខ្លួនរបស់អ្នកហើយរស់នៅសម្រាប់ខ្ញុំ។" តើវាជាអ្វីទៅ? "ទុកឲ្យមនសិការនិងអារម្មណ៍របស់អ្នកទាំងអស់ ស្ថិតនៅពីក្រោយអ្នកដូច្នេះ។ បើកគំនិតរបស់អ្នកនិងចងចាំថានោះជាខ្ញុំ។ សូមអញ្ជើញ មករស់នៅជាមួយខ្ញុំ។"អាម៉ែន។

178 ព្រះជាម្ចាស់ បានហៅគ្រប់ពូជរបស់លោកអ័ប្រាហាំ នៅព្រឹកនេះ ដើម្បីឲ្យមាន ជីវិតដូចគ្នា។ ការប្រយុទ្ធយ៉ាងខ្លាំងបានកើត ឡើងនៅឥឡូវ នេះ នៅទូទាំងពិភពលោក។ តើព្រះចង់ឲ្យកូនរបស់ទ្រង់ញែកខ្លួនចេញពីអ្វី? ចេញពី ការភ្លក់រសជាតិ អារម្មណ៍ ហិតក្លិន ការឮ ការស្រមើលស្រមៃ មនសិការ ការចងចាំ ការស្រឡាញ់ អ្វីៗគ្រប់យ៉ាង។ ចូរបើកគំនិតរបស់ពួកគេ និងអនុញ្ញាតឲ្យ ព្រះបន្ទូលបានចូលទៅនឹងដើរជាមួយព្រះបន្ទូល។នោះហើយជាទាហានដ៏ពិត។

179 នោះជាកន្លែងដែលផ្កាយឈរ។ ប្រព័ន្ធព្រះអាទិត្យ ឆ្នាំមិនផ្លាស់ប្តូរ។ ផ្កាយព្រឹករះឡើង ហើយប្រកាសពី ការបំពេញកាតព្វកិច្ចរបស់ខ្លួន រៀងរាល់ព្រឹក គ្រាន់តែដឹងច្បាស់ថា វាបានធ្វើការនេះនៅពេលដែលផែនដី ត្រូវបានបង្កើតឡើង។ តារារះពេលល្ងាចនៅកន្លែងរបស់ខ្លួន គ្រប់តារា ទាំងអស់គឺដូច្នោះដែរ។ ការផ្លាស់ប្តូរ នៃរដូវ កើតនៅពេលដែលរដូវកាល បានសន្មត់ថាជា កន្លែងដែលវាត្រូវកើត។ តារាខាងជើងឈរនៅនិងមិនផ្លាស់ទីទេ។ ហាលេលូយ៉ា! គ្រប់តារា ទាំងអស់វិលជុំវិញតារាខាងជើងព្រោះវាស្ថិតនៅចំកណ្តាលផែនដី។

180 នោះជាព្រះគ្រីស្ទ។អាម៉ែន។ ទ្រង់ឈរនៅទីនោះហើយបញ្ជាកងទ័ពរបស់ទ្រង់ដូចជាមេទ័ពដ៏អស្ចារ្យម្នាក់។

181 ដូចជាលោកម៉ូសេនៅលើភ្នំ ហើយដៃរបស់គាត់ឡើងហើយអ៊ីស្រាអែលកំពុងប្រយុទ្ធគ្នា ដោយប្រើគ្រប់វិធីរបស់ពួកគេ គាត់ឈរហើយលើកដៃ របស់គាត់ឡើង។ គាត់បានឈរហើយលើកដៃរបស់គាត់ឡើងរហូតដល់ព្រះអាទិត្យលិច។ពួកគេត្រូវលើកដៃរបស់គាត់ឡើង។នោះគឺលោកម៉ូសេ។

182 គាត់គឺជាផ្នែកមួយនៃព្រះគ្រីស្ទ។ ដើម្បីឲ្យប្រាកដថាព្រះហស្តរបស់ទ្រង់លើកឡើងដូច្នេះព្រះហស្តរបស់ទ្រង់ត្រូវដំដែកគោលលើឈើឆ្កាង។ ហាលេលូ

យ៉ា! ហើយទ្រង់បានឡើងទៅកំពែងនៃសិរីល្អ ថ្ងៃនេះ ជាមួយនិងព្រះពស្តឈាមរបស់ទ្រង់នៅចំពោះព្រះ នៅខាងស្តាំព្រះជាម្ចាស់។ ហើយ ការប្រយុទ្ធនេះដើម្បីឲ្យគ្រប់ទាហាននឹងអនុវត្តន៍តាមវិធីរបស់ទ្រង់។ ខ្ញុំមិនខ្វល់ពី អ្វីដែលនឹងកើតឡើងជាមួយនឹងព្រះបន្ទូលនៃព្រះទ្រង់នឹងលះបង់អង្គទ្រង់ដើម្បី សេរីភាព។ អាម៉ែន។

183 ដូចមាន់មួយនៅក្នុងស៊ុតអ្វីនឹងកើតឡើងប្រសិនបើវាភ័យខ្លាចមិនហ៊ានញាស់ ចេញមក? តើនឹងមានអ្វី ប្រសិនបើវាមានការភ័យខ្លាច ពេល វាញាស់ចេញមក? តើមានអ្វីកើតឡើងប្រសិនបើកូនមាន់នៅក្នុងស៊ុតត្រូវបានបក្សីតូចមួយចឹក បំបែក ស៊ុតនោះហើយកូនមាន់ខ្លាចមិនហ៊ានចេញពីស៊ុត? អ្វីនឹងកើតឡើងប្រសិនបើវា បានឮសំឡេងមួយនៅខាងក្រៅនិយាយទៅវាថា "កុំចឹកស៊ុតនេះបើមិនដូច្នោះទេ អ្នកនឹង ឈឺខ្លួន?" ប៉ុន្តែធម្មជាតិរបស់វាបានប្រាប់វាថា "បំបែកវា! ចោះរន្ធទៅ" ។

184 ចូរឲ្យចាស់ទុំទាំងអស់និយាយថា "ថ្ងៃនៃការអស្ចារ្យត្រូវបាន កន្លងផុតទៅ។ អ្នកនឹងធ្វើឲ្យខ្លួនឯងឈឺចាប់។ អ្នកនឹងក្លាយទៅជាអ្នកជ្រុល និយម។"

185 បំបែកសំបកនឹងទៅ គ្រាន់តែធ្វើការប្រឹងប្រែងដូចដែលអ្នកអាចធ្វើបាន។ ហាលេលូយ៉ា! "សាតាំងចេញឲ្យឆ្ងាយ! ខ្ញុំនឹងចេញពីទីនេះ។" ត្រូវហើយ។ "ខ្ញុំនឹងមិននៅក្នុងនេះទៀតទេ។ ខ្ញុំមិនរស់នៅទីនេះទៀត ទេ។ ខ្ញុំមិនមែនស្ថិត នៅក្រោមអារក្សសាតាំងនេះ ដូចមុនទៀតឡើយ។ ខ្ញុំកំពុងរកវិធីចេញពីទីនេះ ព្រឹកនេះ។ អាម៉ែន។ ខ្ញុំជាឥន្ទ្រី។"អាម៉ែន! ហាលេលូយ៉ា!

186 ប៉ុន្តែឥន្ទ្រីដែលចាស់នោះ បានចឹកទីនោះចឹកទំលុះសំបកនោះ។ គ្មានបញ្ហាថាតើសំបកនោះវារឹងប៉ុណ្ណាចឹកទំលុះវាឥឡូវទៅ។ រឿងដំបូងដែលអ្នកដឹង ហើយបន្ទាប់មកវាអាចបើកស្លាបរបស់វាបន្តិច។វាគឺល្អហើយ។

187 ចឹករកផ្លូវចេញមក។ ត្រូវហើយ។ តើអ្នកធ្វើរបៀបណា? បំផុះវា "**ដោយព្រះបន្ទូលរបស់ព្រះអម្ចាស់។ ដោយព្រះបន្ទូលរបស់ព្រះអម្ចាស់។ ដោយព្រះបន្ទូលរបស់ព្រះអម្ចាស់។**" ចុងក្រោយអ្នកចាប់ផ្តើម ស្រង់ក្លិនខ្យល់ ដ៏ស្រស់ស្រាយខ្លះទៅ។ "**នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។**" លានក្បាលរបស់អ្នក ចេញមកខាងក្រៅមក។ "**នេះជាព្រះបន្ទូលរបស់ ព្រះអម្ចាស់។**" រុញឲ្យខ្លាំង ឥឡូវនេះអ្នកនឹងអាចចេញមកបានហើយ!

188 វាមិនត្រឡប់ទៅក្នុងសំបកនោះម្តងទៀតទេ។ អាម៉ែន។ វាមានសេរីភាព ហើយ។ អូខ្ញុំអើយ! ព្រះបន្ទូលបានមកដោយវិញ្ញាណនិងមនសិការទាំងនោះ បាន ដោះស្រាយនៅ*ទីនេះ* ហើយបើកគំនិតអនុញ្ញាត ឲ្យព្រះបន្ទូលបានចូលមក។ ឱព្រះអម្ចាស់អើយ! សូមមានមេត្តា! មិនត្រូវធ្វើជាទាសករទៀតទេ។ អ្នកមាន សេរីភាពហើយ។ ទ្រង់ ដែលជាព្រះរាជបុត្រា បានលោះបាបយើងឲ្យមានសេរីភាព ឡើងវិញ។ និកាយរបស់អ្នកមិនអាចហៅអ្នកមកវិញបានទេ។ អារក្សមិនអាចធ្វើអ្វី ដល់អ្នកទៀតទេ។វានឹងទ្រហោរយំហើយបានបាត់ចេញពីអ្នកទៅ។

189 ប៉ុន្តែអ្នកនៅលើផ្លូវដ៏ខ្ពស់ ដែលអ្នកបានរត់កាត់ក្នុងល្បឿនយ៉ាងលឿន អូ ព្រះជាម្ចាស់នៃខ្ញុំ បានចាក់ប្រេងតាំងដល់ទាហាននៃឈើឆ្កាងទ្រង់។ ហើយ វាជា តន្ត្រីដែលមានសេចក្តីជំនឿ ហើយបានប្រកាសអំពីព្រះយេស៊ូវ ជាពន្លឺនៃលោកិយ៍ និងដំកើងស្តេចនៃស្ថានដ៏ខ្ពស់។ប្រាកដណាស់។ត្រូវហើយ!

190 ទាំងនេះជា "វិញ្ញាណនៃការបំរើ" បានបញ្ជូនពីវត្តមាននៃព្រះទៅ បំរើ(អ្វី?)ព្រះបន្ទូលទ្រង់ មិនមែនទេវវិទូទេប៉ុន្តែជាព្រះបន្ទូលរបស់ព្រះ។ ពួកគេជា អ្នកបម្រើនៃទ្រង់ ដែលបានចាត់មកដោយ ព្រះជាម្ចាស់ដើម្បីបម្រើយើង។ អ្នកបម្រើ នៃព្រះវិញ្ញាណ! អូ! ហើយចូរចាំថា ប្រសិនបើ វាបំម្រើអ្វីមួយក្រៅពីព្រះបន្ទូល នេះ មិនបានមកពី ព្រះទេ។ ពីព្រោះ "ព្រះបន្ទូល តែងតែបញ្ជាក់មកពីស្ថានសួគ៌។" តែងតែមកពីស្ថានសួគ៌ព្រះបន្ទូលនៃទ្រង់ទតមកយើង។ ហើយទ្រង់មិនដែល បញ្ជូនព្រះវិញ្ញាណនៃការបម្រើដែលក្រៅពីព្រះបន្ទូលនៃព្រះទេ។

191 ទ្រង់នឹងមិនប្រទានព្រះវិញ្ញាណជាមួយនឹងពួកឌី.ឌី.ឌី.បណ្ឌិត ហើយដោយ អំនួតរបស់គេទេ អ្វីគ្រប់យ៉ាងគឺដូននោះនិយាយថា "ល្អ ណាស់ ជាការពិតណាស់ ថ្ងៃនៃការអស្ចារ្យត្រូវបានកន្លងផុតទៅ។ យើងទាំង អស់គ្នាបានដឹងហើយ។" ទេ អត់ទេ។ នោះមិនបានមកពីព្រះទេ។ វាជាការផ្ទុយនឹង ព្រះបន្ទូលព្រះ។ អាម៉ែន។

192 ទ្រង់ បានប្រទានព្រះវិញ្ញាណនៃព្រះបន្ទូលតែមួយគត់មក។ អាម៉ែន។

193 អូមានសេចក្តីប្រហែលបួនឬប្រាំទៀតប៉ុន្តែខ្ញុំនឹងបញ្ចប់ឲ្យនៅត្រង់នេះយើង នឹងលើកយកទៅនិយាយនៅថ្ងៃអាទិត្យក្រោយ។ ល្អណាស់។

សាតាំងនិងពួកបិសាចរបស់វាគឺត្រូវបានរើសតាំង។

194 ប្រសិនបើជា ព្រះវិញ្ញាណនៃទេវតាទាំងនេះ ត្រូវបានចាក់ប្រេងតាំង បណ្តាល ឲ្យអ្នកជឿលើព្រះបន្ទូល ឥឡូវនេះ តើអ្នកធ្លាប់បានឮពីព្យាការី ព្យាការីដ៏ពិតនៃ ព្រះ បានបដិសេធពីព្រះបន្ទូលរបស់ព្រះឬទេ? [ក្រុមជំនុំនិយាយថា"ទេ។"—Ed។] ទេ លោក។ តើមានអ្វីកើតឡើងនៅថ្ងៃដែល ពួកគេបានរស់ឡើងវិញ ហើយនិយាយ ទៀតថា"ឥឡូវនេះគាត់ខុសឬ?" ទ្រង់បានរស់ដោយខ្លួនឯងនិងបានឈរតែម្នាក់ ឯង។គាត់បាននិយាយថា"ហ្នឹងហើយ។"

195 នៅថ្ងៃនោះ មើលទៅមីកាយា ដែលជាក្មេងតូចដ៏បរិសុទ្ធ ឃើញទេ គាត់ជា កូនរបស់អ៊ីមឡា។ មានមនុស្សប្រហែលបួនរយនាក់ ដែលបាន ចាក់ប្រេងតាំង សន្មត់ថាបានចាក់ប្រេងអភិសេក ដោយពួកព្យាការីដែល នៅទីនោះ បានផ្គត់ផ្គង់ និងជួយគ្រប់ទាំងអស់ ហើយព្រមទាំងអ្នកប្រាជ្ញ ដែលមានការអប់រំខ្ពស់ផងដែរ។ ហើយទ្រង់មានព្រះបន្ទូលថា "ចូរលើក តំកើងស្តេចដ៏ស្មោះត្រង់នៃយើង។ សូម ព្រះអម្ចាស់គង់នៅជាមួយអ្នក។ ដែលយើងជាកម្មសិទ្ធិរបស់ទ្រង់។ លោកយ៉ូស្វេ បានឲ្យវាមកពួកយើង។ ដូច្នេះអ្នកចេញទៅហើយទទួលវា។ នោះជាការត្រឹម ត្រូវ ណាស់។ អ្នកចេញទៅហើយយកវាមក។ តើមានអ្វី..."គាត់និយាយថា "បាទល្អ យូស្វេ—..."

196 អ្នកដឹងទេថាយ៉ូសាផាតបាននិយាយថា "តើគ្មាននរណា ផ្សេងទៀតឬនៅ កន្លែងណាទៀតទេ?" ល្អណាស់ ពួកគេ មានចំនួនបួនរយនាក់។ ហេតុអ្វីបានជា មិនជឿអ្នកទាំង៤០០នាក់នោះ? ទ្រង់មានបន្ទូលថា "ប៉ុន្តែចូរ ប្រាកដណាស់ អ្នកមានម្នាក់ទៀតនៅកន្លែងណាមួយ។"

197 ហើយនិយាយថា "ខ្ញុំ—ខ្ញុំ...ល្អយើងមានម្នាក់ដែរ។ គឺមានម្នាក់ផ្សេងទៀត ប៉ុន្តែអូខ្ញុំស្អប់គាត់ណាស់។"ហឹម! អ្នកឃើញទេ?

198 "នោះ—នោះ នោះហើយជាបុរសដែលខ្ញុំចង់ស្តាប់ អ្នកឃើញទេ។" គាត់ បាន និយាយថា"ចូរយកគាត់ឡើងមក។យើងនឹងបានដឹងនូវអ្វីដែលគាត់នឹង និយាយ។"

199 ដូច្នេះហើយពួកគេបានប្រាប់ទៅគាត់ថា "ឥឡូវចូរស្តាប់។ អ្នកបានកំណត់ ការអធិប្បាយរបស់អ្នកនៅព្រឹកនេះ ដោយសារតែអ្នកកំពុងផ្សាយដំណឹងល្អដល់ ស្តេច។ អ្នកបានផ្សាយដំណឹងល្អទៅ...សមាគម—សមាគម ទាំងអស់នៃការ *ដូច្នេះ—ហើយ—ដូច្នេះ*អ្នកឃើញទេ ទាំងពួកសមាគមប៉ាឡេស្ទីននៃ រដ្ឋមន្ត្រីទាំង

មូល។ ឥឡូវនេះអ្នកចាំបានថានៅទីនេះ គឺជាអ្វីដែលពួកគេបាននិយាយអំពី។ អ្នកនិយាយរឿងដដែលៗនេះ។ អ្នកបានជឿលើរឿងដដែលៗនេះ។ នោះតិចតួចទេ...

200 ទ្រង់—ទ្រង់ មានមនុស្សម្នាក់ដែលខុសគេនៅទីនោះ។ មនុស្សម្នាក់ដែលបានចាកចេញពីហេតុផលចាស់ៗ។ គាត់បានសម្អាតយកវាចេញ ឃើញទេ ពីសតិសម្បជញ្ញៈដ៏ល្អរបស់គាត់។

201 "ហើយ ល្អណាស់ ហេតុអ្វីបានជាអ្នកដឹងពីអ្វីដែលពួកគេនឹងធ្វើយ៉ាង ណានោះ? ប្រសិនបើអ្នកនិយាយដូចពួកគេដែរ នោះខ្ញុំគិតថា ពួកគេនឹងធ្វើឲ្យអ្នកក្លាយជាបព្វជិតក្នុងស្រុក។ ពួកគេនឹងធ្វើបែបនោះ។ ពួកគេ—ពួកគេនឹងធ្វើឲ្យអ្នកក្លាយជាអ្នកមើលការទូទៅនៅក្នុងស្រុកនេះ បើអ្នក—អ្នកគ្រាន់តែយល់ស្របជាមួយពួកគេ។" នោះមិនមែនជាមនុស្សពិតនៃព្រះទេ។

202 ហេតុអ្វី របៀបរបស់គាត់ត្រូវបានសម្អាតចេញទាំងអស់ គ្រប់ទាំងសតិសម្បជញ្ញៈគឺស្អាត។ គំនិតរបស់គាត់បានបើកសម្រាប់ទទួល ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ហើយព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយ គត់ ដែលគាត់នឹងជឿ។ នោះជាព្រះវិញ្ញាណនៃអ្នកបម្រើ ។ នោះហើយជាព្រះវិញ្ញាណ នៃអ្នកបម្រើម្នាក់។

203 គាត់និយាយថា "ខ្ញុំមិនដឹង ត្រូវនិយាយអ្វីទេឥឡូវនេះ។ ប៉ុន្តែខ្ញុំនឹងប្រាប់អ្នករឿងមួយខ្ញុំនិយាយតែអ្វីដែលព្រះឲ្យខ្ញុំនិយាយតែប៉ុនោះ។"

ដូច្នេះពួកគេបានរង់ចាំនៅយប់នោះ។គាត់មានការនិមិត្តមួយ។

204 នៅព្រឹកបន្ទាប់ ខ្ញុំអាចស្រមៃថា មីកាយាសម្លឹងមើលបទគម្ពីរ ហើយនិយាយថា "ឥឡូវនេះចូរយើងមើលឥឡូវនេះ។ មើលនិម្មិតនោះ...ឥឡូវនេះអ្នកទាំងអស់គ្នាមានអ្វីមួយខុសនៅកន្លែងណាមួយ មូលហេតុគឺវា ផ្ទុយទៅនឹង អ្វីដែលពួកគេបាននិយាយ។ ល្អ តើអ្នកចង់និយាយ ពីអ្វី? តោះយើងមើលនូវអ្វីដែល លោកអេលីយ៉ាបាននិយាយនៅទីនេះ ព្យាការី ពីព្រោះយើងដឹងថាគាត់ជាព្យាការីមួយរូប។ អ្នកឃើញទេ អ្វីដែល...ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់អេលីយ៉ា។ បាទ។ ហើយតើមានន័យយ៉ាងម៉េច? 'ហើយសត្វឆ្កែនឹងលិទ្ធឈាមរបស់អ្នក។ យេសិបិល ឆ្កែនឹងហែកនាងស៊ី។ ហើយ' ដោយសាសេចក្តីសុចរិតរបស់អាហាប់...សេចក្តីសុចរិតរបស់ណាបោត។'" លោក បាននិយាយ បន្ទាប់មក ថា...នៅពេលដែលគាត់ឃើញថាគាត់បានឃើញនូវនិម្មិតរបស់គាត់គឺតម្រង់ទៅកាន់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បន្ទាប់មកវៃយចំណាស់របស់អ័ហាប់ក៏បានមកដល់។

205 ចូរដើរតម្រង់ចេញទៅទីនោះហើយនិយាយថា "ចូរបន្តដំណើរទៅ។ ប៉ុន្តែខ្ញុំ បានឃើញអ៊ីស្រាអែល..."អ្នកឃើញទេគាត់មិនបាន ខ្វាស់ទេក្នុងការប្រាប់ពីនិម្មិតរបស់គាត់ដោយសារព្រះបន្ទូលរបស់ព្រះអម្ចាស់។ គាត់បានដឹងថា គាត់គ្រាន់តែ យករឿងនោះមកប្រាប់ឲ្យល្អឥតខ្ចោះប៉ុនោះ។ តើអ្វីទៅ? គាត់បានបើកចិត្តនិងគំនិតរបស់គាត់ ដើម្បីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយព្រះ បន្ទូលរបស់ព្រះជាម្ចាស់បានបង្ហាញត្រឡប់មកវិញដូច្នេះគាត់បានដឹងថា គឺជាការ ល្អឥតខ្ចោះនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។

206 ឥឡូវនេះអ្នកនិយាយថា"អូ! ប្រសិនបើខ្ញុំជាលោកមីកាយាវិញ!" អ្នកអាចធ្វើបាន។ អ្នកអាច។ អ្នកក៏អាចធ្វើបានដែរសំណព្វចិត្ត។[បងប្រុសប្រានហាំបាននិយាយទៅ កាន់បងស្រីដែលឈឺម្តងទៀត—Ed។] អ្នកជាព្យាការីមីកាយា។ តើអ្នកអាចធ្វើអ្វីបានខ្លះ? បើកគំនិតរបស់អ្នក។ តើមានអ្វីដែលខ្ញុំនឹងប្រាប់ដល់អ្នកនៅព្រឹកនេះ? នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកឃើញទេ? បើកចិត្តរបស់អ្នកហើយ និយាយ ថា "ឥឡូវនេះអ្នកដឹងទេ ខ្ញុំជឿថា ខ្ញុំអាចទទួលការប្រោសឲ្យជាបាន។" ល្អណាស់ អ្វីដែលនឹងកើត? តើជាព្រះបន្ទូលរបស់ព្រះអម្ចាស់ឬ? ប្រាកដណាស់នោះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។

207 ហើយបុរសម្នាក់*នេះ* នៅទីនេះបាននិយាយថា "ថ្ងៃនៃការអស្ចារ្យនេះ ត្រូវបានបញ្ចប់។ អ្នកមិនអាចធ្វើការ*នេះ* បានទេ។ ហើយអ្នក..."បំភ្លេចវាចោលទៅ។ ចាត់ទុកព្រះជាទីមួយសិន។

208 នេះនៃព្រះបន្ទូល ព្រះអម្ចាស់គាត់និយាយចេញ ហើយក៏សម្រេចដូចនោះ។

209 ឥឡូវអ្វីដែលសាតាំងបានធ្វើ? សាតាំងមានអ្នកចាក់ប្រេងតាំងផ្សេងទៀត។ ឥឡូវនេះ សាតាំងបានចាក់ប្រេងតាំងពួកអ្នកបំរើរបស់វា។ អូ ពិតមែន។ អូហូ។ ប្រាកដណាស់។ វាបានចាក់ប្រេងតាំងអ្នកបំរើរបស់វា។ តើវាចាក់ប្រេងតាំងពួកគេធ្វើអ្វី? ជាមួយនឹងការមិនជឿ។ សាតាំងនិងពួកបិសាចរបស់វាចាក់ប្រេងតាំងមនុស្សជាតិដើម្បីមិនឲ្យមនុស្សជាតិជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។

210 ឥឡូវនេះ ប្រសិនបើអ្នកចង់បញ្ជាក់ឲ្យច្បាស់សូមបើកទៅ លោកុប្បត្តិជំពូក ៣ ខ ៤ ។ តោះគ្រាន់តែបើកត្រឡប់មកវិញទីនោះ ហើយស្តាប់ ការនេះតែមួយនាទី ហើយមើលថាតើនោះមិនមែនជាលើកដំបូងទេ នៃយុទ្ធសាស្ត្រ។ នោះជារឿងដំបូង ដែលវាបានធ្វើ។ វាមិនដែលប្រើយុទ្ធសាស្ត្ររបស់វាដដែលទេ។ វាបានធ្វើវា

គ្រប់ ពេលវេលា។ ឥឡូវនេះ គ្រាន់តែមើលថាតើនោះ—នោះជាអ្វីដែលបានធ្វើ។ ឥឡូវនេះវាមិនយល់ស្របជាមួយព្រះបន្ទូលរបស់ព្រះទេ។ វាគ្រាន់តែបណ្ដាលឲ្យនាងទៅជាកាត់យល់ខុសបន្តិចអ្នកដឹងទេថាវា គ្រាន់តែជាសំឡេងនៃការស្ដាប់ ទៅដូចនេះថាហេតុអ្វីបានជាវាចង់ឲ្យយើងស្ដាប់ហើយមិនព្រមទទួលយកព្រះបន្ទូលទាំងមូល។ ឥឡូវនេះនៅលោកុប្បត្តិខ្ញុំបានរកឃើញនៅទីនេះ លោកុប្បត្តិ ជំពូក៣ខ៤។ តោះយើងមើលទៅថាតើនោះជាអ្វីដែលមាននៅក្នុងព្រះបន្ទូលឥឡូវនេះ។ ល្អណាស់។

*ពស់បាននិយាយទៅស្ត្រីម្នាក់នោះថាអ្នកនឹងមិនស្លាប់ជាពិតមែនទេ:*

211 "មិនស្លាប់ជាពិតមែនទេ។" អ្នកឃើញទេសម្ដីនោះជារបៀបដែលវាប្រើ? "អូ យើងជឿថ្ងៃ នៃការអស្ចារ្យនេះត្រូវបានកន្លងផុត។ យើងមិនជឿថា មានរឿងបែបនេះដែល មនុស្សបានទទួលព្រះវិញ្ញាណបរិសុទ្ធ ដូចដែលពួកគេ បានធ្វើនៅថ្ងៃបុណ្យទីហាសិបដែរ។ អូ ម្យ៉ាងវិញទៀត វិធីដែលអ្នកជ្រមុជទឹកមិនមានអ្វីខុសប្លែកទេ។" អ្នកឃើញទេនោះជាអារក្សសាតាំង? អ្នកឃើញទេ នោះជាយុទ្ធ សាស្ត្ររបស់វា? "មែនហើយប្រសិនបើវេជ្ជបណ្ឌិតបានប្រាប់អ្នកថា អ្នកមិនអាចជាសះស្បើយទេនោះគឺចប់។"

212 ឥឡូវ កុំជឿពាក្យនោះអី កុំជឿគ្រូពេទ្យអី។ គ្រូពេទ្យគឺជាការធ្វើតាមវិធីវិទ្យាសាស្ត្រ។ ហើយគ្រូពេទ្យបានធ្វើគ្រប់យ៉ាងអស់ហើយដើម្បីសង្គ្រោះជីវិតមនុស្សម្នាក់ៗប៉ុន្តែនៅតែមិនអាចសង្គ្រោះបានព្រោះគ្មានវិធីណាទៀតដែលគាត់អាចធ្វើបានឡើយ។ គាត់បានប្រើសមត្ថភាពរបស់គាត់អស់ហើយ។ មនុស្សគឺស្មោះត្រង់។ ប៉ុន្តែឥឡូវនេះដើមដឹងខុសត្រូវ គឺដឹងការមែន ប៉ុន្តែនៅពេលដែលអ្នក ប្រព្រឹត្តការនោះអ្នកនឹងបន្តដើមជីវិតម្ដងមួយជំហានៗ ជាបន្តបន្ទាប់។ អាម៉ែន។អស់ហើយ។វានឹងមានដំណើរយ៉ាងឆ្ងាយ។បាទ។

213 ឥឡូវនេះ តើយុទ្ធសាស្ត្ររបស់សាតាំងវាធ្វើយ៉ាងណាឥឡូវនេះ? តើទ្រង់មានព្រះបន្ទូលអ្វីនៅទីនេះ? ឥឡូវនេះសូមមើលខ១ និងខ—ខ២។ ឥឡូវនេះសូមអនុញ្ញាតឲ្យ—អនុញ្ញាតឲ្យខ្ញុំបានអានខ១ដល់ខ៣។

*ឯពស់ជាសត្វចេះឧបាយកលលើសជាងសត្វព្រៃអស់ទាំងសត្វព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយទៅកាន់ស្ត្រីថា តើ*

*ព្រះមានព្រះបន្ទូលហាមមិនឲ្យអ្នកបរិភោគ...គ្រប់ទាំងផ្លែឈើនៅក្នុងសួនច្បារមែនឬ?*

214 សូមស្តាប់ វានៅពេលនេះវាគ្រាន់តែប្រើរបៀបអាក្រក់ដែលវាមាន នឹងពីរបៀប—របៀបដែលវាប្រព្រឹត្តខុសពីព្រះបន្ទូលព្រះ។ អ្នកឃើញទេ? វាជា...តើវាកំពុងតែចង់ធ្វើអ្វី? វាបានចូលទៅក្នុងគំនិតរបស់នាង។ អ្នកឃើញទេ? វាបាននិយាយទៅនាងបន្ទាប់ពីព្រះបន្ទូលបានពង្រឹងនៅទីនោះ។

215 ឥឡូវនេះ កុំអនុញ្ញាតឲ្យអារក្សសាតាំង ពង្រឹងការរឹងមាំរបស់វាឲ្យសោះ។ អ្នកឃើញទេ? អ្នកបានរក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យមានភាពរឹងមាំក្នុងចិត្តរបស់អ្នក។ អ្នកឃើញទេ? អ្នកធ្វើដូច្នោះដូចគ្នា។ ឥឡូវនេះសូមអ្នកមើលទៅអ្នកមីកាយា។

*...ស្ត្រីឆ្លើយតបថាយើងបរិភោគអស់ទាំងផ្លែឈើនៅក្នុងសួនច្បារបានតែ...*

*តែត្រង់ដើមឈើ១ដែលនៅកណ្តាល(កណ្តាលនោះ អ្នកឃើញទេ) សួន ច្បារ*

*នោះព្រះទ្រង់មានព្រះ...បន្ទូលថាកុំឲ្យបរិភោគផ្លែនោះឡើយ ថែមទាំងកុំឲ្យពាល់ប៉ះផងក្រែងលោស្លាប់។*

216 អ្នកឃើញទេនោះហើយជាព្រះបន្ទូលឥឡូវនេះ។ នោះជាពាក្យដែលនាង បាននិយាយទៅអារក្សសាតាំង។ ឥឡូវសូមមើល។

*រួចពស់ក៏និយាយទៅស្ត្រីថា អ្នកមិនស្លាប់ជាពិតមែនទេ:*

217 អ្នកឃើញទេនោះជាទិចនិចរបស់វា? អ្នកឃើញទេ? តើវាកំពុងតែចង់ ធ្វើអ្វី? ការកើតដំបូងនៃមនុស្សវាបានព្យាយាមពង្វក់ស្ត្រីម្នាក់ដែលជាកូនស្រីរបស់ព្រះនិងការដែលមិនជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នោះហើយជាអ្វីដែល វាកំពុងតែព្យាយាមដើម្បីនាំនាងឲ្យប្រព្រឹត្តការនោះ។

218 នោះហើយ ជាអ្វីដែលវាបានព្យាយាម ដើម្បីនាំអ្នកឲ្យប្រព្រឹត្តការនោះ ប្អូនស្រីជាទីស្រលាញ់។ [បងប្រុសប្រាណហាំនិយាយទៅកាន់ប្អូនស្រីដែលឈឺនោះ ម្តងទៀត—Ed។] នោះហើយជាអ្វីដែល វា បានព្យាយាមពង្វក់អ្នករាល់គ្នា ដើម្បី នាំអ្នករាល់គ្នាប្រព្រឹត្តការនោះ។ ហើយ រឿងតែមួយគត់ដែលអ្នកត្រូវធ្វើឥឡូវ នេះ...

អ្នកមានសេរីភាពសីលធម៌។ ឥឡូវនេះ អ្នកអាចទទួលយកវាបានប្រសិនបើអ្នកចង់។ ប៉ុន្តែចូរទាត់វាចេញ។ បើសិនជានាងអេវ៉ាមិនបានឈប់នៅពេលនោះ ស្ដាប់! កុំឈប់ចំពោះអ្វីទាំងអស់។កុំឈប់។

219 នៅពេលដែល—នៅពេលដែលលោកអេលីយ៉ា បានប្រាប់លោក កេហាស៊ីថា "ចូរយកដំបងរបស់ខ្ញុំដាក់លើទារកដែលស្លាប់។ ហើយ ប្រសិនបើមាននរណាម្នាក់និយាយទៅកាន់អ្នក ចូរកុំនិយាយតបទៅវិញ។ ប្រសិនបើមានអ្វីមួយព្យាយាមបញ្ឈប់អ្នកគ្រាន់តែបន្តកុំឈប់ឲ្យសោះ។"

220 មើលទៅស្ត្រីម្នាក់ទៅដែលនាងបានហៅអ្នកបំរើរបស់នាង។ នាងនិយាយថា "អំណាចនៃមនុស្សក្បាលរឹងនឹងទៅមុខ ហើយកុំឲ្យអ្នកបញ្ឈប់ រហូតដល់ខ្ញុំប្រាប់អ្នក។"គ្រាន់តែប៉ុណ្ណឹង។

221 នៅពេលដែលអ្នកទទួលបានសារនេះ ចូរបន្ត។ អាម៉ែន។ ហើយ និយាយថា "ខ្ញុំមិនអាចដើរម្ដងទៀតបានទេ។ មិនអាចទេ ខ្ញុំកំពុងតែមាន ភាពទន់ខ្សោយ។" គ្រាន់តែបន្ត។ កុំបញ្ឈប់។ ផ្ទេរអ្វីគ្រប់យ៉ាង ដាក់មួយឡែក គ្រាន់តែរក្សាការធ្វើតាមរយៈការនោះ។ បងប្អូនអើយអ្នកបានទទួលដាវនៅក្នុងដៃរបស់អ្នក គ្រាន់តែបន្តការកាប់រហូតទៅ។

222 នៅពេលមួយខ្ញុំ បានចូលទៅក្នុងកីឡាដ្ឋានបាល់ទាត់មួយ ហើយខ្ញុំបានទៅ ដើម្បីអធិប្បាយ។ ហើយខ្ញុំបានឈប់នៅមាត់ទ្វារហើយមើលទៅទីនោះ។ វាបាន និយាយថា"វាមិនសំខាន់លើមាឌសត្វឆ្កែនៅក្នុងការប្រយុទ្ធឡើយ។តែជាកំលាំងការប្រយុទ្ធនៅក្នុងសត្វឆ្កែវិញ។"ដូច្នេះនោះជាអ្វីដែលឈ្នះសមរភូមិ។អ្នកឃើញទេ?

223 អ្នកនិយាយថា "មែនហើយ មើលទៅ។ មើលនៅក្នុងព្រះវិហារ ដ៏ធំទាំងអស់គឺប្រឆាំងនឹងការនេះ។"

224 ខ្ញុំមិនខ្វល់ពីទំហំមាឌដែលពួកគេមានឡើយ។វាជាកំលាំងនៅក្នុងសត្វឆ្កែនោះហើយជាអ្វីដែលគេរាប់ជាការប្រយុទ្ធ។ វាជាជំនឿ ដែលមាននៅក្នុង បុគ្គលម្នាក់ៗ។ ប្រសិនបើអ្នកជាមនុស្សកំសាកសូមត្រលប់ទៅជំរុំរបស់អ្នកវិញចុះ។ ប៉ុន្តែបងប្អូនអើយប្រសិនបើអ្នកជាទាហានម្នាក់ឈរនៅទីនោះ។ នោះការប្រយុទ្ធគ្នានឹងត្រូវចាប់ផ្ដើម។ខុសនិងត្រូវបាននៅជាមួយគ្នា។ សូមឲ្យយើងចាប់ផ្ដើមប្រយុទ្ធទៅ។

225 ដូចលោកពេត្រុសខាត់រ៉ាយបានចូលទៅក្នុងទីក្រុងមួយហើយបាននិយាយថា "ព្រះអម្ចាស់បានប្រាប់ខ្ញុំមក—មកទីនេះនិងមានការរីកផុសផុល។" លោកបានជួលឃ្លាំងមួយដ៏ចាស់ហើយ បានស្នាក់នៅទីនោះ ហើយលោកបានចាប់ផ្តើមសម្អាតវា។

226 ហើយពួកក្មេងដែលចូលចិត្តឆាឆៅដ៏សាហាវ នៃទីក្រុងបានស្នាក់នៅជិតនោះដែរពួកគេបានដើរមក។ ដល់ទ្វារ...ពួកគេមួយចំនួន បាននិយាយថា "តើបុរសម្នាក់នោះកំពុងធ្វើអ្វីនៅទីនោះ?"

227 ហើយទៀតនិយាយថា "គាត់គឺជាគ្រូអធិប្បាយម្នាក់។ លោកនឹងមានកិច្ចប្រជុំមួយលោកបាននិយាយដូច្នោះ។"

228 "ល្អ" គាត់បាននិយាយថា "ទាយមើលខ្ញុំនឹងដេញគាត់ចេញពីទីនេះទៅឲ្យនៅតាមផ្លូវវិញ។ អស់ហើយ។ យើងមិនចង់មានកិច្ចប្រជុំនៅជុំវិញកន្លែងរបស់យើងទេ។"

229 ដូច្នេះគេបានទៅហើយច្រានទ្វារតែម្តង។ លោកពេត្រុសខាត់រ៉ាយពាក់ អាវវែងរបស់គាត់អ្នកដឹងហើយគាត់ទើបតែលាងបង្គួចនិងជញ្ជាំងរួច។ ជាមនុស្សដែលគួរឲ្យអាណិតម្នាក់អ្នកដឹងហើយ។

230 ពួកគេបានចំអកដាក់គ្រូអធិប្បាយដែលមានអាយុចំណាស់ម្នាក់នេះ អ្នកដឹងហើយ ចំពោះការបរិភោគមាន់ដោយប្រើដៃ លិតដៃដូចសព្វថ្ងៃនេះ អ្នកដឹងទេ។

231 ដូច្នេះគាត់គ្រាន់តែលាងបង្គួចនិងជួសជុលរបស់របរនៅជុំវិញនោះ។ ពួកក្មេងដែលចូលចិត្តឆាឆៅដ៏សាហាវនៃទីក្រុងនោះ បានទាញអាវធំ របស់គាត់ ហើយផ្ទុងកាំភ្លើងខ្លីលើខ្លួនរបស់គាត់និងបាននិយាយថា "តើអ្នកកំពុងធ្វើអ្វី?"

232 "អូ!" គាត់បាននិយាយថា "ខ្ញុំកំពុងលាងសម្អាតបង្គួច។" ហើយគាត់នៅតែបន្តលាងបង្គួចដដែលអ្នកដឹងទេ។ គាត់មានគោល បំណងមួយ។ ព្រះបានប្រាប់ គាត់ឲ្យប្រកាន់ខ្ជាប់ការធ្វើការនោះដដែល។កំពុងលាងបង្គួច។

ពួកគេបាននិយាយថា "យើងមិនអនុញ្ញាតឲ្យកម្មវិធីរីកផុសផុលនៅទីនេះទេ"

233 គាត់បាននិយាយថា "អូ ប៉ុន្តែព្រះអម្ចាស់បានប្រាប់ខ្ញុំ—ឲ្យកម្មវិធីនៅទីនេះ។" អ្នកដឹងទេ? គាត់នៅតែបន្តការសម្អាតហើយគាត់ នឹងបញ្ចប់ការងាររបស់គាត់។ អ្នកឃើញទេ? ឃើញទេ?

234 "ល្អណាស់" គាត់បាននិយាយថា "មានរឿងមួយដែល—អ្នករាល់គ្នាត្រូវយល់។"ពួកគេបាននិយាយថា"ខ្ញុំជាម្ចាស់នៅជុំវិញទីក្រុងនេះ។"

235 គាត់បាននិយាយថា "អូ! ដូច្នេះផង?" ហើយគាត់នៅតែបន្តការលាង បង្ហួចអ្នកដឹងហើយ។

236 ពួកគេនិយាយថា "មុនពេលដែលអ្នកធ្វើកម្មវិធីការរីកផុសផុលនៅទីនេះត្រូវឆ្លងកាត់ខ្ញុំជាមុនសិន។"

គាត់បាននិយាយថា "អូ! តើខ្ញុំត្រូវធ្វើអ្វីខ្លះ? ជាការប្រសើរណាស់ខ្ញុំនឹងធ្វើការនោះបន្ទាប់ពីខ្ញុំបញ្ចប់ការងាររបស់ខ្ញុំសិន។"

237 គាត់បានដោះអាវធំរបស់លោក។ គាត់បានដើរទៅទីនោះ ហើយពួកគេបានក្របួចកអាវនិងវាយផ្តួលគាត់ទៅលើឥដ្ឋ និងលោតជាន់គាត់។ ហើយគាត់និយាយថា "ខ្ញុំត្រូវតែប្រយុទ្ធបើខ្ញុំមិនអាចគ្រប់គ្រងចិត្តបាន។ សូមបង្កើនភាពក្លាហានដល់ខ្ញុំព្រះអម្ចាស់។"ចាប់គាត់ចេញ។

ហើយនិយាយថា"អ្នកទទួលបានគ្រប់គ្រាន់ឬនៅ?"

238 គាត់បាននិយាយថា "បាទ។" គាត់បានក្រោកឡើងហើយរលាស់ ដៃរបស់គាត់។គាត់បានសង្គ្រោះនៅយប់នោះនៅក្នុងព្រះវិហារ។

239 គឺជាអ្នក ឃើញទេ? អ្នកបានដកចេញនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយប្រព្រឹត្តតាមការសង្ស័យរបស់អ្នកជារៀងរាល់។ ឃើញទេ? សូម ប្រាកដណាស់វាបានចប់ហើយ។ នោះហើយជាការងារបន្ទាប់ សូមធ្វើវាឲ្យបានសម្រេច។ ត្រូវហើយ។ រឿងដែលខ្ញុំនឹងធ្វើបន្ទាប់គឺបំបាត់ការសង្ស័យរបស់ខ្ញុំចោល។ នោះជាការងារបន្ទាប់ទៀតរបស់ខ្ញុំគឺ បំបាត់ការបាក់ទឹកចិត្តរបស់ខ្ញុំទាំងអស់ទៅឲ្យឆ្ងាយ។ បើសិនជាអារម្មណ៍ របស់ខ្ញុំប្រាប់ខ្ញុំថា "មែនហើយអ្នកមានអារម្មណ៍មិនល្អ" រឿងបន្ទាប់ដែល ត្រូវធ្វើគឺកាត់បន្ថយរឿងរ៉ាវទាំងអស់ចេញ។ ហ្នឹងហើយ។

240 អ្នកនិយាយថា"មែន អ្នក...ពួកគេបានប្រាប់ខ្ញុំថា...អ្នកដឹងទេមនសិការរបស់ខ្ញុំបានប្រាប់ខ្ញុំថា បងប្រុសប្រានហាំដែលខ្ញុំ..." មែនហើយ អ្នកប្រហែលជាអាចកាត់បន្ថយរឿងខ្លះចេញបានយ៉ាងល្អ។ អ្នកនឹងមិនទៅណាឆ្ងាយពីនោះទេ។ គ្រាន់តែ ធ្វើការងារបន្ទាប់របស់អ្នក ឲ្យបានសម្រេច។ ចូរដោះអាវធំរបស់អ្នក ហើយ

ដើរចូលទៅក្នុងនោះ។ គ្រាន់តែបន្តការនោះ។ គោលបំណងមួយថា "ខ្ញុំនឹងឈ្នះ។" អាម៉ែន។"ខ្ញុំមិនអាចចាញ់បានទេ។ខ្ញុំនឹងឈ្នះ។"អាម៉ែន។

241 អារក្សសាតាំងជាអ្នកពង្វក់។ អ្នកឃើញទេ? យុទ្ធសាស្ត្រទីមួយរបស់វា ជាអ្វី? តើអ្វីទៅជាចំណុចដំបូងរបស់វាដើម្បីទទួលបានជោគជ័យ? គឺចិត្ត។ នាងបាន ឈប់មួយភ្លែតដើម្បីស្តាប់នូវអ្វីដែលវាបាននិយាយ។ "អូ អ្នកមិនបាននិយាយដូច្នេះទេ?"

242 នោះហើយជាកន្លែងដែលស្ត្រីក្មេងៗ ជាច្រើនបានធ្វើ ឲ្យមានកំហុសហើយមនុស្សជាច្រើនបានប្រព្រឹត្តការខុសពួកគេឈប់មួយភ្លែតគ្រាន់តែ ឈប់មួយភ្លែត។ តើប៉ុន្មានដងដែលខ្ញុំបានឃើញពីករណីលែងលះគ្នានិងការអ្វីដែលកើតឡើងនៅទី នោះ។

243 "មែនហើយ ខ្ញុំប្រាប់អ្នក បងប្រុស ប្រានហាំ គេហួចដូច 'វ៉េត—វ៉ូវ' អ៊ីចឹង អ្នកដឹងទេ ហើយខ្ញុំបានឈប់ ហើយដោយ ស្មោះត្រង់ខ្ញុំ—ខ្ញុំមិនចង់ធ្វើដូច្នោះទេ។"អូហូ។អ្នកធ្វើរួចហើយ។

244 "អូ នាង ខ្ញុំបានអង្គុយតុក្បែរនាង។ នាង—នាងមានភ្នែក ស្រស់ស្អាតដាច់គេ!"អ្នកឃើញទេ? អូហូ។ឃើញទេ? ហ្នឹងហើយ។

245 អារក្សបានធ្វើរឿងដូចគ្នា។ អូ គ្រូពេទ្យបានប្រាប់ខ្ញុំថា"ខ្ញុំមិនអាចជាសះស្បើយបានទេដូច្នេះខ្ញុំ..."គឺអ្នកនៅទីនោះបានជួបប្រទះរឿង ដូចគ្នាក្នុងការប្រយុទ្ធដ៏ធំបំផុតដែលមិនដែលជួបប្រទះ។

246 "មែនហើយពួកគេបានប្រាប់ខ្ញុំ...ខ្ញុំបានឃើញ*ដូច្នេះ–ដូច្នេះ–ដូច្នេះ*បញ្ជាក់ថាមកពីព្រះវិញ្ញាណបរិសុទ្ធ។" បាទ ចូរអ្នកមើលមនុស្សកំពុងចំណាស់ ខ្លះមានការភ័យខ្លាច។ តើធ្វើដូចម្តេចទើបដឹង ពីពួកគេថាពិតជាមានមែន? អូហូ។ បាទ។ អារក្សនេះនឹងប្រើអ្នក ជានុយសម្រាប់សត្វក្អែក ប៉ុន្តែវានឹងមិនបង្ហាញអ្នក នូវសត្វព្រាបទេ។ អូហូ ពិតប្រាកដណាស់។ ហើយវានឹងធ្វើឲ្យអ្នក មិនយល់អ្វីទាំងអស់។

247 អូ! គាត់ជាអ្នកចម្បាំងម្នាក់ដែរ ចូរចងចាំ។ ប៉ុន្តែដែលអស្ចារ្យនោះ គឺពួកយើងទេ..."ដែលអស្ចារ្យនោះគឺ វាបានស្ថិតនៅក្នុងអ្នក ហើយវានៅក្នុងលោកិយ៍ដែរ" ប៉ុន្តែចូរប្រកាន់ខ្ជាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចូរជឿថាទ្រង់ជាមេទ័ពដែលដឹក នាំ

នៅទីនេះ។ ចូរកាន់ បន្ទាយរបស់បងប្អូន។ នោះជាការត្រឹមត្រូវចូរបំពេញ កាតព្វកិច្ចរបស់អ្នក។

248 ដូច្នេះ ខ្ញុំបានជួបក្មេងស្រីតូចម្នាក់នៅទីនេះម្តង។ ក្មេងស្រីនេះ ប្រហែលជាអង្គុយនៅទីនេះដែរ ឥឡូវនេះ។ ឈ្មោះរបស់នាងគឺ ណោលី សាន់ដឺរ។ ជាលើកដំបូងដែលខ្ញុំធ្លាប់បានឃើញសាតាំងចេញពីនាង។ យើងបានរស់នៅ ឥឡូវនេះ ប្រសិនបើខ្ញុំគ្រាន់តែនៅកន្លែងណាមួយ ហើយ គ្រាន់តែមានផ្លូវបីចន្លោះ នៅទីនេះដែលមានគ្រោះថ្នាក់។ ហើយខ្ញុំទើបតែបានក្លាយទៅជាគ្រូអធិប្បាយ ម្នាក់ ហើយខ្ញុំបានផ្សាយដំណឹងល្អនៅទីនេះ នៅជ្រុងផ្លូវនេះ ដោយមានការជួបប្រជុំមួយ។

249 ហើយក្មេងស្រីតូច នោះជាម្នាក់ក្នុង ចំណោមនៃអ្នករបាំដ៏ល្បីនោះដែរ។ នាងបានរៀននៅសាលារៀនទីនេះ ជាមួយលីហ៊ានដែរ។ មានមនុស្សជាច្រើន នៅទីនេះលីហ៊ា រស់នៅក្នុងទីក្រុងនេះដែរ អ្នកដឹងទេ នាងបានរត់ទៅអាងហែលទឹក។ ដូច្នេះហើយ លីហ៊ាន និងមិត្តរបស់នាងគឺជាអ្នករាំរបាំដែលល្បីបំផុតនៅក្នុងប្រទេស។ពួកគាត់ជាពួកកាតូលិក។ ជំនឿសាសនាមិនមានន័យថាគ្មានអ្វីសម្រាប់ ពួកគាត់ទេដូច្នេះបន្ទាប់មក...ណោលីហើយនឹងពួកគេ។ ដូច្នេះនាងជាអ្នករាំដ៏ល្បី ល្បាញហើយគាត់ដូចគ្នាដែរ។ ហើយពួកគេបានមករាំរបាំនៅទីនេះគេហៅថា "បាតខ្មៅ"និង"រាំហ្សីត័របឹក"ហើយមានគ្រប់ទាំងរបស់។ ហើយនាងគឺ ជា... ពួកគេទាំងពីរគឺល្បីបំផុតនៅក្នុងប្រទេសនេះ។

250 ថ្ងៃមួយនាងបានបង្កើតកិច្ចប្រជុំមួយឡើងនៅទីនេះ បានមួយយប់។ នាងបានលុតជង្គង់នៅមុខអាសនៈ ហើយក្មេងស្រីណោលីបានផ្លាស់ប្តូរ។ ព្រះពរបាន ចូលដល់ចិត្តរបស់នាង។ នាងបានក្រាប់នៅមុខអាសនៈនោះ។ ហើយនាងបាន ងើបក្បាលរបស់នាងឡើងវិញ។ នាងបានយំហើយទឹក ភ្នែកកំពុងរត់នៅលើថ្ពាល់ របស់នាង។ នាងបាននិយាយថា"ប៊ីលី..." នាងបានស្គាល់ខ្ញុំ។ នាងបាននិយាយ ថា"ខ្ញុំចង់ទទួលបានការសង្គ្រោះឲ្យរួចពីការអាក្រក់ណាស់។"

251 ហើយខ្ញុំនិយាយថា "ណោលី អ្នកនឹងបានសង្គ្រោះ។ ព្រះយេស៊ូវបានសង្គ្រោះអ្នករួចទៅហើយប្អូនស្រី។ អ្នកត្រូវតែទទួលយកទ្រង់ឥឡូវនេះ ដោយកាន់តាមព្រះបន្ទូលរបស់ទ្រង់។"

252 ហើយនាងបាននៅទីនោះ។ ហើយនាងបានយំ ហើយនាងបាន អធិស្ឋាន ហើយនាងបានទូលទៅ ព្រះជាម្ចាស់ថានាងនឹងមិនធ្វើតាម លោកិយ៍ម្តងទៀត

ឡើយ។ ថ្វាយទាំងអស់ដាក់នៅទ្រង់តែមួយសន្តិភាពការផ្អែមល្ហែមគួរឲ្យស្រឡាញ់បាន ចូល មកក្នុងព្រលឹងវិញ្ញាណរបស់នាង។ នាងបានងើបឡើងពីទីនោះ ហើយស្រែក និងសរសើរតម្កើងព្រះជាម្ចាស់ ទាំងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ផង។

253 ហើយប្រហែលប្រាំមួយឬប្រាំបីខែបន្ទាប់ពីនោះនាងបានដើរតាម ផ្លូវស្ត្រីងនៅយប់មួយ។

254 ឥឡូវនេះ គ្រាន់តែក្មេងស្រីម្នាក់ នាងគឺគ្រាន់តែជាក្មេងជំទង់ អាយុ ប្រហែលដប់ប្រាំបីឆ្នាំ។ ហើយនាងបានមករកខ្ញុំ ហើយនាងបាននិយាយ ថា "ហូប..."នោះជាភរិយារបស់ខ្ញុំ ម្នាក់ដែលបានស្លាប់ទៅនោះ។ នាងបាន និយាយថា"ខ្ញុំសង្ឃឹមថា ខ្ញុំនឹងដូចជាហូបនិងអាយរិន។" នាងបាននិយាយថា "អ្នកដឹងទេពួកគេមិនចេញមកលោកិយ៍នេះទេ។" ហើយបាននិយាយថា "លោកិយ៍នេះបានដាក់សញ្ញាសម្គាល់មួយនៅលើអ្នក។" ហើយបាននិយាយទៀត ថា "ខ្ញុំមើលទៅវាអាក្រក់ណាស់។" ហើយបាននិយាយទៀតថា "ឥឡូវនេះខ្ញុំ បានបញ្ឈប់ការតុបតែងមុខនិងពាក់អលង្ការហើយ ប៉ុន្តែខ្ញុំដឹងថាវាជាការលំបាកណាស់។ សូម្បីតែករណីនេះដែលខ្ញុំត្រូវប្រឈមមុខ" នាងបាននិយាយថា"ខ្ញុំមើលទៅវាជាការលំបាកណាស់។" នាងបាននិយាយទៀតថា "ពួកគេ មើលទៅដូចជាគ្មាន កំហុស និងការសង្ស័យអ្វីទេ។" បាននិយាយថា "ខ្ញុំសង្ឃឹមថា ខ្ញុំនឹងមិនធ្វើការទាំងនោះទេ។"

255 ខ្ញុំ បាននិយាយថា "ណេលី ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ បានសំអាតអំពើបាបរបស់មនុស្សទាំងអស់ណាប្អូនស្រី។ចូរបន្តជឿទ្រង់ចុះ។"

256 លោករ៉េនី ប្លេដូ នៅទីនេះមានមនុស្សជាច្រើនបានស្គាល់គាត់ដែលជាមិត្តភក្តិជិតស្និទ្ធរបស់ខ្ញុំជាច្រើនឆ្នាំមកហើយ។ គាត់គឺជាអ្នកប្រមឹក។ ហើយគាត់បានមកទីនេះជាមួយបងប្រុសរបស់ខ្ញុំគឺលោកអីដវដ។ ហើយគាត់បានស្រវឹងហើយដើរតាមចិញ្ចើមផ្លូវហើយខ្ញុំបានលើកគាត់ឡើង ពីព្រោះប៉ូលីសបានតាមចាប់គាត់។ ហើយខ្ញុំបាននាំគាត់ មកទីនេះ។ ហើយខ្ញុំជាគ្រូគង្វាលម្នាក់ ព្រមទាំងម្តាយនិងឪពុករបស់ខ្ញុំ បានរស់នៅទីនេះ តាំពីខ្ញុំបានរៀបការរួចម្លេះ។ ហើយខ្ញុំបានយកគាត់ដាក់នៅលើគ្រែនៅទីនោះ។ ខ្ញុំបានដេក...ដេកនៅ លើកន្លែង មួយ។ ជាក្រុមធំរបស់ប្រាណហាំ តើអ្នកដឹងទេដប់នាក់នៃយើង។ ដូច្នេះហើយយើងមានប្រហែលបួនបន្ទប់ ហើយមួយបន្ទប់មានពីរនាក់។ ដូច្នេះ ខ្ញុំបានឈានជើងទៅកន្លែងមួយទៀត។ ខ្ញុំបានដកវាចេញដូច *នេះ* ហើយ—ហើយ បានដាក់លោករ៉េ

នីនៅលើគ្រែជាមួយខ្ញុំ។គាត់បានស្រវឹងខ្ញុំបានគ្រាគាត់ដាក់នៅ ក្នុងផ្ទះហើយដាក់គាត់ផ្ដេកចុះ។

257 ហើយខ្ញុំបានដាក់គេនៅទីនោះ។ ខ្ញុំបាននិយាយថា"លោកវេនីគឺមិនខ្មាស់ខ្លួនឯងដែលក្លាយជាបែបនោះទេ?"

258 ហើយលោកបាននិយាយថា "អូ លោក ប៊ីលី កុំនិយាយ ជាមួយខ្ញុំ ដូច្នោះ។"

ហើយបន្ទាប់មកខ្ញុំបានលើកដៃរបស់ខ្ញុំបួងសួងឡើង។ ខ្ញុំបាននិយាយថា "ខ្ញុំនឹង អធិស្ឋានសម្រាប់អ្នកលោកវេនី។ សូមព្រះប្រទានពរដល់អ្នក។" ហើយខ្ញុំ បានសង្គ្រោះអូខ្ញុំគិតថាប្រហែលជាមួយឆ្នាំ។

259 ដូច្នេះហើយបន្ទាប់មក អ្នកទាំងអស់គ្នានៅពេលតែមួយ—មួយ ហើយបានគោះទ្វារហើយមាននរណាម្នាក់កំពុងគោះទ្វាខ្លាំងៗ។ "បងប្រុសប៊ីល! បងប្រុសប៊ីល!"[បងប្រុសប្រានហាំបានគោះលើវេទិការ—Ed។]

260 គិតដូច្នេះថា "សេចក្ដីល្អរបស់ខ្ញុំ នរណាម្នាក់ត្រូវតែស្លាប់។" ខ្ញុំបានរត់ទៅឯទ្វារ បានចាប់យកអាវចាស់របស់ខ្ញុំនៅទីនោះបោះវាដូច *នេះ* ហើយដណ្ដប់ទៅលើលោកវេនី។ហើយរត់ទៅកាន់ទ្វារ។

261 វាដូចជាស្ត្រីម្នាក់។ ខ្ញុំបានបើកទ្វារ ហើយក្មេងស្រីម្នាក់នេះបានឈរ នៅមាត់ទ្វារ។ នាងបាននិយាយថា "អូ! ខ្ញុំអាចចូលក្នុងបានទេ?"

ខ្ញុំបាននិយាយថា"អញ្ជើញចូលក្នុងមក។"ហើយខ្ញុំបានបើកភ្លើង។

262 ហើយឥឡូវនេះនាងកំពុងតែយំដូច្នោះហើយនាងបាននិយាយថា"អូ! បងប្រុស ប៊ីលីខ្ញុំ—ខ្ញុំ—ខ្ញុំទៅហើយ! ខ្ញុំទៅហើយ!"

263 ខ្ញុំបាននិយាយថា "តើមានបញ្ហាអ្វីណោលី? អ្នក—មានជំងឺគាំងបេះដូងឬ?"

264 នាងបាននិយាយថា "ទេ" ហើយនាងនិយាយថា "បងប្រុសប៊ីលខ្ញុំបានមក កាន់ស្ត្រីង។" ហើយនាងនិយាយថា "និយាយឲ្យ ស្មោះត្រង់ទៅ បងប្រុសប៊ីល! ស្មោះត្រង់ណាស់ បងប្រុសប៊ីល មិនដែលមានបំណងអាក្រក់នោះទេ។ ខ្ញុំគ្មានបំណងអាក្រក់នោះទេ។"

265 ខ្ញុំបាននិយាយថា "តើមានបញ្ហាអ្វី?" ខ្ញុំបានគិតថា "តើខ្ញុំនឹងធ្វើយ៉ាងណានឹងនាងឥឡូវនេះ?" ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ។ ខ្ញុំទើបតែស្គាល់នាង។ ខ្ញុំនិង...

266 បាននិយាយទៀតថា "អូបងប្រុស ប៊ីល" បាននិយាយថា "ខ្ញុំគ្រាន់ តែ—ខ្ញុំគ្រាន់តែ—ខ្ញុំគ្រាន់តែជាអ្នករួមចំណែកតែបន្តិចបន្តួចប៉ុណ្ណោះ។"

ខ្ញុំក៏និយាយថា"ឥឡូវនេះសូមស្ងៀមស្ងាត់ប្អូនស្រី។ សូមប្រាប់ខ្ញុំពីការនោះ។"

267 ហើយនាងបាននិយាយថា "ចាស" នាងបាននិយាយថា "ខ្ញុំបានដើរតាមចិញ្ចើមផ្លូវហើយបានដល់សាលប្រជុំរ៉េដមែន..."ហើយពួកគេ ធ្លាប់មានការរាំរែករៀងរាល់យប់ថ្ងៃសៅរ៍នៅទីនោះ។ ហើយនាងបាននិយាយថា "ខ្ញុំមានវត្ថុមួយចំនួនហើយខ្ញុំបានទៅផ្ទះដើម្បីពាក់វា។" ហើយនាងបាននិយាយថា "ខ្ញុំបានឮចម្រៀងនោះ។" ហើយនាងបាននិយាយថា"អ្នកដឹងទេ" ហើយបាននិយាយថា "ខ្ញុំបានឈប់ប្រហែលមួយនាទី។" ហើយនិយាយថា "វាកាន់តែមានសម្លេងពិរោះ ជាងមុនទៀត។ ដូច្នេះខ្ញុំគិតថា 'អ្នកដឹងទេ វាមិនខាតបង់អីទេ ប្រសិនបើខ្ញុំឈរទីនោះ។'"

268 នោះគឺជាអ្វីដែលនាងបានធ្វើខុសនាងបានឈប់មួយភ្លែត។ ហើយនាងគ្រាន់តែស្តាប់។

269 ហើយនិយាយថា "ចាស ខ្ញុំនឹងគិត។" បាននិយាយទៀតថា "ឱព្រះអម្ចាស់អើយទ្រង់ដឹងថាខ្ញុំស្រឡាញ់ទ្រង់ណាស់។" ហើយបាននិយាយថា "អ្នកដឹងថាខ្ញុំ ស្រឡាញ់ព្រះអម្ចាស់ណាស់។ ប៉ុន្តែខ្ញុំចាំប្រាកដនៅពេលដែលលើហើយនឹងខ្ញុំបានឈ្នះ —ពានរង្វាន់នោះ។"បាននិយាយថា "ការចងចាំរបស់ខ្ញុំ ខ្ញុំចាំថាតន្ត្រីវ៉ាយចំណាស់ នេះធ្លាប់ បានទាក់ទាញខ្ញុំ។ ខ្ញុំមិនដឹងថាវានឹងធ្វើអ្វីទៀតទេ ឥឡូវនេះ។"

270 អូហូ! អ្នកគ្រាន់តែគិតថាវាមិនអាចទៀតទេ។ វាបានកើតរួចទៅហើយនៅទីនោះ។ នោះគ្រាន់តែជាការល្អដូចដែលវាចង់បាននៅទីនោះ។ អ្នកឃើញទេ?

271 តើមានប៉ុន្មាននាក់ដែលធ្លាប់ស្គាល់នាង ណេលីសាន់ដឺរ? ជាការប្រសើរណាស់ ខ្ញុំអាចទាយបានថា ភាគច្រើនអ្នកទាំងអស់គ្នា បានស្គាល់នាង។ បាទ។ ប្រាកដណាស់។ដូច្នេះពួកគេ—គេ—គេបាន...

272 ហើយបាននិយាយថា នាងបាននិយាយថា "ល្អណាស់ អ្នកដឹងថា ជាអ្វីទេ?" នាងបាននិយាយថា"បើខ្ញុំបានដើរតាមតាំងពីពេលនោះ"បាននិយាយថា"ប្រហែលជាខ្ញុំអាចនឹងថ្លែងពីទីបន្ទាល់មួយចំនួនដល់ពួកគេ។"

273 អូ! ឃើញទេ អ្នកបានធ្លាក់ចូលក្នុងការគ្រប់គ្រងរបស់អារក្ស។ សូមចេញ ឲ្យឆ្ងាយពីវា។"សូមជៀសចេញពីអំពើអាក្រក់របស់អារក្ស។"

274 ប៉ុន្តែនាងបានដើរទៅហើយបានឈរនៅទីនោះប្រហែលពីរបីនាទី។ ហើយរឿង ដំបូងអ្នកត្រូវដឹង គឺនាងបាននៅក្នុងដៃរបស់ក្មេងប្រុសម្នាក់នៅលើតដួ នោះ។

275 បន្ទាប់មកនាងបានក្រោកឡើងវិញ។ ហើយនាងបានឈរយំ នៅ ទីនោះ ហើយនិយាយថា "អូ ខ្ញុំអស់អីពីខ្លួនហើយឥឡូវនេះ ខ្ញុំគ្មានអ្វីល្អទៀតទេ។ខ្ញុំ..."

276 ខ្ញុំគិតថា "មែនខ្ញុំមិនសូវចេះអំពីព្រះគម្ពីរប៉ុន្មាននោះទេប៉ុន្តែខ្ញុំជឿថាព្រះយេស៊ូវមានព្រះបន្ទូលដូចនេះថា 'ដោយនូវឈ្មោះរបស់ខ្ញុំ ពួកគេនឹងដេញអារក្សចេញពីមនុស្សបាន។'"ខ្ញុំ...

277 ហើយ វេនីបានដឹងខ្លួនបន្តិច ហើយអង្គុយនៅទីនោះមើល។ អ្នកឃើញទេ? ដូច្នេះខ្ញុំបាននិយាយថា "អារក្ស ខ្ញុំមិនស្គាល់ថាឯងជា នរណានោះទេប៉ុន្តែខ្ញុំប្រាប់ឯងឥឡូវ នេះគឺជាប្អូនស្រីរបស់ខ្ញុំ ហើយឯងមិន ត្រូវ ធ្វើអ្វីទៅលើនាងទេ។នាងមិនចង់ធ្វើបែបនោះទេ។ នាងគ្រាន់តែឈប់មួយនាទី។" នោះហើយជាកន្លែងដែលនាងបានធ្វើខុស។ ខ្ញុំបាននិយាយថា"ប៉ុន្តែឯងត្រូវតែ ចេញពីនាង។តើឯងឮខ្ញុំទេ?"

278 ដូច្នេះហើយ ឱព្រះជាម្ចាស់អើយ សូមជួយខ្ញុំ ក្នុងការកាត់ទោស នេះផង។ ទ្វារនឹងចាប់ផ្តើមបើក ហើយបិទដោយខ្លួនវាផ្ទាល់។ "ឈរតម្រង់ជួរ ឈរតម្រង់ជួរ" នៅទ្វារនោះ។ "តម្រង់ជួរ ការ—តម្រង់ជួរ ការ—តម្រង់ជួរ។"ខ្ញុំគិតថា។

ហើយនាងនិយាយថា"លោកប៊ីលចូរមើលនៅទីនោះ។ មើលនៅទីនោះ។"

ហើយខ្ញុំបាននិយាយថា "មែនហើយ។ តើនោះជាអ្វី?"

នាងបាននិយាយថា"ខ្ញុំមិនដឹងទេ។"

ខ្ញុំបាននិយាយថា"ខ្ញុំមិនដឹងដូចគ្នាដែរ"។

279 ហើយទ្វារ "បិទបើក បិទបើក" បិទដូចនោះ។ ខ្ញុំគិតថា"តើមានបញ្ហាអ្វីនៅទីនេះ? តើមានរឿងអ្វីកើតឡើង?"

280 ខ្ញុំបានមើលម្តងទៀតដូច*នោះ*។ ហើយខ្ញុំបាននិយាយថា "ថយចេញពីនាងភ្លាមសាតាំងអើយ! នៅក្នុងព្រះយេស៊ូវចេញពីនាងទៅ!"

281 នៅពេលដែលខ្ញុំបាននិយាយដូច្នោះ វាមើលទៅដូចជាប្រជាវយ៉ាងធំ ប្រហែលវែងប៉ុ*នេះ* បានហើរចេញពីក្រោយខ្នងរបស់នាង តាមសក់និងស្លាបប្រជៀវរបស់

នាងនិងចេញពីជើងរបស់នាង*ដែរ* ។ វាបានចេញទៅព្រុសូរ "អ៊ូ" ។ វាបានចាប់ផ្តើមចេញមកនៅចំពោះមុខរបស់ខ្ញុំវាបានចេញមកយ៉ាងច្រើន។

282 ខ្ញុំបាននិយាយថា "បពិត្រព្រះអម្ចាស់ ព្រះលោហិតនៃ ព្រះយេស៊ូវគ្រីស្ទបានការពារខ្ញុំពីការនោះ។"

283 បន្ទាប់មក វេនី នាងបានលោតឡើងទៅលើគ្រែ មើលចុះ។ ហើយនៅទីនេះវា ដូចជាមានស្រមោលរង្វង់ដ៏ធំ បានវិញជុំវិញគ្រែរបស់ នាង។ ហើយបានចេញពីគ្រែរបស់វេនី ទៅនៅក្នុងបន្ទប់ផ្សេង ទៅយ៉ាងលឿនដូចដែលវាអាចធ្វើបាន។ ដូច្នេះយើង...

284 ខ្ញុំទៅទទួលណេលីនិងនាំនាងត្រលប់ទៅផ្ទះរបស់នាងវិញ។ ហើយខ្ញុំត្រឡប់មកវិញហើយខ្ញុំមិនអាច...

285 ម៉ាក់របស់នាងបានទៅទីនោះ ហើយមានការរន្ធត់ជាខ្លាំង ហើយបាន ដើររកនាងគ្រប់ទីកន្លែង។ គ្មានអ្វីទាំងអស់នៅក្នុងបន្ទប់។ តើមានរឿងអ្វី? អារក្សបានចេញពីខ្លួននាង។ តើមានអ្វីកើតឡើង? នាងបានឈប់ មួយភ្លែត។ បេងប្រុស ប្រានហាំបានឡើងលើវេទិកានេះពីរដងហើយ—Ed។]គឺតែប៉ុណ្ណឹង។

286 កុំឈប់ឲ្យសោះ។ នៅពេលដែលព្រះបន្ទូលរបស់ទ្រង់បានចាក់ចូលទៅក្នុងចិត្តរបស់អ្នកគ្រាន់តែយក ដាវកាត់ហើយកាប់សម្លាប់ទៅ។ ហាលេលូយ៉ា!

287 "ខ្ញុំមិនមានពេលរង់ចាំការឥតប្រយោជន៍ឡើយ។ គ្រាន់តែធ្វើវាឥឡូវនេះខ្ញុំ មិនមានពេលគ្រប់គ្រាន់ផង។"

288 គាត់និយាយថា "អើ ចូរយកសម្ភារះរបស់ខ្ញុំមកហើយដាក់វានៅលើទារកនោះ។ ហើយប្រសិនបើមាននរណាម្នាក់និយាយទៅកាន់អ្នកសូមកុំសូម្បីតែនិយាយទៅកាន់ពួកគេវិញឲ្យសោះ។"

289 ប្រសិនបើមានអារក្សនិយាយថា"ហ្អេតើអ្នកដឹងពីអារម្មណ៍ដែលអ្នកកំពុងមានទេ?"កុំនិយាយជាមួយវា។គ្រាន់តែបន្តការងាររបស់អ្នក។

290 អារក្ស តើអ្នកដឹងទេ អារក្សសាតាំងបាននិយាយថា "ប៉ុន្តែអ្នកដឹងទេ? អ្នកដឹងទេ*ដូច្នេះ-ហើយ-ដូច្នេះ* ទំរាំតែពួកគេទទួលព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកចាំទេថាពួកគេ—ពួកគេស្ទើរតែបាត់បង់គំនិតរបស់ពួកគេហើយ។" កុំសូម្បីតែនិយាយទៅកាន់វា។ គ្រាន់តែបន្តការងាររបស់អ្នក។ អ្នកមិនដឹង ពី *ស្អី-ជា-ស្អីនោះទេ*។

291 វាជារឿងរវាងអ្នកនិងព្រះ។ ហ្នឹងហើយ។ ដើរតាមព្រះ។ ទ្រង់នឹងចាក់ ប្រេងតាំងសម្រាប់អ្នកបំរើរបស់ទ្រង់។ ខ្ញុំត្រូវតែប្រញាប់។ ព្រះបានចាក់ ប្រេងតាំង ដល់ពួកអ្នកបម្រើរបស់ទ្រង់។អ្នកឃើញទេ?

292 ឥឡូវនេះខ្ញុំបាននិយាយពីរបីចំនុចនៅទីនេះប៉ុន្តែខ្ញុំចង់និយាយនៅ ទីនេះបន្តិច ទៀត។នៅទីនេះចូរស្តាប់ដោយយកចិត្តទុកដាក់ឥឡូវនេះ។

293 ក្មេងស្រីតូច ចូរស្តាប់ដោយយកចិត្តទុកដាក់ ឥឡូវនេះ។ [បងប្រុស ប្រានហាំបាននិយាយទៅកាន់ក្មេងស្រីដែលឈឺនោះ—Ed។]

294 នៅទីនេះយើងបានឃើញអំពីយុទ្ធសាស្រ្តរបស់សាតាំង។ តើយើងត្រូវធ្វើដូចម្ដេច? ឥឡូវនេះ ខ្ញុំមានបទគម្ពីរជាច្រើននៅទីនេះ នៃរឿងរបស់ព្យាការីនិងជាកន្លែងដែលវាបានធ្វើការអាក្រក់ដល់ពួកគេ និងប្រជាជន ផ្សេងៗទៀត តាមរយៈព្រះគម្ពីរបានមានព្រះបន្ទូល។ វាជាយុទ្ធសាស្រ្ត ដែលអារក្សបានប្រើ ដើម្បីពង្វក់មនុស្សកុំឲ្យជឿដល់ព្រះបន្ទូលរបស់ព្រះ។ ចូរស្តាប់អ្នកជាទាហានឈើឆ្កាង។ នៅពេលដែលអ្នកមិនជឿដល់ព្រះបន្ទូលនៃព្រះ គម្ពីរបានសរសេរទេអ្នកដូចជាគ្មានអាវុធនៅក្នុងដៃដែរ។

295 ចូរមានជំនឿណាប្អូនស្រី? [បងប្រុសប្រានហាំនិយាយទៅកាន់ក្មេងស្រីដែលឈឺនោះម្តងទៀត—Ed។]

296 អ្នកគ្មានអាវុធនៅក្នុងដៃទេ។ អ្នកនឹងចុះចាញ់ អ្នកនឹងចុះខ្សោយ។ ចូរប្រដាប់គ្រឿងសឹករបស់ព្រះជាម្ចាស់។ អាម៉ែន។ យើងកំពុងស្ថិតក្នុង សមរភូមិមួយ។ អ្វីដែលព្រះបាននិយាយគឺជាការពិត។ "គ្រប់សម្ដីរបស់អារក្សសុទ្ធតែជាការកុហក។" អ្នកឃើញទេ? ប៉ុន្តែកាលណាអ្នក...អ្នកទៅស្តាប់ យុទ្ធសាស្រ្តរបស់ខ្លួនវា នោះអ្នកគ្មានអាវុធនៅនឹងដៃទេ។

297 តើប៉ុន្មានរឿងដែលនាងអេវ៉ាបានស្តាប់អារក្ស? មួយរឿង។ នាងត្រូវ បានវាដក ហូតអាវុធពីដៃរបស់នាង។ តើអារក្សបានធ្វើអ្វីខ្លះ? វាបានចូល ទៅដល់ចិត្តនិង វិញ្ញាណរបស់នាង ហើយនាងបានក្លាយជាមនុស្សខូចភ្លាម។ តើត្រូវទេ? នាងបានក្លាយជាមនុស្សខូច នៅនាទី ដែល វាដកហូតអាវុធពីនាង នៅពេលដែលនាងមិនជឿដល់ព្រះបន្ទូលនៃព្រះ។ ត្រឹមត្រូវណាស់។ នៅទីនេះយើងបានឃើញយុទ្ធសាស្រ្តរបស់វា។

298 ទាហានរបស់ព្រះត្រូវបានបញ្ជាឲ្យទៅ"ចូរប្រដាប់គ្រឿងសឹកនៃព្រះ។" តើត្រូវ ទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed។] ឥឡូវនេះ ប្រសិនបើអ្នកចង់សរសេរបទគម្ពីរនេះចូល វានៅក្នុងគម្ពីរអេភេសូរ ជំពូក6:10 និង 13 អ្នកឃើញទេ? យើង បានអានវារួចហើយ។ វាជាអត្ថបទរបស់យើង។ ត្រឹមត្រូវណាស់។ចូរចំណាំ។ "ចូរប្រដាប់គ្រឿងសស្ត្រាវុធរបស់ព្រះ។" ចូរ...តើអ្នកមានពេលពីរបីនាទីទៀតទេ? ["អាម៉ែន។]" ចូរត្រឡប់ទៅក្រោយមួយនាទី។ គ្រាន់តែមើល នូវអ្វីដែលជាគ្រឿងសាស្ត្រាវុធនៃព្រះ។ ត្រឹមត្រូវណាស់។ ចូរចាប់ផ្ដើម អានពីខ១០។ ឥឡូវសូមស្ដាប់ដោយយកចិត្តទុកដាក់។ សូមឲ្យយើង ស្វែងរក នូវគ្រឿងសាស្ត្រាវុធនៃព្រះ។ "ឯសេចក្ដីឯទៀតបងប្អូនអើយ..."ឥឡូវនេះខ្ញុំដឹងថាខ្ញុំនឹង...ខ្ញុំ...

299 វាខ្វះញម្ភៃនាទីទៀតម៉ោង12។ ខ្ញុំ—ខ្ញុំមិន...ខ្ញុំមិនចង់បង្រៀនអ្នកយូរពេកទេថ្ងៃនេះប៉ុន្តែខ្ញុំ—ខ្ញុំមិនអាច ប៉ុន្តែមានសារមួយទៀត រហូតដល់ខ្ញុំធ្វើដំណើរត្រឡប់មកទីនេះនៅរដូវក្ដៅហ្នឹងហើយ។

300 ហើយអ្នកដឹងទេថា? អ្នកដឹងថាហេតុអ្វីខ្ញុំធ្វើការនេះ? ខ្ញុំនឹងប្រាប់អ្នក។ នៅថ្ងៃបន្ទាប់ទៀតដែលខ្ញុំនឹងមានការសុបិន្ត។ ខ្ញុំនឹងមិនប្រាប់ ពីរឿងនោះទេ ប៉ុន្តែវាគ្រាន់តែស្ថិតនៅក្នុងគំនិតរបស់ខ្ញុំ។ ខ្ញុំអាចធ្វើវាដូច្នោះដែរក្រោយពីព្រះអម្ចាស់បានប្រទានការសង្គ្រោះឲ្យខ្ញុំ។

301 ខ្ញុំបានសុបិន្តឃើញថាខ្ញុំឆ្លងកាត់ទន្លេមួយដ៏ធំចំពោះបេសកកម្ម នេះ។ ហើយឥឡូវនេះ ជាលើកដំបូងដែលខ្ញុំបានទៅទីនោះ ជាមួយនឹងភរិយា របស់ខ្ញុំ...

302 ហើយតើអ្នកណាខ្លះធ្លាប់ស្គាល់លោកចចស្មីត ប្រហែលប្រាំមួយនាទីសម្រាប់លោកស្មីតដែលបាននៅក្នុងទីក្រុងនេះ? លោកចចស្មីត ដែលកូនប្រុសរបស់លោក ជាកងកម្លាំងប៉ូលីសនៅទីនេះ។ លោក ចច ជាជនក្រីក្រម្នាក់ ហើយជាអ្នកញៀន គ្រឿងស្រវឹងម្នាក់ ឥឡូវនេះ។ ប៉ុន្តែគាត់គឺជាម្នាក់ដែលពូកែក្នុងការប្រយុទ្ធបំផុត។ លោកជាមនុស្សម្នាក់ ដែលបានផ្ដល់ការបណ្ដុះបណ្ដាលដល់ខ្ញុំ សម្រាប់ក្លាយជា Y.M.C.A.។ ហើយគ្រប់ទីកន្លែង។ គាត់ប្រើការបណ្ដុះបណ្ដាលជាច្រើនសម្រាប់ យើង។ ហើយគាត់លឿនណាស់ លឿនពិតមែន។ លោកគឺគ្រាន់តែជាមនុស្សម្នាក់ដែលធាត់ គីឡូប្រហែល មួយរយសែសិបប្រាំផោន។ ហើយគាត់បានបណ្ដុះបណ្ដាលដល់ខ្ញុំ។ ហើយដើម្បីឈរនៅទីនោះហើយគាត់បានធ្វើដៃ ដូច*នោះ* ហើយបានវាយពោះនិងលើកខ្ញុំផ្ទប់នឹងជញ្ជាំងហ្នឹងហើយប៉ុន្តែវាមិនអីទេសំរាប់ខ្ញុំ។

គាត់គ្រាន់តែបានបណ្ដុះបណ្ដាលដល់ខ្ញុំវាគ្មានអ្វីនោះទេ ប៉ុន្តែវាគ្រាន់តែជា ការហ្វឹកហាត់។

303 ហើយបន្ទាប់មកខ្ញុំ—ខ្ញុំបានសុបិន្តនៅយប់បន្ទាប់ទៀត ខ្ញុំបានសុបិន្តឃើញ លោកស្មីតប្រហែលប្រាំមួយ—វិនាទី។ ឥឡូវនេះវាមិនមែន ជាការមើលឃើញទេ។ វាជាសុបិន្តមួយ។ ហើយខ្ញុំបានឃើញលោកស្មីតប្រហែលប្រាំមួយ—វិនាទីថា លោកស្មីតជាបុរសវ័យក្មេងចូលមកប្រគួតនឹងគាត់នៅក្នុងការប្រកួតបោកចំបាប់។ ហើយគាត់ជាបុរសម្នាក់ មានអាយុប្រហែល អូ ខ្ញុំគិតថា...ខ្ញុំគិតថាហាសិបពីរ។ គាត់ប្រហែលជាហាសិបប្រាំបីឬហុកសិប។គ្រប់ទាំងសកម្មភាពគ្មានក្មេងស្ទាវណាអាច ប៉ះពាល់គាត់បានទេ។ គាត់គ្រាន់តែចងពួកគេ *ដូច្នោះ* ហើយគាត់ចង់ ឲ្យពួកគេដឹងជា ថាគាត់អាចផ្តួលពួកគេបាន ហើយអាចចាប់ពួកគេ ដោយដៃ របស់គាត់។

304 ហើយខ្ញុំបានគិតថា "នោះជាការចម្លែកណាស់។" ខ្ញុំគិតថាប្រពន្ធរបស់ខ្ញុំនៅជាមួយខ្ញុំ ហើយខ្ញុំបាននិយាយថា "នោះជាការចម្លែកណាស់។" ខ្ញុំនិយាយថា "អ្នកដឹងថាជាអ្វីទេមេដា? គាត់ធ្លាប់ធ្វើជាគ្រូបង្វឹករបស់ខ្ញុំ។"

នាងបាននិយាយថា "ខ្ញុំ—ខ្ញុំចាំថាអ្នកបានប្រាប់រឿងនោះដល់ខ្ញុំហើយ។"

305 ខ្ញុំនិយាយថា "បាទលោក។ ជាមួយនឹងការបណ្ដុះបណ្ដាល ដ៏ល្អរបស់លោក ខ្ញុំបានឈ្នះដប់ប្រាំដងលើអ្នកជំនាញវិជ្ជាជីវៈក្នុង—ក្នុងការប្រយុទ្ធគ្នានិង ការផ្សាយដំណឹងល្អ។"

306 បន្ទាប់មកជាការផ្លាស់ប្តូរ ហើយខ្ញុំបានចាប់ផ្តើមធ្វើដំណើរឆ្លង—ទឹក។ ប៉ុន្តែនៅពេលដែលខ្ញុំទៅ ខ្ញុំបានទៅដោយជិះទូក។ ខ្ញុំបានក្រឡេក មើលទៅទីនោះ ហើយបានឃើញពីរនាក់បងប្អូនអង្គុយនៅទីនោះ ក្នុងទូកកាណូតមួយ ហើយបានត្រៀមខ្លួនជាស្រេចនឹងទៅជាមួយខ្ញុំដែរ។ខ្ញុំបាននិយាយថា "អ្នកមិនអាចធ្វើដូច្នោះបានទេប្អូនប្រុស។អូហូ។ខ្ញុំត្រូវតែទៅតែម្នាក់ឯង។"

307 ហើយអ្នកបើកទូកបានឡើងមក ហើយគាត់បាននិយាយថា "នេះជាទូក" អ្នកជាអ្នកបើកទូកកាណូតប្លាស្ទិចដ៏ជំនាញ។

ខ្ញុំនិយាយថា "នូ។អូហូ។មិនមែនដូច្នោះទេ។"

308 គាត់បាននិយាយថា "មែនហើយ អ្នកអាចធ្វើដំណើរតាមផ្លូវ*នេះ* វាធ្វើដំណើរហាសិបម៉ាយក្នុងមួយម៉ោង។"

ខ្ញុំបាននិយាយថា "ប៉ុន្តែខ្ញុំត្រូវឆ្លងកាត់តាមផ្លូវ *នោះ*។" ឃើញទេ?

"មែនហើយ"គាត់បាននិយាយថា"ចូរគិតពីវាប្អូនប្រុស។"

309 ខ្ញុំបាននិយាយថា "ពួកគេមិនមែនជាអ្នកបើកទូកទេ។ ពួកគេមិនបានដឹងគ្រប់គ្រាន់អំពីការនោះទេ។ ពួកគេចូលចិត្តសប្បាយ។ ពួកគេមិនអាចធ្វើដូច្នោះទេ។ ពួកគេនឹងលិចលង់នៅទីនោះ។ ពួកគេមិនអាចធ្វើវាបានទេ។"

ហើយគាត់បាននិយាយថា"តើអ្នក...អ្នកអាចទុកចិត្តបានទេ...?"

310 ខ្ញុំបាននិយាយថា "សូមស្តាប់សិន ខ្ញុំ—ខ្ញុំដឹង ពីការបើកទូកជាងពួកគេទៀតហើយ ខ្ញុំនឹងមិនព្យាយាមធ្វើវាទេ វាគ្រាន់តែជា សម្ភារៈប៉ុណ្ណោះ។" ខ្ញុំបាននិយាយថា "ខ្ញុំនឹងប្រើកម្លាំងទូក ដើម្បីឆ្លងកាត់ទន្លេនោះ។" ខ្ញុំបាននិយាយថា "ខ្ញុំនឹងស្វែងរកវិធីសាស្ត្រមួយដែលល្អជាងនេះ។"

311 ហើយខ្ញុំបានមើលជុំវិញខ្លួន ហើយក្រលេកមើលប្អូនប្រុសម្នាក់នោះ ហើយខ្ញុំនិយាយថា "តើអ្នកជាអ្នកបើកទូកឬ?"

ប្អូនប្រុសនោះបាននិយាយថា"បាទ។"អ្នកឃើញទេ?

ខ្ញុំបាននិយាយថា"នោះគឺខុសហើយ។"

312 ហើយអ្នកបើកទូកបានត្រឡប់មកវិញ។ លោកបាននិយាយថា "ខ្ញុំចូរប្រាប់អ្នកនូវអ្វីដែលអ្នកធ្វើ។" ខ្ញុំបាននិយាយថា"ពួកគេ ស្រឡាញ់អ្នក។ ពួកគេជឿជាក់លើអ្នក។ ប៉ុន្តែ" ហើយបាននិយាយថា "ប្រសិនបើអ្នកព្យាយាមឆ្លងកាត់ដោយកម្លាំងទូកនោះពួកគេនឹងព្យាយាមធ្វើតាមអ្នកក្នុងទូកកាណូតនោះ។ ពួកគេទាំងពីនឹងស្លាប់ឃើញទេ។" ហើយបាននិយាយថា "ពួកគេមិនអាចធ្វើតាមអ្នកបានទេ។"

ហើយខ្ញុំបាននិយាយថា"ល្អតើខ្ញុំត្រូវធ្វើអ្វី?"

313 ហើយអ្នកបើកបានបើកទូកទៅចតនៅទីនោះគាត់បាននិយាយថា"អ្នកត្រឡប់ ឡើងទៅ*ទីនោះ*ចុះ។" ហើយបាននិយាយថា "វាមានឃ្លាំងតូច មួយតែប៉ុណ្ណោះ ទាំងអស់នៅក្នុងប្រទេសនេះ វាជាឃ្លាំងដ៏តូចមួយ។ ហើយគ្រាន់តែរកប្រាក់បាន តិចតួចក្នុងការផ្គត់ផ្គង់ប៉ុណ្ណោះ" ហើយបាននិយាយថា "ហើយពួកគេនឹងស្នាក់ នៅទីនេះ។ ពួកគេនឹង—ពួកគេនឹងស្នាក់នៅទីនេះខណៈពេលដែលអ្នក

—ខណៈ ពេលដែលអ្នកបានទៅ។ ប៉ុន្តែ"ខ្ញុំបាននិយាយថា"អ្នកត្រូវតែស្វែងរកការផ្គត់ផ្គង់ នោះ។"

314 ហើយខ្ញុំគ្រាន់តែបានបញ្ជាឲ្យគេដកស្លែគ្រប់ប្រភេទ និង ឆែថាវនិងអ្វីគ្រប់ប្រភេទគរនៅទីនោះដូច្នោះ។បន្ទាប់មកខ្ញុំក៏បានភ្ញាក់ឡើង។

315 ខ្ញុំមិនបានដឹងថាវាគឺជាអ្វីទេ ប៉ុន្តែខ្ញុំទើបតែដឹងឥឡូវនេះ។ ឃើញទេយើងកំពុងស្វែងរកការផ្គត់ផ្គង់ណាបងប្អូន។នេះជាជីវិតដែលអ្នកដើរតែម្នាក់ឯង។

316 លោកលីអូអ្នកចាំពីសុបិន្ត ដែលអ្នកបានសុបិន្តនៅពេលដែលអ្នកមកទីនេះ ជាលើកដំបូងទេ? [បងប្រុសលីអូបាននិយាយថា"អាម៉ែន។"—Ed។]អំពីពីរ៉ាមីត ហើយអ្នកគិតថាអ្នកនឹងមកទីនោះ។ ខ្ញុំបាននិយាយថា"លីអូគ្មានមនុស្សណាម្នាក់នៅទីនេះទេ។ព្រះបានដាក់មនុស្សម្នាក់នៅទីនេះ។ អ្នកបានឡើងដោយសាច់ឈាមដែលអាចឡើងបាន។" ខ្ញុំបាននិយាយថា"អ្នកមិន អាចមកទីនេះបានទេលោកលីអូ។ អ្នកឃើញទេ? ចូរវិលត្រឡប់ទៅវិញចុះ។ ហើយ គ្រាន់តែប្រាប់ប្រជាជនថាការនោះបានមកពីព្រះ។"ឃើញទេ? អ្នកឃើញទេ?

317 វាជាអ្វីដែលអ្នក—អ្នករាល់គ្នាមិនអាចពឹងផ្អែកបាន វាមិនល្អដូចជាបងប្អូនប្រុសស្រីនិងក្រុមជំនុំផ្សេងទៀតនិងអ្វីគ្រប់យ៉ាងវាមិនល្អដូចក្រុមជំនុំនិងបងប្អូននៅគ្រប់ទីកន្លែងនោះទេ។

318 ឥឡូវនេះខ្ញុំមិនអាចទុកក្រុមជំនុំនៅឆ្ងាយទីនោះបានទេ។ មានអ្នកខ្លះនិយាយថា "បាទ ហេតុអ្វីបានជាអ្នកចេញទៅជាមួយពួកគេដែលពួកគេជឿព្រះត្រីឯកទាំង*នេះ ទាំងនោះ* ហើយ*ផ្សេងទៀត* និងភាពតែមួយ ហើយព្រះនាមព្រះយេស៊ូវនិងការទាំងអស់នេះគឺនៅទីនោះ? ហេតុអ្វីបានជាអ្នករស់នៅលាយគ្នាជាមួយពួកគេសម្រាប់ធ្វើការទាំងអស់នេះ?" ពួកគេជារបស់ខ្ញុំ។គ្មានបញ្ហាអ្វីទេ ពួកគេបានធ្វើអ្វីពួកគេជារបស់ខ្ញុំ។ពួកគេជាវេទិការបស់ខ្ញុំ។

319 នៅពេលដែលអ៊ីស្រាអែលបានធ្វើអំពើអាក្រក់ដូច្នេះ រហូតដល់ព្រះ បានប្រាប់ដល់លោកម៉ូសេថា "បំបែកខ្លួនអ្នក។ ខ្ញុំនឹងចាប់ផ្ដើមជាថ្មី—កុលសម្ព័ន្ធថ្មីជាមួយអ្នក។"

320 លោកម៉ូសេបានថ្វាយខ្លួនឯងនៅក្នុងការនេះហើយបាននិយាយថា "មុនពេលទ្រង់យកពួកគេសូមយកទូលបង្គំសិន។"

321 មិនខ្វល់ថាពួកគេធ្វើអ្វីនោះទេ នោះជាមនុស្ស ដែលអញបញ្ជូនមក។ ទ្រង់បានបញ្ជូនពន្លឺមក មិនមែនបំភ្លឺនៅកន្លែងដែល ភ្លឺនោះទេ។ គឺបំភ្លឺកន្លែងដែលងងឹតវិញ នោះជាការដែលពន្លឺ នឹងបំភ្លឺទៅ។ ហើយអ្នក នឹងទទួលបានជាមួយប្រជាជនទាំងនោះ។ អ្នកនឹងបានឈរជាមួយពួកគេដោយ មិនបានគិតអ្នកនឹងទទួលកំហុសដូចជាកំហុសរបស់ពួកគេដែរ។

322 អ៊ីស្រាអែលអាចជាអ្នកដែលមានកំហុស។ ពួកគេខុសរហូតទាល់តែព្រះជា ម្ចាស់បោះបង់ពួកគេ។ ប៉ុន្តែលោកម៉ូសេ ខ្ញុំតែងតែឆ្ងល់ពីរបៀបដែលមិនធ្លាប់កើតមាន ប៉ុន្តែព្រះវិញ្ញាណរបស់ព្រះគ្រីស្ទគង់នៅ ក្នុងលោកម៉ូសេ។ អ្នកឃើញទេ?

323 អ្នកឃើញទេយើងខុសទាំងអស់គ្នា។ គាត់បានក្រោកឡើងសម្រាប់យើងទាំងអស់គ្នានៅពេលដែលគាត់ដឹងថាពួកយើងមានកំហុស។

324 មិនខ្វល់ថាពួកគេខុសប៉ុណ្ណានោះទេចូរកុំបោះបង់ការប្រកបគ្នាឬចូលរួមជាមួយគ្នាឡើយ។ ដរាបណាយើងអាចយកឈ្នះ ព្រលឹងវិញ្ញាណ ចូរឲ្យចូលទៅ "ឆ្លាតដូចជាសត្វពស់ហើយសុភាពដូចជាសត្វព្រាប" ឃើញទេហើយព្យាយាមយកឈ្នះព្រលឹងទាំងឡាយតាមដែលយើងអាចធ្វើបាន។

325 ឥឡូវនេះ គឺជាអ្វីដែលខ្ញុំបាននិយាយនៅព្រឹកនេះ ត្រូវរក្សាទុកដូចជា អាហារ។ រក្សាទុកដូចជាម្ហូបអាហារដូច្នេះអ្នកនឹងមានអ្វីដែលត្រូវបរិភោគដូច្នេះអ្នកនឹងមានអ្វី ដែលអាចទទួលទាន។ ទុកវានៅក្នុងការសែតរបស់អ្នក។ ដាក់ក្នុងបន្ទាប់ត្រជាក់មួយ។ ប្រហែលជានៅពេលដែលខ្ញុំទៅណាឆ្ងាយ អ្នកនឹងនៅតែ ចងចាំការទាំងនេះនិងអ្វីដែលជាការពិត។ ទុកវានៅក្នុងរបស់អ្នកហើយស្តាប់។ អ្នកឃើញទេ? ហើយនេះគឺជាអាហារដែលបានរក្សាទុកនៅក្នុងឃ្លាំង។ ខ្ញុំមិនដឹងថាធ្វើដំណើរទៅកន្លែងណាទេ។ ប៉ុន្តែនៅគ្រប់ទីកន្លែងដែលខ្ញុំទៅ ទ្រង់បានដឹងថាកន្លែង នោះជាកន្លែងដែលទ្រង់បាននាំខ្ញុំទៅ ខ្ញុំមិនដឹង។ ខ្ញុំគ្រាន់តែអនុវត្តតាមទ្រង់។

326 ឥឡូវនេះតើអ្វីដែលលោកបាននិយាយនៅទីនេះឥឡូវនេះ? ចូរស្តាប់ដោយយកចិត្តទុកដាក់។

*មួយវិញទៀតបងប្អូនអើយចូរមានកម្លាំងឡើងនៅក្នុងព្រះអម្ចាស់ និង ព្រះ ចេស្តា នៃអំណាចរបស់ទ្រង់ចុះ។*

*...ចូរមានកម្លាំង...ដោយសារព្រះចេស្តារបស់ទ្រង់។*

*ចូរបំពាក់គ្រប់ទាំងគ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអ្នកអាចនឹងឈរប្រឆាំងនឹងកលល្បិច របស់អារក្ស។*

*ដ្បិតយើងមិនតយុទ្ធប្រឆាំងនឹងសាច់ឈាម...*

ការបាញ់គ្រាប់កាំភ្លើង និងមានការកាត់បន្ថយជាមួយការកាប់ចាក់ អ្នកឃើញទេមិនមែនដូច្នោះទេ។

*...ប៉ុន្តែការប្រឆាំងនឹងក្សត្រប្រឆាំងនឹងអំណាចហើយទប់ទល់នឹងមេត្រួតត្រា*

*ទាំងនេះ...ភាពងងឹតនៃលោកិយ៍នេះ...*

327 "អ្នកគ្រប់គ្រងភាពងងឹត។" តើនរណាជាមេគ្រប់គ្រងលោកិយ៍នេះ? អារក្សសាតាំង។ ជាការពិតណាស់។ អ្នកដែលបានគ្រប់គ្រងអ្វីទាំងអស់នៅលើ មនុស្សទុច្ចរិតទាំងអស់នេះ និងមាន រឿងនៅជុំវិញទីនេះ ហើយរដ្ឋាភិបាលនេះជាដើម? វាជាការទាំងអស់របស់អារក្ស។ ព្រះគម្ពីរបានចែងដូច្នេះ។ អារក្សគ្រប់គ្រងលើសហរដ្ឋអាមេរិក។ អារក្សបានគ្រប់គ្រងលើប្រទេសអាល្លឺម៉ង់។ សាតាំងបានគ្រប់គ្រងជាតិសាសន៍ទាំងអស់ នៅក្នុងលោកិយ៍នេះ។ ខ្ញុំនឹងទៅកាន់វានៅប៉ុន្មាននាទីទៀតយើងនឹងទៅកាន់ការនោះឥឡូវដើម្បីដឹងថាពិតឬអត់។ថាតើ...គ្រប់ទាំងអាណាចក្រទាំងអស់ធ្លាប់ និងមិន ធ្លាប់មានវា រហូតដល់ព្រះបានបង្កើតនគររបស់ទ្រង់ឡើងហើយត្រូវបានគ្រប់គ្រងដោយអារក្ស។

328 ខ្ញុំគ្មានន័យថាមនុស្សគ្រប់គ្នាជាវិញ្ញាណអារក្សទេឥឡូវនេះ។ ក៏មានមនុស្សជាច្រើនដែលកោតខ្លាចដល់ព្រះនៅ—ក្នុងជួរមន្ត្រីរដ្ឋាភិបាលដែរ។

329 មាននរណានៅទីនេះនៅក្នុងប៉ុន្មានយប់នេះទីនេះ ដើម្បីបង្ហាញរូបភាពនៅទីនេះជាមួយនឹងបងប្រុសអាហ្កាន់ប្រ៊ីតនៅទីនេះនៅកន្លែងនេះ។ លោកបានទំនាក់ទំនងការទូតជាមួយនឹងគ្រូគង្វាលប្រហែលប្រាំនាក់ផ្សេងទៀតបងប្រុសរ៉ូ។ ហើយគាត់និង...គាត់នឹងនៅទីនេះខ្ញុំគិតថាវាជាសប្តាហ៍ទីពីរនៅក្នុងខែមេសា។ បងប្រុសណេវីល នឹង ប្រកាសពីការនោះ។ ហើយគាត់ជាមនុស្សដ៏អស្ចារ្យ។

330 លោកបាននិយាយថា គាត់អាចនិយាយបានប្រាំបីភាសាខុសៗគ្នាខ្ញុំជឿដូច្នោះ។ ប៉ុន្តែពេលដែលគាត់ ទទួលបានព្រះវិញ្ញាណបរិសុទ្ធ គាត់ មិនមានភាសា

ដែលអាចនិយាយទៅកាន់ព្រះអម្ចាស់បានឡើយដូច្នេះ ព្រះជាម្ចាស់ផ្តល់ឲ្យគាត់មួយភាសារអាចនិយាយបាន ដូច្នេះគាត់និយាយទៅកាន់ទ្រង់ដោយប្រើភាសារនោះ។ ផ្តល់ឲ្យគាត់នូវភាសារមួយដែលគាត់មិនដែលបានរៀន។ហ្នឹងហើយ។

*...ការអាក្រក់ទាំងឡាយដែលស្ថិតនៅស្ថានសួគ៍ដែរ។*

*ហេតុនេះហើយបានជា...*

331 តឡូវទាហានទាំងអស់គ្នាចូរស្តាប់តឡូវនេះមុនពេលយើងចាប់ផ្តើម អធិស្ឋានតាមជួរ។

*...ចូរមកប្រាប់បងប្អូនរបស់អ្នក...(ការ–ទាំង–អស់)ការទាំងមូល(មិនមែន គ្រាន់តែជាផ្នែកមួយ)...គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអ្នកអាចនឹងទប់ទល់ក្នុងថ្ងៃ អាក្រក់បាន...*

នោះហើយជាថ្ងៃដែលយើងកំពុងរស់នៅក្នុងនោះរាល់ថ្ងៃ។

*...និងបានធ្វើការទាំងអស់ដើម្បីរឹងមាំ។*

*ចូរក្រោកឈរ...*

332 អាម៉ែន។ យល់ទេ? អ្នកឃើញទេ ប្អូនស្រី? [បងប្រុសប្រានហាំ បាននិយាយទៅកាន់ប្អូនស្រីដែលឈឺម្តងទៀត—Ed។] នៅពេលដែលអ្នកបានធ្វើការទាំងអស់ដែលអ្នកអាចធ្វើបានដើម្បីរឹងមាំហើយរឹងមាំទៀត។ ដោយមិនផ្លាស់ប្តូរ។

*ក្រោកឈរនិងប្រដាប់ចង្កេះរបស់...*

333 សូមស្តាប់នៅទីនេះ។ សូមស្តាប់នៅទីនេះ នេះគឺជាអ្វីដែលយើងត្រូវស្តាប់។ "ចង្កេះរបស់អ្នក។"នោះហើយជាជាផ្នែកកណ្តាលរបស់អ្នកនៅ*ទីនេះ*អ្នកឃើញទេ។

*...ក្រវាត់សេចក្តីពិត...*

334 សេចក្តីពិតគឺជាអ្វី?
ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ត្រឹមត្រូវណាស់។"ព្រះបន្ទូល គឺជាសេចក្តីពិត។" ត្រឹមត្រូវណាស់។

*...និងនៅទ្រូងគឺសេចក្តីសុចរិតនេះ;*

335 នោះគឺ "តើអ្វីដែលជាការត្រឹមត្រូវហើយ។" សូមទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដាក់នៅក្នុងចិត្តអ្នក ធ្វើការអ្វីដែលជាការត្រឹមត្រូវ។ "ទ្រូងនៃសេចក្តីសុចរិត។"

*ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្ត ទុកជាស្បែកជើង។*

336 ទៅកន្លែងណាក៏ដោយនៅទីណាក៏ដោយនៅពេលណាក៏ដោយស្បែកជើងជាដំណឹងល្អ។ អ្នកឃើញទេ? ហើយមើល:

*ថែមទាំងយកសេចក្តីជំនឿទុកជាខែលផង...*

337 នោះហើយជាការបំបាក់ព្រួញអ្នកឃើញទេ "ខែលនៃសេចក្តីជំនឿ។"

*...ដែលអ្នករាល់គ្នានឹងអាចរំលត់អស់ទាំងព្រួញឆេះរបស់មេកំណាចដោយសារខែលនោះបាន។*

*ចូរយកសេចក្តីសង្រ្គោះទុកជាមួកសឹក*

338 នោះជាព្រលឹង...គំនិត—គំនិតនៅទីនេះ ក្បាល គ្របនៅលើក្បាល។

*...ហើយ—និងដាវរបស់ព្រះវិញ្ញាណដែរគឺជាព្រះបន្ទូល។*

339 តើអ្នកនឹងប្រើមួកនេះដូចម្តេចអ្វីដែលវាបានធ្វើ? វាជាអ្នកការពារ។ មួកធ្វើចេញ ពីអ្វី? លង្ហិន។លង្ហិនមិនអាចវាយចំបែកបានទេវារឹងពិបាកជាងដែកទៅទៀត។ ស្ពាន់(តើជាអ្វី?)សេចក្តីសង្គ្រោះនៃចំណេះដឹង "ហើយការប្រោសឲ្យជារបស់ខ្ញុំ បានមកពីព្រះជាម្ចាស់។ ការសង្គ្រោះរបស់ខ្ញុំបានមកពីព្រះជាម្ចាស់។ ទីបន្ទាល់របស់ខ្ញុំត្រូវនិងព្រះបន្ទូលមិនមែនជាគំនិតរបស់ក្រុមជំនុំទេ គឺព្រះបន្ទូល!" អាម៉ែន។ អ្នកនៅត្រង់នេះ។ បំពាក់ដោយការការពាររបស់មួកនៃសេចក្តីសង្គ្រោះ។ ចូរយកវា បន្ទាប់មកចូលដើរតាមក្បួនទៅមុខ។ អូ ឥឡូវនេះពេលនេះ នេះជាអ្វីដែលយើងត្រូវធ្វើ។កងទ័ពរបស់អារក្សសាតាំង...

340 ឥឡូវនេះចូរមើលឥឡូវនេះយើង...ខ្ញុំត្រូវប្រញាប់បន្តិចប៉ុន្តែខ្ញុំ—ខ្ញុំត្រូវឲ្យអ្នកយល់ដែរ។

341 កងទ័ពរបស់សាតាំង បាននាំជម្ងឺមក។ នោះហើយជាអ្វីដែល សាតាំងបានធ្វើ វាជាអ្នកពិឃាតម្នាក់។នគរទាំងអស់របស់សាតាំងគឺជាជំងឺ ការស្លាប់ ទុក្ខព្រួយ ការវង្វេង និងការព្រួយបារម្ភ ទាំងអស់នេះ គឺនៅជាប់នឹងអារក្សសាតាំង។

ព្រះគឺជាជីវិត ជំនឿ អំណរ សេចក្តីសុខសាន្តនៅ*ទីនេះ*។ អ្នកឃើញទេ?

342 ឥឡូវនេះកងកម្លាំងដ៏ខ្លាំងក្លាពីរបានចូលមកប្រឈមគ្នាឥឡូវនេះ។ ពួកគេកំពុងតែប្រយុទ្ធគ្នា។ពួកគេកំពុងប្រយុទ្ធនៅទីនេះនៅក្នុងអគារនេះឥឡូវនេះ។ ពួកគេបានប្រយុទ្ធគ្នាពីមួយថ្ងៃទៅមួយថ្ងៃរាល់ថ្ងៃ។

343 សាតាំងបានផ្តល់កម្លាំងយ៉ាងខ្លាំងដល់យក្សកូលីយ៉ាត ហើយព្យាយាមដើម្បីបន្លាចអ្នក។វាត្រូវទេប៉ុន្តែព្រះ...

344 អ្នកកំពុងរៀបចំមនុស្សធ្វើសឹក ជាមួយនឹងដំណឹងល្អ ជាមួយនឹងព្រះបន្ទូលនៃសេចក្តីពិតនៅជុំវិញចង្កេះរបស់អ្នក។ ថ្វាយសិរីល្អ! អ្នកអធិប្បាយ នោះហើយជាអ្វីដែលអ្នកត្រូវធ្វើ។ មួកនៃការសង្គ្រោះ ខែលនៃជំនឿ និងដាវគ្រីវ៉ានៅដៃរបស់អ្នក! "សាតាំងខ្ញុំកំពុងមកជួបអ្នក។ អ្នកជួបខ្ញុំនៅក្នុងវិទ្យាសាស្រ្ត។ អ្នកជួបខ្ញុំនៅក្នុង—វប្បធម៌។ អ្នកជួបខ្ញុំក្នុងអង្គការ។ អ្នកជួបខ្ញុំ ក្នុងនាម*នេះ នោះ* ឬ*ផ្សេងទៀត*។ ប៉ុន្តែខ្ញុំបានជួបអ្នកនៅក្នុងព្រះនាមនៃព្រះអម្ចាស់ជាព្រះនៃជនជាតិ អ៊ីស្រាអែល។ ខ្ញុំបានមកតាមក្រោយអ្នក។ ទៅឲ្យឆ្ងាយ!"ទោះបីជាសេចក្តីស្លាប់របស់វា ក៏មិនអាចនៅទីនោះបានដែរ។កាប់រន្ធរូងរកវា។ហ្នឹងហើយ។

345 កងទ័ពរបស់សាតាំងបាននាំមកនូវជម្ងឺ។ ហើយកងទ័ពរបស់ព្រះ បានដេញពួកវាចេញ។ អាម៉ែន។ អ្នកបានធ្វើវា។ រាល់ពេលដែលសាតាំងបានដាក់ អ្វីមួយនៅលើអ្នក កងទ័ពរបស់ព្រះគឺជាអ្នកបណ្តេញវាចេញ។ អាម៉ែន។ ដេញ វាចេញ!

346 នោះហើយជាបច្ចេកទេសយ៉ាងខ្លាំងដែលព្រះបានប្រើ។ សាតាំងបានប្រើកង ទ័ពរបស់វាក្នុងការបំផ្លាញមិនឲ្យជឿ ព្រះបន្ទូលព្រះ ហើយដាក់គាត់ឡើងនៅអាណាចក្រមួយដែលប្រសើជាងមីគែលប៉ុន្តែព្រះបានបណ្តេញវាចេញ។

347 វិធីសាស្រ្តរបស់ព្រះគឺដេញការអាក្រក់ចេញ។ ដេញហេតុផលចេញ។ ដេញអបិយជំនឿចេញ។ ដកនូវការបារម្ភចេញ។ ដកជម្ងឺចេញ។ ដកអំពើបាបចេញ។ អាម៉ែន។ អ្នកនឹងនៅលើវា បានរស់ឡើងវិញនៅក្នុងអង្គព្រះគ្រីស្តយេស៊ូវ ហើយអង្គុយនៅស្ថានសួគ៌ដ៏ខ្ពស់បំផុត ជាមួយនឹងវេលាដែលអារក្សសាតាំង ស្ថិតនៅក្រោមជើងរបស់អ្នក។ប្រសិនបើវាបានចាប់ផ្តើមធ្វើអ្វីនៅទីនោះតើអ្វី...

348 អ្នកដឹងទេ អ្នកគឺស្លាប់ហើយ។ ជីវិតរបស់អ្នកត្រូវបានលាក់ទុក។ តើអ្វីជាការ*ស្លាប់*? អ្នកបានស្លាប់ខាងវិញ្ញាណរបស់អ្នក។ អ្នកបានស្លាប់ ខាងមនៈសិការបស់អ្នក។ ខ្លួនរបស់អ្នកផ្ទាល់នឹងនិយាយថា"បាទខ្ញុំគិតថាខ្ញុំ..."ស្លាប់ចំពោះ ហេតុផល

របស់អ្នក។ អ្នកស្លាប់ក្នុងការទាំងនោះ។ ហើយអ្នកត្រូវបានកប់ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទនិងបានលើកឡើងជាមួយទ្រង់។ហើយគ្រប់ទីកន្លែងដែលទ្រង់គង់នៅអ្នកនឹងនៅទីនោះដែរ។

349 តើមានអ្វីកើតឡើងពេលដែលមាន ម្នាក់ក្នុងចំណោមពួកគេសង្ស័យបានទៅស្ថានសួគ៌? ព្រះទាត់វាចេញ។ ហើយអ្វីដែលទ្រង់មានបន្ទូលទៅកាន់ពួកទាហានដែលបានលើកឡើងក្នុងព្រះគ្រី? "នៅពេលអារក្សមកជាមួយចូរទាត់វាចេញ។ ដេញវាចេញ។" នៅពេលដែលព្រះយេស៊ូវបានហ្វឹកហាត់កងទ័ពរបស់ទ្រង់ហើយបង្គាប់ពួកគេឲ្យទៅចុងបំផុតនៃផែនដី "ចូរនាំគ្នាទៅគ្រប់ទីកន្លែង ក្នុងពិភពលោកហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់។ អ្នកណាជឿហើយទទួល ពិធីជ្រមុជទឹកពីព្រះជាម្ចាស់អ្នកនឹងបានសង្គ្រោះ អ្នកដែលមិនជឿនឹងត្រូវវិនាស។ ហើយទីសម្គាល់ទាំងនេះនឹងនៅជាមួយអស់អ្នកដែលជឿ ទាហានរបស់ខ្ញុំ។ នៅក្នុងឈ្មោះខ្ញុំពួកគេនឹងដេញអារក្ស និយាយភាសាថ្មី អាចកាន់ពស់ឬផឹកអ្វី ដែលស្លាប់នោះនឹងមិនប៉ះពាល់អ្វីដល់ពួកគេទេ! ប្រសិនបើពួកគេដាក់ដៃរបស់ពួកគេលើអ្នកឈឺនោះអ្នកឈឺ នឹងបានជាសះស្បើយឡើងវិញ។"

ចូរទៅមុខពួកគ្រីស្ទាន!
ដូចទាហានចូលច្បាំង
មានឈើឆ្កាង ព្រះយេស៊ូវ
កំពុងដើរទៅមុខ។

350 "ខ្ញុំបានជាប់ឆ្កាងជាមួយនឹងទ្រង់ទោះជាយ៉ាងណាខ្ញុំរស់នៅមិនមែន ខ្ញុំទៀតនោះទេ ប៉ុន្តែទ្រង់បានគង់ក្នុងខ្ញុំវិញ។" ព្រះបន្ទូលកំពុងបន្តមុនពេលព្រះជាម្ចាស់កាត់ចេញដោយដាវមុខពីរដ៏មុតស្រួចរបស់ទ្រង់។

351 បន្ទាប់មក មិនឆ្ងល់ទេថានៅពេលដែលលោកគ្រេន និង វីជម៉ុន និងក្មេងស្រីតូចម្នាក់នៅភាគខាងត្បូងគេបានឃើញលោកគ្រេនមកការបំផុស គំនិតរបស់នាងបានផុសឡើង។ ហើយនាងបាននិយាយថា:

ភ្នែកទូលបង្គំបានឃើញសិរីរុងរឿងនៃការយាងមកនៃ
ព្រះអម្ចាស់;
ទ្រង់បានគង់នៅកន្លែងមួយដែលជាកន្លែងដែលមាន ផ្លែ
ទំពាំងបាយជូរដុះ;

ទ្រង់បានស្រាយទំនាយនោះជាមួយនឹងការគួរឲ្យភ័យខ្លាច
នៃដាវរបស់ទ្រង់;
ទាហានរបស់ទ្រង់គឺត្រូវដើរទៅតាមក្បួន។

352 អាម៉ែន។ លោកគ្រេនបានយករីជម៉ុនមកបានដោយរបៀបណា? គ្រាន់តែគាត់ បានមកដល់ទ្រង់។ អាម៉ែន។ នោះហើយជារបៀបដែលគាត់ បានយករីជម៉ុនមក។

353 នោះជារបៀបដែលពួកទាហានរបស់ព្រះរំដោះពីបាប ពីជងឺ គឺគ្រាន់តែពួកគេមកកាន់វា។ អាម៉ែន។ នោះជាវិធីដែលពួកគេបានយកឈ្នះ លើការសង្ស័យ និងការភ័យខ្លាច និងរឿងជាច្រើនទៀតរបស់ពួកគេ។ ពេលមានវាងើប ឡើងពួកគេកាប់ចេញភ្លាម។ "ផ្លាស់ទីចេញពីទីនោះ!" អូ ខ្ញុំអើយ! ត្រូវហើយ។ ព្រះបានដេញពួកគេចេញដូចដែលទ្រង់បានធ្វើនៅស្ថាន សួគ៌ ដែរ។ មេបញ្ជាការដ៏អស្ចារ្យរបស់យើងបានបង្ហាញយើងពីរបៀបដែលទ្រង់ធ្វើ។អាម៉ែន។

354 លោក រយ រូប៊ឺតសាន់ និងបងប្រុស ហ្វាំង និងមនុស្សជាច្រើន ដែលជាចាស់ទុំនៅទីនេះអ្នកដឹងថាអ្វីដែលជាមេកងពិតប្រាកដទេ។

355 ពេលមួយខ្ញុំ...នាយកដ្ឋានអគ្គីភ័យនៃរដ្ឋជេសហ្វើសាន់វីល។ ជាកន្លែងរបស់លោកភ្វូ(Pfau) មានអគ្គីភ័យកើតឡើង។ ហើយនៅទីនេះគឺជា នាយកដ្ឋានអគ្គីភ័យរបស់រដ្ឋ ជេសហ្វើសាន់វីល ហើយប្រធានក្រុមកំពុងដើរនៅជុំវិញ ហើយបាននិយាយថា"នាំឡានទឹកមក*ទីនេះ*។" "Sp-SP-SP-SP" ដូចជាបំពង់តូចនៅទីនេះ។ នៅទីនេះជារោងចក្រក្លាកវីល(Clarksville)"នាំទឹកមក*នៅទីនេះ*។" "Sp-sp-sp។" អាគាររបស់លោកភ្វូ (Pfau) ត្រូវបានឆេះហើយ។

356 ពួកគេបានហៅល្វីសវីល(Louisville)។ អ្នកបានហ្វឹកហាត់មកហើយ។ អូ ពួកគេបន្លឺសម្លេងស៊ីរ៉ែនយ៉ាងម៉េចនៅទីនោះ!

357 ហើយ នេះគឺជាប្រធានក្រុមដែលមកជាមួយ នៃក្រុមនាយកដ្ឋាន ពន្លត់អគ្គីភ័យ និយាយថា "បាញ់ទឹកនៅត្រង់*នេះ។* បាញ់ទឹកនៅត្រង់*នេះ*។" បុរសដែលមិនទទួលការហ្វឹកហាត់ក៏ធ្វើ។

358 បងប្អូនអើយ នៅពេលដែលម៉ាស៊ីននោះឈប់ តើនរណាដែលនៅលើកាំជណ្ដើរនោះ? គឺជាមេក្រុម។ នៅពេលដែល ជណ្ដើរនោះ លើក ឡើងទៅលើ

គឺគាត់នៅឯខាងលើវា។ នៅពេលដែលគាត់ជាប់គាំងនៅជាមួយនឹងបង្អួចគឺគាត់មិនអាចទៅដល់ឯបង្អួចនោះបានទេ។ គាត់ចាប់កាន់ពូថៅរបស់គាត់និងគប់វា ទៅឯបង្អួចហើយនិយាយថា "មកនេះក្មេង។" ហើយភ្លើងក៏រលត់ក្នុងពេលប៉ុន្មាននាទី។ ប្រធានក្រុម!

359 វាគឺមិន មែនប្រធានក្រុមនិយាយទេ "បាញ់ទឹកត្រង់*នេះ*។ បាញ់បន្ថែមនៅ*ត្រង់នេះ*ទៀត។"

360 ប៉ុន្តែ"មកនេះក្មេងៗ!" អាម៉ែន។ គាត់នាំផ្លូវ។ គាត់បង្ហាញយើងពីរបៀបដែលត្រូវធ្វើវា។

361 ខ្ញុំគិតថា"នាយកដ្ឋានពន្លត់អគ្គីភ័យហ្នឹកហាត់បានល្អណាស់ពួកគេបានពន្លត់ភ្លើងពីរបីនាទី។" ហេតុអ្វី? ព្រោះពួកគេមានប្រធានក្រុមដែលនៅទីនោះដែលដឹងថាត្រូវធ្វើអ្វី។

362 បងប្អូនអើយនិយាយពីទេវសាស្ត្រដែលអ្នកចង់។ មនុស្សដែលបង្កើតនិកាយអង្គភាពរបស់អ្នក: លេងជាមួយវា។

ខ្ញុំមានប្រធានក្រុមម្នាក់ដែលបានប្រាប់ខ្ញុំពីរបៀបដែលត្រូវធ្វើវា។

និយាយថា "មែន បើខ្ញុំធំក្លិនវា គឺមានអារម្មណ៍អំពីវា" អូ គ្មានប្រយោជន៍ទេ!

363 *ទីនេះ* ជារបៀបដែលលោកប្រធានក្រុមបាននិយាយថាវាកើតឡើង នៅក្នុងលូកាជំពូកទី៤។ ខ្ញុំគ្មានពេលវេលានឹងអានវាទេ។ សូមអានដោយខ្លួនឯង។ មិនអីទេ។ នៅក្នុងលូកាជំពូកទីបួនចាប់ផ្តើមជាមួយនឹងខទី១។

364 ទ្រង់ មិនដែលមានបន្ទូលថា "ឥឡូវខ្ញុំនឹងប្រាប់អ្នក។ អ្នកទៅ*ទីនេះ* ហើយអ្នកបង្កើតអង្គភាពដ៏អស្ចារ្យមួយ។ អ្នកមានសភាភិបាល ចាស់ទុំ និង គ្រូធំ គ្រូតូច និងអ្នកមាន*នេះ។*" ទ្រង់មិនដែលមានបន្ទូលដូច្នេះឡើយ។

365 នៅពេល សាតាំងបានជួបទ្រង់ ទ្រង់មានបន្ទូលថា "ឥឡូវអ្នកឃ្លាន។ ចូរ ធ្វើឲ្យដុំថ្មនេះក្លាយជានំប៉័ងទៅ។"

ទ្រង់មានបន្ទូលថា "ដូចមានសេចក្តីចែងមកដូច្នេះ..."

366 វា និយាយថា "ចូរឡើងទៅលើយើងនឹងនាំ អ្នកទៅខាងលើព្រមទាំងបង្ហាញអ្វីជាច្រើនទៀត។"

"ប៉ុន្តែដូចមានចែងមកថា..."

"ខ្ញុំនឹងធ្វើ*នេះ* បើសិនអ្នកធ្វើដូច្នេះ។"

"ដូចមានសេចក្តីចែងមក..."

367 នោះជារបៀប ដែលប្រធានក្រុមនោះបាននិយាយថាទ្រង់បានធ្វើហើយ។ តើទ្រង់ បានធ្វើយ៉ាងម៉េចទៅបងប្អូនស្រីៗ? "បានចែងទុកមកថា 'ប្រសិនបើគេដាក់ដៃលើអ្នកជំងឺ នោះអ្នកជំងឺនឹងបានជា។'" "ដូចមានចែងមកថា 'ដោយនៅក្នុងព្រះនាមខ្ញុំគេនឹងអាចដេញវិញ្ញាណអាក្រក់។'" អាម៉ែន។ តើវាជាអ្វីទៅ? "ដូចមានចែងមក!" នេះជាបញ្ជារបស់ប្រធានក្រុមបានបង្គាប់មក។ "ដូចមានចែងមកថា 'អស់អ្នកដែលបានឮព្រះបន្ទូល និងជឿទៅលើព្រះដែលចាត់ឲ្យខ្ញុំមក នឹងមានជីវិតអស់កល្បជានិច្ច។' ដូច មានចែងមកថា! ដូច មានចែងមកថា! ដូច មានចែងមកថា!" នោះគឺជា— នោះគឺជាសេចក្តីបង្គាប់។ នោះគឺជាទាហាន។ នោះគឺជាផ្លូវ។ នោះគឺជាកាំភ្លើងធំដែលយើងតម្រង់ឡើងទៅលើ។

368 តើគាត់បានធ្វើអ្វី? គាត់បានដើរតម្រង់ទៅឯកូលីយ៉ាត។ គាត់បានបង្ហាញ... តើដាវីឌបានបង្ហាញទៅកាន់ទាហាន ពីរបៀបដែលត្រូវធ្វើយ៉ាងម៉េច? តើដាវីឌបានបង្ហាញទៅកាន់ជនជាតិអ៊ីស្រាអែលពីរបៀបត្រូវធ្វើយ៉ាងម៉េច? *ដាវីឌ* មានន័យថា "ជាទីស្រឡាញ់ ជាអ្នកសង្គ្រោះ ។" ឃើញទេ? តើដាវីឌបានធ្វើវាដោយរបៀបណា? គាត់បាននិយាយថា "នេះជារបៀបដែលវាត្រូវធ្វើ។ ចូរទុកចិត្តលើព្រះបន្ទូលរបស់ព្រះអម្ចាស់។"

369 ហើយកូលីយ៉ាត បានចេញមកខាងក្រៅព្រមទាំងស្រែកថា "ឯងដឹងទេ? អញនឹងចាក់ឯងនិងចុងលំពែងហើយអញនឹងឲ្យឯងទៅជាចំណីសត្វ។"

370 គាត់ និយាយថា "អ្នកជួបខ្ញុំជាអង្គការ។ អ្នកជួបខ្ញុំជាអ្នកវិទ្យាសាស្ត្រទំនើប។ អ្នកជួបខ្ញុំជាមួយនឹងដាវដែលមានប្រវែង ១៥ ហ្វូតដ៏ធំ។ អ្នកជួបខ្ញុំដោយមានមួកការពារធ្វើពីលង្ហិន ជាមួយនឹងខែលដែល ពិបាកទាំងលើកផុតពីដីផង។ អ្នកជួបខ្ញុំជាអ្នកចម្បាំងដែលទទួលការហ្វឹក ហាត់ដ៏ខ្លាំងក្លា។ អ្នកជួបខ្ញុំរៀនចប់ បណ្ឌិត Ph D និង L.L.D និង L.D ជាច្រើន។ អ្នកជួបខ្ញុំជាមួយនឹងចំនេះដឹងទាំងអស់នេះ។ ប៉ុន្តែខ្ញុំមកដោយនៅក្នុង ព្រះនាមព្រះអម្ចាស់ជាព្រះនៃអ៊ីស្រាអែល ថ្ងៃនេះ យើងនឹងកាត់ក្បាលរបស់ឯងចេញពីស្មារ។" អាម៉ែន។ គឺក្មេងប្រុសដ៏តូចនោះ បានចេញមកតទល់ ជាមួយនឹងយក្សមាឌធំនោះ ប៉ុន្តែគាត់ស្គាល់ពី ជំហររបស់គាត់។

អ៊ីស្រាអែល ញ័រនៅខាងក្រោយនោះ "ឱ ក្មេងតូច ដ៏កំសត់ អើយ។"

កូលីយ៉ាត និយាយថា "អញនឹងបង្ហាញឯងពីនរណាដែលអញត្រូវធ្វើ។" ហើយវាក៏ចាប់ផ្តើម។

371 គាត់ មានជំ–នឿឃើញទេនៅក្នុង–ព្រះ–យេ–ស៊ូវថ្ម ៥ដុំ។ ថ្មតូចមួយនៅទីនោះ អូចាប់ផ្តើមវា។ គ្រវីវាដូចច្នេះព្រះវិញ្ញាណបរិសុទ្ធ គឺនៅជាមួយថ្មនោះ ហើយក៏គប់ទៅ។ កូលីយ៉ាតក៏ដួលចុះលើដី។ នោះ គឺជារឿងដែលបានកើតឡើង។

372 នោះគឺជារបៀបដែលព្រះយេស៊ូវមានបន្ទូលតើទ្រង់បាននិយាយអ្វី។ "ឥឡូវបងប្អូនដែលធ្វើព័ន្ធកិច្ចប្រសិនបើអ្នកចង់ដឹងពីរបៀប ដែលយកឈ្នះ លើវិញ្ញាណអាក្រក់ខ្ញុំនឹងបង្ហាញវាពីរបៀបដែលត្រូវធ្វើ។"

373 សាតាំងនិយាយ "ខ្ញុំនឹងជួបអ្នក។" កូលីយ៉ាត "អញនឹងបង្ហាញឯងពីអ្វីដែលអញអាចធ្វើបាន។ ឯងឃ្លានហើយ។ ប្រសិនបើឯងជាព្រះបុត្រារបស់ព្រះ អញនឹងប្រកួត ជាមួយឯង។ អ្នកនិយាយថាអ្នកជាបុត្រារបស់ព្រះ។ ខ្ញុំនឹងប្រកួតជាមួយអ្នក។ ប្រសិនបើអ្នកជាព្រះបុត្រារបស់ព្រះជាម្ចាស់ ចូរធ្វើឲ្យដុំថ្មនេះក្លាយជានំប៉័ងទៅ។ ចូរញុាំ អ្នកឃ្លានហើយ។ ហើយប្រសិនបើអ្នកជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន អ្នកមានអំណាច ក្នុងការធ្វើវា។"

374 ទ្រង់មានបន្ទូលថា "ប៉ុន្តែមានសេចក្តីចែងទុកមក ឥឡូវនេះ 'មនុស្សមិនរស់ដោយសារតែនំប៉័ងប៉ុណ្ណោះទេ។'" នេះគឺជារបៀប ដែលប្រធានក្រុមធ្វើវាយ៉ាងដូច្នេះ។

យកគាត់ ឡើងទៅលើកំពូលនៃព្រះវិហារ វានិយាយថា "បើសិន អ្នកលោតចុះពីលើ" និយាយ "អ្នកដឹងទេដូចមានចែងមកដូច្នេះ..."

375 គាត់និយាយថា "បាទ។" បន្ថែមថា "ដូចមានចែងម្តងទៀត 'មិនត្រូវល្បងលព្រះអម្ចាស់ជាព្រះនៃឯងឡើយ។'" ឃើញទេ តើទ្រង់ហៅអង្គទ្រង់ថាយ៉ាងម៉េច? "ព្រះអម្ចាស់ដ៏ជាព្រះ។" អឺ–អឺ។ "'មិនត្រូវល្បងលព្រះអម្ចាស់ជាព្រះនៃឯងឡើយ' គឺមានចែងយ៉ាងដូច្នេះម្តងទៀត គឺដូច្នេះ។"ឃើញទេ? អូ ខ្ញុំអើយ!

376 តើទ្រង់បានធ្វើអ្វី? ទ្រង់បានយកឈ្នះលើវាជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យុទ្ធសាស្ត្ររបស់អារក្សគឺធ្វើឲ្យយើងមិនជឿព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ហើយប្រធានក្រុមនិយាយថា"ចូរកាន់តាម ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងធ្វើតាម។ ក្នុងនាមរបស់ខ្ញុំអ្នកអាចដេញ អារក្សបាន។"

377 អូ សាតាំង ប្រធានក្រុមរបស់ពួកវាអូ មែនហើយអ្នកដឹងទេនិកាយទាំងនេះព្យាយាមទាញអ្នកដូចក្រចកសេះអ្នក ដឹងទេជាមួយនឹងកន្ទុយនិងប្រភេទស្រដៀងគ្នានេះ។ តើអ្នកមិនជឿទេឬ។ គេមិនតាមរបៀប នោះទេ។ ទេ បងប្អូន។ គេរអិលហើយ។ តើអ្នកមិនដឹងទេឬថាវាមានដូច្នេះ? គេធ្វើដូច្នេះដើម្បីបន្លាចអ្នកឲ្យចេញទៅឆ្ងាយ។ នោះមិនមែនជា អារក្សទេ។ អារក្សគ្មានក្រចកទេ ចាប់ផ្តើមជាមួយវា ខ្ញុំ សង្ស័យវាខ្លាំងណាស់។ វាគ្រាន់តែវិញ្ញាណមួយតែប៉ុណ្ណោះ។ អារក្សគឺជាវិញ្ញាណអាក្រក់។វាគ្មានក្រចកនិងអ្វីផ្សេងទៀតទេដូចជាអ្វីដែលអ្នកស្រមៃនោះទេ។ ទេ ទេ។

378 ប៉ុន្តែគេឆ្លាត។ បងប្អូនអើយគេជាមនុស្សដែលឆ្លាតទទួលការអប់រំខ្ពស់គឺតែងតែ មានប្រាជ្ញាខាងលោកិយ៍ជ្រៅជ្រះ។ អូបាទ។ វាស្អាត។ រៀបចំទ័ពរបស់វាដោយប្រាជ្ញាលោកិយ៍រហូតដល់ បងប្អូន តើអ្នកមិន ព្យាយាម—និយាយពាក្យពេជន៍របស់អ្នកទេឬ។ អ្នកគួរតែដឹងពីអ្វីដែលអ្នកកំពុងនិយាយ នៅពេលដែលអ្នកជួបមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនេះនិយាយថា "ថ្ងៃនៃការអស្ចារ្យបានកន្លងផុតទៅហើយ។" ទេ គេមិន—គឺគេមិនមានគោលដៅច្បាស់លាស់ទេ។ គេ អូ គេ—គេ—គេរៀនវគ្គជាន់ខ្ពស់។ បងប្អូនខ្ញុំមានន័យថា គេឆ្លាត Ph.D., L.L.D., Q.U.S.T., និង ជាច្រើនទៀត។ ឃើញទេ? អ្វីទាំងអស់គឺនៅទីនោះ គឺគេឆ្លាតតាមកាលដែលគេអាចធ្វើបាន។ ឆ្លាតប្រាកដណាស់គេគឺជាពស់គឺខាំគេទាំងអស់គ្នា។ សក់វែងចុះក្រោមបងប្អូនខ្ញុំចង់មានន័យ ទៅលើសម្លៀកបំពាក់ និងមិនមានស្នាមជ្រួញនៅលើ អាវ។ ឆ្លាត គឺឆ្លាត និងវាសរវៃតាមការដែល គេអាចធ្វើទៅបាន។ ពិតមែនហើយ។

379 អ្នកមិនវង្វេងជាមួយគេឡើយ កាលណាដែល អ្នកយល់នូវអ្វីដែលអ្នកកំពុងនិយាយ។ ហ្នឹងហើយ។ អូ ប៉ុន្តែ យើងស្គាល់ពីតិចនិចចាស់—ចាស់របស់គេ។ យើងស្គាល់ពីអ្វីដែលវាកំពុងព្យាយាមធ្វើៈ គឺនាំយើង មិនឲ្យជឿព្រះបន្ទូលព្រះ។

380 ហើយគេមិនគោលដៅត្រឹមត្រូវទេ។ អត់ទេ ទេ ទេ។ ឥឡូវយើងរក ឃើញថាប្រសិនបើគេមិនមានគោលដៅច្បាស់ទេ ចឹងគេត្រូវមានអ្វីផ្សេងទៀត។ គេគឺជាអ្នកបញ្ឆោត។ គេមានប្រាជ្ញា ទទួលការអប់រំ ចេះរៀបចំ។ បងប្អូនគឺគេមានទ័ពជាច្រើន។

381 សូមមើលនៅពេលមួយនៅឯប្រទេសស្វីស។ ខ្ញុំមិនអាចរកកន្លែង ដើម្បីបញ្ចប់ជាមួយនឹងមនុស្សទាំងអស់នេះបានទេ។ មាន—មាន...នៅប្រទេសស្វីស មានទាហានអាឡឺម៉ង់ជាក្បួន–...ជាមួយនឹងសម្ព័ន្ធមិត្តដែលចូលមក។ ហេតុអ្វី វាមើលទៅហាក់ដូចជាជញ្ជាំងតដ្ឋដែល គ្រប់គ្នាទទួលការហ្វឹកហាត់ គ្រប់ទាំងលំពែងបានកំណត់*ដូចនេះ*គឺប្រាំបីឬដប់ហ្វីតនៅខាងមុខ។ ហើយគេបានមកខាងលើជាមួយជនជាតិស្វីសដែលនៅខាង នោះ តើពួកគេមានអ្វី? ពួកគេគឺជាទាហាន ជាមួយ—ជាមួយដាវចេញពីស្រោមជាប់នឹងរឹងមាំហើយគេឈរនៅទីនោះ។គេអាចបណ្ដេញពួកគេ ទៅទីនោះ។ នៅខាងស្ដាំភ្នំគឺជាផ្ទះរបស់គេ។ ហើយកងទ័ពស្វីសបានចេញមកជួបពួកគេ។ ពួកគេមិនបានធ្វើអ្វីទៅកាន់អ្នកទាំងនោះទេ។ ពួកគេគ្រាន់តែមកយកដីគេតែប៉ុណ្ណោះ។

382 តើ ក្មេងនេះបានធ្វើអ្វីទៅកាន់ពិភពលោកនេះ គ្រាន់តែជាក្មេងម្នាក់សោះ? សាតាំង ដែលជាអ្នក អាចយកជីវិតគេបាន បើសិនជាវាអាច។ ប្រាកដណាស់ គឺវានៅទីនោះមិនការកំណត់។ ឃើញទេ?

383 ពួកស្វីសនេះមិនបានធ្វើអ្វីទេ។ ពួកគេជាមនុស្សល្អ។ ពួកគេគ្រាន់តែព្យាយាមការពារផ្ទះរបស់គេតែប៉ុណ្ណោះប៉ុន្តែគេឈរនៅខាងក្រៅនោះដើម្បី ការពារ។ បន្ទាប់មកទៀតមានមនុស្សម្នាក់ឈ្មោះអាណុល វុន វីកឃីរីឌ។ កងទ័ពនេះបានមក។ ពួកគេនៅជុំវិញ។ ទាំងនិយាយថា "តើយើងអាចធ្វើអ្វីបាន?"

384 នៅគ្រប់ទីកន្លែង ដូចជាសមុទ្រមនុស្ស ដែលហ្វឹកហាត់បានល្អ។ ជារបៀបដែលសាតាំងធ្វើ។ការហ្វឹកហាត់ល្អ លំពែងរបស់គេបានចង្អុលទៅក្រៅ ម្នាក់ៗដើរបោះជំហាន មួយ ពីរ មួយ ពីរ រុញច្រានទៅកាន់កងទ័ពដ៏តិចតួចម្ខាងទៀត។ គ្រាន់តែ—គ្រាន់តែបន្តរដើរ នោះជាអ្វី ដែលពួកគេត្រូវធ្វើ និងចាក់ពួកគេដោយដាវ។ លំពែងបានចាក់ទម្លុះពួកគេ។ ដែលនោះអាចបញ្ចប់កងទ័ពស្វីសបាន។ គឺត្រូវបានបញ្ចប់ទាំងអស់។នៅលើភ្នំនោះគឺជាផ្ទះនិងមនុស្សជាទីស្រឡាញ់របស់ពួកគេ។ ស្ត្រីជាច្រើនត្រូវបានចាប់ពង្រត់និងរំលោភ ក្មេងស្រីៗ និង ក្មេងប្រុសៗជាច្រើនត្រូវបានសម្លាប់ ហើយផ្ទះត្រូវបានដុតបំផ្លាញ ជាមួយនឹងអ្វីផ្សេងៗជាច្រើនទៀតអាហារ សត្វចិញ្ចឹមនិងរបស់អ្វីៗត្រូវបាត់បង់អស់។ នេះជាអ្វីដែលពួកគេបានបាត់បង់។

385 តើមានអ្វីបានកើតឡើង? មានម្នាក់ឈ្មោះ អា ណុលរ៉ុន វីនខឺរីតជាអ្នកដែលជំរុញចិត្ត។ គាត់បាននិយាយថា "បងប្អូននៃជនជាតិស្វីសទាំងអស់ ថ្ងៃនេះខ្ញុំស្លាប់ដើម្បីទឹកដីស្វីសហើយ។"

ពួកគេបាននិយាយថា "តើអ្នកនឹងធ្វើអ្វី?"

386 គាត់និយាយថា "អ្នកគ្រាន់តែតាមខ្ញុំ ហើយប្រយុទ្ធជាមួយអ្វីដែលអ្នក មាន។" គាត់បានឈរនៅខាងលើទីនោះគប់លំពែងរបស់គាត់គឺឈើតូចមួយនៅក្នុងដៃរបស់គាត់*ដូចនោះ។* ហើយស្រែក ដោយលើកដៃឡើងទៅលើ *ដូចនោះ* ហើយរត់សំដៅទៅទីនោះ និងស្រែកខ្លាំងៗថា "យើងត្រូវការសេរីភាព!" រត់ គឺប្រឹងរត់តាមដែលអាចធ្វើទៅបាន ទៅឯទាហាន។ ហើយនៅពេលដែលគាត់ស្លាប់ គាត់បានចាប់កាន់លំពែងហើយបុកមកដើមទ្រូងគាត់*ដូចនោះ* ហើយគាត់ក៏ស្លាប់ទៅ។

387 គាត់បានប្រាប់គេថាគាត់នឹងចាកចេញទៅ។ និយាយថា "មានផ្ទះតូចមួយនៅត្រើយខាងនោះប្រពន្ធនិងកូនៗ ដែលខ្ញុំបានចាកចេញទៅ ផ្ទះតូចមួយដែលខ្ញុំបានទិញ។" ហើយនិយាយថា "ខ្ញុំ—ខ្ញុំស្រឡាញ់ពួកគេប៉ុន្តែថ្ងៃនេះ ខ្ញុំបានស្លាប់សម្រាប់ប្រជាជនស្វីស។ គាត់ឲ្យខ្ញុំ..."គាត់និយាយថា "ខ្ញុំលះបង់ជីវិត ខ្ញុំដើម្បីសង្គ្រោះប្រជាជាតិ។" ហើយនោះគឺជា វីរៈបុរស។ ក្រោយមកក៏លែងមានសង្គ្រាមតាំងពីពេលនោះមក។ នោះ ក៏មកដល់ទីបញ្ចប់។

388 វា ជាគំនិតប្រាប់ទៅទ័ពទាំងនោះ ថាវិរៈបុរសត្រូវបានបង្ហាញឡើង រហូតដល់មិនមាន...ទាហាន—ទាហានស្រឡាំងកាំង។ ពួកស្វីស បានរមៀលដុំថ្មដាក់លើពួកគេ និងដេញគេចេញពីប្រទេសនោះ ហើយគេមិនដែលត្រឡប់មកវិញឡើយ។ នេះគឺជារឿងដែលកើតឡើងរាប់រយឆ្នាំមុន។ ឃើញទេ? ហេតុអ្វីៗ នេះគឺ ជា រឿងរ៉ាវដ៏អស្ចារ្យ។

389 ប៉ុន្តែ អូ បងប្អូនអើយ នៅថ្ងៃមួយ នៅពេលដែលមានភាពអវិជ្ជា ការមិនយល់ដឹងការសង្ស័យការ វង្វេងនិង សេចក្តីភ័យខ្លាចហើយប្រជារាស្ត្ររបស់ព្រះបានត្រឡប់មករកព្រះ។ គឺមានព្រះនាមមួយអង្គគឺព្រះយេស៊ូវគ្រីស្ទ "នៅថ្ងៃនេះខ្ញុំបានស្លាប់ សម្រាប់មនុស្សជាច្រើន។" ត្រូវហើយ។

390 តើ គាត់បាននិយាយអ្វីទៅកាន់កងទ័ពរបស់គាត់? "ចូរតាមខ្ញុំ នឹងប្រយុទ្ធជាមួយអ្វីដែលអ្នកមាន។ ប្រសិនបើអ្នកមានព្រនង់មួយ ចូរវាយនឹងប្រនង់នោះ។ ចូរកុំ ភ័យខ្លាចឡើយ។ អ្នកមានដំបងចូរវាយជាមួយដំបងនោះ។ អ្នកមានដុំថ្ម ចូរវាយ ជាមួយនឹងដុំថ្មនោះ គឺជាមួយអ្វីដែលអ្នកមាន។"

391 នេះជាអ្វីដែលប្រធានក្រុមរបស់ យើងនិយាយនៅថ្ងៃនេះ។ "ខ្ញុំបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយបានយកឈ្នះវិញ្ញាណអាក្រក់ និងអំណាចរបស់វា។" គាត់បានចិញ្ច្រាំវាទៅជាចំរៀកៗ អាម៉ែន គឺដោយ ព្រះបន្ទូល។ ឥឡូវអ្វីដែលអ្នកមាន ប្រសិនបើអ្នកគ្រាន់តែមានតែព្រះបន្ទូល តែមួយប៉ុណ្ណោះ "គឺព្រះអម្ចាស់ដែលជាអ្នកប្រោសដល់គាត់" ចិញ្ច្រាំវា។ ដើរតាម។ អាម៉ែន។ តាមប្រធានក្រុមរបស់យើង។ ហ្នឹងហើយ។ គឺគាត់បាន ចិញ្ច្រាំវា។

392 សាតាំងជាមួយនឹងនគរដ៏ធំស្អាត និងអ្វីដែលស្អាត និងជាច្រើនទៀត គឺចេញមកថ្មីៗ។ គឺមិនមានអ្វីដែលទាក់ទងជាមួយយើងទេ។ ត្រូវហើយ។ វាគឺនៅតែជាសត្វល្បិចច្រើននៅឯវាលក្នុងចំណោមសត្វនានា។ ហ្នឹងហើយ។ ព្រះយេស៊ូវមានព្រះបន្ទូលថា កូនៗនៅលើផែនដីនេះឆ្លាតជាងកូនៗដែលនៅក្នុងនគរព្រះ។

393 ឥឡូវ នេះជាភាពប្រឆាំងធំពីរ។ យើងនឹង…ខ្ញុំត្រូវ…ត្រូវបញ្ចប់វា។ការប្រឆាំងពីរធំៗបានមកដល់ហើយឥឡូវ។ ឥឡូវ ជាពេលវេលាដែលជំងឺនិងអ្វីផ្សេងទៀតបានវាយចូលក្នុងពិភពលោក រហូតដល់វិទ្យាសាស្ត្រនៃការព្យាបាលបានជាប់គាំង និងគ្រប់យ៉ាងគឺទាល់ផ្លូវ។ មិនមានជាអ្វីឡើយ ហើយ—ហើយយើងគ្រាន់តែ…ហើយកងទ័ព ទ័ពតូចមួយរបស់ព្រះ នឹងត្រឡប់មកជ្រុងវិញ និងអ្វីគ្រប់យ៉ាង។ បងប្អូនអើយវាជាពេល អាណុលវីងឃីរីម្នាក់ទៀត។ វាជាពេលសម្រាប់មនុស្សរបស់ព្រះម្នាក់ទៀតងើបឡើង។ វាជាពេលរបស់អេលីយ៉ាលេចឡើង។ វាជាពេលដែលអ្វីមួយកើតឡើង។

394 ទ័ពរបស់ព្រះ បិទគំនិតរបស់អ្នក។ កុំឈប់មួយនាទីណាឡើយ ដើម្បីគិតពីអ្វីដែលអារក្ខដែលវាបានផ្តល់ឲ្យមកវិញ្ញាណឥន្ទ្រីយរបស់អ្នក។ ប៉ុន្តែសូមចងចាំព្រះបន្ទូលរបស់ព្រះមិនបរាជ័យឡើយ។

395 ទ័ពធំទាំងពីរនេះ! នៅពេលដែលសត្រូវមកដូចជាទឹកជំនន់ដូចសព្វថ្ងៃនេះ តើព្រះមានបន្ទូលថាទ្រង់នឹងធ្វើអ្វី? "វិញ្ញាណនៃព្រះនឹងងើបឡើងហើយទាស់នឹងវា។" តើអ្នកជាម្នាក់ក្នុងចំណោមពួកគេឬ? ហ្នឹងហើយ។

396 យើងត្រូវបានបង្រៀននៅក្នុងគម្ពីរយ៉ាកុប4:7...ខ្ញុំមិនមានពេលអានឡើយ។ យ៉ាកុប4:7 "តស៊ូជាមួយអារក្ខ និង" វាមិនដើរចេញពីអ្នកទេ តែ "វាគេចចេញ។" "តស៊ូនិងអារក្ខ។" តើអ្នកតស៊ូនិងអារក្ខយ៉ាងម៉េច? ដូចគ្នាទៅហ្នឹងមេបញ្ជារការបង្គាប់ដែរ។ យកព្រះបន្ទូលព្រះ។ នោះជារបៀបប្រឆាំងនឹងអារក្ខ គឺដោយព្រះបន្ទូលរបស់ព្រះ។ លោកមេបញ្ជាការបង្គាប់យើងបែបនេះ។ ត្រូវហើយ។

397 ឥឡូវក្នុងការបញ្ចប់ ខ្ញុំចង់និយាយបែបនេះ។ អារក្ខចាស់នោះ អ្នកគិតថាវាមិនមានអៀនខ្មាស។ អ្នកគិតថាតើវាវាយក្មេងៗទេ? វានឹងវាយប្រហាទាំងអស់។ វាវាយប្រហាព្រះយេស៊ូវគ្រីស្ទ។ វាមកឯទ្រង់ជាមួយការវាយលុកបីយ៉ាងកម្រោល។ តើអ្នកដឹងរឿងនោះទេ? សាតាំងមិនមែនវាយលុកតែម្តងទេ។ វាវាយលុកអ្នកជាមួយជំងឺ រួចត្រង់នេះ វាវាយនឹងត្រឡប់មកវិញដើម្បីវាយប្រហារអ្នក ប្រាប់អ្នកថា "ថ្ងៃនៃការអស្ចារ្យបានកន្លងផុតហើយ។ អ្នកនឹងមិនជាឡើយ។ គ្មានអ្វីប៉ះពាល់ទាំងអស់។" អ្នកដឹងច្បាស់ហើយមែនទេ។

398 វាវាយប្រហារព្រះយេស៊ូបីដង។ វាយប្រហារយ៉ាងកម្រោល វារត់មកព្រះយេស៊ូវ ជាមួយការមិនជឿរបស់វាលើព្រះបន្ទូលរបស់ព្រះ។ ព្រះយេស៊ូវជាព្រះបន្ទូល។ ប្រាកដណាស់វាមិនជឿឡើយ។ "ប្រសិនបើ...ប្រសិនបើអ្នក..." ត្រង់នេះវាយប្រហារយ៉ាងកម្រោល ដូចអ្វីដែលខ្មាំងសត្រូវបានធ្វើសព្វថ្ងៃ។ ត្រង់នេះវាមកនិយាយថា "ប្រសិនបើអ្នកជាបុត្រារបស់ព្រះចូរបង្ហាញខ្ញុំនូវការអស្ចារ្យ។ ចូរឲ្យខ្ញុំបានឃើញថាសម្រេចជាយ៉ាងណា" បងប្អូនអើយការវាយប្រហាយ៉ាងកំពោលបីដែលវាបានបញ្ចូល "ប្រសិនបើ...ប្រសិនបើ...។"

399 ឥឡូវ តើព្រះយេស៊ូវជាអ្វី? ជាព្រះបន្ទូលរបស់ព្រះ។ ទ្រង់ជាព្រះបន្ទូល។ វាវាយប្រហារព្រះបន្ទូល។ សិរីរុងរឿង! ខ្ញុំ—ខ្ញុំមាន...មានអារម្មណ៍ថាល្អដែលអធិប្បាយឥឡូវ ខ្ញុំធ្វើដោយស្មោះត្រង់។ ត្រូវហើយ។ ព្រះយេស៊ូវជាព្រះបន្ទូល "កាលដើមដំបូងមានព្រះបន្ទូលហើយព្រះបន្ទូលគង់នៅជាមួយព្រះហើយព្រះបន្ទូលនោះឯងជាព្រះ ព្រះបន្ទូលគង់នៅ ក្លាយជាសាច់ឈាម គង់នៅ..."ព្រះយេស៊ូវជាព្រះបន្ទូល។ តើទ្រង់បានធ្វើអ្វី? ទ្រង់កាត់ឆ្អឹងជំនីទ្រង់។ អូ ខ្ញុំអើយ! ខ្ញុំចង់ឈប់។ តើព្រះយេស៊ូវបានធ្វើអ្វី? ទ្រង់ជាព្រះបន្ទូល។ ដូច្នេះដោយព្រះបន្ទូលទ្រង់បានកាប់សាតាំងទៅលើការវាយប្រហាររបស់វា។ វាហោះមកទីនោះដូចជាបាច់នៃព្យុះទាហាន ឬជាអ្វីស្រដៀងនោះ ហោះចូលមកព្រះយេស៊ូវជាព្រះបន្ទូលដោយបែប

នោះ។ ហើយព្រះយេស៊ូវយកព្រះ បន្ទូលទ្រង់ហើយកាត់វាជាចម្រៀកៗ។ ហាលេលូយ៉ាៗ! ពិតណាស់ កាត់វាជាចម្រៀកៗ យកឈ្នះវាដោយព្រះបន្ទូល។

400 មើលការវាយប្រហាររបស់វា? មើល ស្តាប់ឲ្យជិត ការបញ្ចប់នេះ។ ការវាយប្រហាររបស់វាគឺអ្វី? មិនជឿព្រះបន្ទូលព្រះនោះហើយជាការវាយប្រហា។ ទីនោះតើ អ្នកឃើញសមរភូមិធំបំផុតដែលមិនធ្លាប់ជួបទេ? មានកងកម្លាំងតែពីរគត់ គឺសាតាំងនិងព្រះ។ តើអ្វីទៅជាអាវុធរបស់សាតាំងប្រឆាំងនឹងអ្នក? គឺព្យាយាមមិនឲ្យជឿលើអាវុធរបស់អ្នក។ វាដកយកអាវុធអ្នក។ ចូរ—ចូរស្តាប់ដោយស្ងាត់ស្ងៀមឥឡូវ។ សូមស្តាប់។ បើសិនជាវាអាចធ្វើឲ្យអ្នកមិនជឿលើអាវុធរបស់អ្នកគឺដូចជាគ្នា នឹងថាវាបានធ្វើឲ្យអ្នកជឿថាអាវុធរបស់អ្នកមិនខ្លាំងពូកែ គ្រប់គ្រាន់នោះមានន័យថាវាបានធ្វើឲ្យអ្នកធ្លាក់អាវុធហើយ។

401 អូ បងប្អូនប្រុសនេវីល(Neville)យើងសង្ឃឹមថាយើងមិនចាកចេញពីចំណុចនោះ។[បងប្អូនប្រុសនេវីលនិយាយ "ខ្ញុំសង្ឃឹមនិងមិនភ្លេចអធិស្ថាន"—Ed។]

402 មើល។ វាទម្លាក់អាវុធអ្នកចុះ ពេលវាធ្វើឲ្យអ្នកមិនជឿអាវុធនោះ។ ពេលអ្នកទម្លាក់ចុះ នោះចម្បាំងរបស់អ្នកគឺចប់ហើយ។ អ្នកគឺចប់ហើយ។ កាន់អាវុធរបស់អ្នក។ កុំទម្លាក់វាចុះ។ យើងឃើញការមិនជឿរបស់វា។ ចូរ...

មួយវិញទៀតខ្ញុំចង់និយាយឥឡូវប្រហែលមួយនាទី។

403 រុស្ស៊ី ខ្ញុំចង់និយាយរឿងនេះសម្រាប់ជាប្រយោជន៍ទាហានជើងចាស់ និងអ្វីបន្តទៀត ត្រង់នេះហើយអ្នក សិស្សសាលាព្រះគម្ពីរ។ តើអ្នកជម្រុញអង្រួននិងស្រែកបង្កូកហៅរុស្ស៊ី? ហិម! តើអ្នកមិនឮខ្ញុំឲ្យអ្នកសង់ជម្រកគ្រាប់បែកទេ មិនចឹងទេ? តើអ្វីដែលអ្នកជម្រុញរុស្ស៊ី? រុស្ស៊ីមិនជាអ្វីនោះទេ។ កុម្មុយនិស្តមិនឈ្នះ ពិភពលោកឡើយ។ អ្វីជាបញ្ហាជាមួយមនុស្ស។

404 ស្តាប់ នេះជាអ្វីតាមខ្សែអាត់ឥឡូវ។ ចំពោះពិភពលោកខ្ញុំនិយាយ និងគ្រប់កន្លែងដែលខ្សែអាត់នេះទៅដល់។ ហើយចំពោះមនុស្សដែលនៅទីនេះ មិនថាអ្វីកើតឡើងចំពោះខ្ញុំ អ្នកជឿការនេះចុះ។

405 រុស្ស៊ីជាកុំម្មុយនិស្តមិនអាចឈ្នះអ្វីឡើយ ហើយ។ ព្រះបន្ទូលរបស់ព្រះក៏មិនបរាជ័យដែរ។ រ៉ូម៉ាំងនិយមនឹងគ្រប់គ្រងពិភពលោក។

406 ចូរពិនិត្យនិមិត្តរបស់ដានីយ៉ែល។ នោះជាព្រះបន្ទូលរបស់ព្រះ។ "អ្នក អូ ដានីយ៉ែលអើយ..." "អ្នកអូ ស្តេចនេប៊ូក្នេសាជាក្បាលជាមាស" បាប៊ីឡូន "អាណាចក្រផ្សេងទៀតនឹងបន្តពីអ្នកដែលជាប្រាក់" មើលគឺជា មេ-ដូ-ភើសៀ។ មួយទៀតជាក្រិក អាឡិចសាន់ដឺដឺក្រេត។ បន្ទាប់មកចូលដល់រ៉ូម។ ហើយមិនមានជាអ្វីដែល និយាយពីកុំម្មុយនិស្តឡើយ។ រ៉ូមបានឈ្នះពិភពលោក។

407 ព្រះយេស៊ូវបានប្រសូត្រនៅសម័យអាណាចក្ររ៉ូម៉ាំង និងត្រូវបានបៀតបៀនការយាងមកផែនដីលើកទីមួយរបស់ទ្រង់ គឺដោយអាណាចក្ររបស់រ៉ូម៉ាំង។ ហើយមុនការយាងមកជាលើកទីពីរកំពុងតែមកឥឡូវ សាររបស់ទ្រង់ត្រូវបានរងការបៀតបៀនដោយនិកាយរបស់រ៉ូម៉ាំង ដែលជាម្តាយរបស់និកាយទាំងអស់នោះ។ ហើយពេលទ្រង់ត្រឡប់មកវិញ ទ្រង់នឹងយាងមកលុបចេញអាណាចក្ររ៉ូម៉ាំងដែលជន ជាតិយូដាតែងសម្លឹងទ្រង់ថានឹងមកលុបបំបាត់អាណាចក្ររ៉ូម។

408 ប្រព័ន្ធកាតូលិក ជាមួយនឹងនិកាយទាំងអស់នៅក្នុងពិភពលោក ឥឡូវបានប្រមូលគ្នាជាអង្គការ សហព័ន្ធនៃក្រុមជំនុំបង្កើតជាអង្គភាពខ្លួនឯងទាំងអស់គ្នា។ វាមិនមែនជារុស្ស៊ីនោះទេ។ វាជារ៉ូម។ **នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់**។ មែន។ បង្ហាញ ខ្ញុំមកខគម្ពីរកន្លែងណាដែលបង្ហាញថាកុំម្មុនិស្ត ឬអ្វីក្រៅពីរ៉ូមដែលនឹងគ្រប់គ្រង។

409 តើ មេដេ–អូ–ភើសៀ ឈ្នះនេប៊ូក្នេសាទេ? ប្រាកដណាស់ តើក្រិកឈ្នះពួក គេទេ? ហ្នឹង។ តើរ៉ូមយកឈ្នះទាំងអស់? តើវាបានបំបែកជាអំណាចអូតូម៉ង់(Ottoman) ដប់ដូចយើងមានឥឡូវទេ? តើ...

410 *Eisenhower* ដែលមានន័យថា "ដែក" *Khrushchev* មានន័យថា "ដីឥដ្ឋ" តើពួកគេបានជួបគ្នានៅទីនោះឬ? ហើយKhrushchev បានដោះស្បែកជើងរបស់ពួកគេ [បងប្អូនប្រុសប្រានហាំគោះតុវេទិកា—Ed។] ដើម្បីឲ្យវាច្បាស់បើកនិងគោះតុដូច *នោះ* ដើម្បីបង្ហាញមនុស្ស។ [បងប្អូនប្រុសប្រានហាំគោះតុអាសនាវេទិកា]។

411 ល្អតើមានបញ្ហាអីជាមួយមនុស្សសព្វថ្ងៃ? តើជំនឿនៅឯណា? ហេតុអ្វី តើអ្នក មិនជឿ ថាព្រះបន្ទូលរបស់ព្រះជាសេចក្តីពិតឬទេ? [ពួកជំនុំនិយាយ "អាម៉ែន"—Ed។]ហើយការ នោះមិននៅ*ទីនេះ*ទេ។ តើមានបញ្ហាអ្វីជាមួយគ្រូអធិប្បាយសម័យនេះ? "កុំម្មុយនីស្តនិយម!" គ្រប់គ្រូអធិប្បាយដែលនៅក្រៅពីទីនេះព្យាយាមច្បាំងជាមួយកុំម្មុនិស្តនិយម។ លទ្ធិកុំម្មុយនិស្តមិនជាអ្វីឡើយ!

412 អ្វីដែលអារក្ខត្បាញនៅក្រោមច្រមុះរបស់អ្នកនិងមិនដឹងវាឡើយ វាជាលទ្ធិរ៉ូមលទ្ធិនិកាយនិយម។ហើយរ៉ូមជាម្ដាយនៃនិកាយទាំងអស់។ ព្រះគម្ពីរនិយាយ"នាងជាស្រីសំផឹង ហើយកូនស្រីនាងជាស្រីពេស្យា" ប្រឆាំងព្រះ ទាស់ព្រះបន្ទូលទ្រង់។

413 កងទ័ពអើយចាប់យកព្រះបន្ទូល។ទេវតានៃសេចក្ដីសណ្ដោសអើយនៅឲ្យជាប់ជាមួយព្រះបន្ទូលនោះ។ ខ្ញុំនឹងបាត់ទៅនៅថ្ងៃណាមួយ ប៉ុន្តែព្រះបន្ទូលទ្រង់មិនបាត់បង់ឡើយ។ ហើយអ្នកជា ក្មេងៗអើយបើសិនវាជាមិនកើតឡើងក្នុងជំនាន់របស់ខ្ញុំ អ្នកនឹងឃើញ។ មានសេចក្ដីនោះ។

414 តើអ្នកបានឮព័ត៌មានកាលពីព្រឹកមិញទេ? លោកស្រីខេនឌីនឹង ជួបផប់ហើយអ្វីដែលផប់និយាយ។ មើលមានគ្រប់ទាំងសាសនានៃពិភពលោក! អូ! មែនប្រហែលជាយើងនឹងបន្តបន្តិចទៀតនៅអាទិត្យក្រោយ។

415 មើល កុំបារម្ភពីរុស្ស៊ី។ រុស្ស៊ីគ្រាន់តែជាដុំគ្រួសតូចមួយប៉ុណ្ណោះនៅតាមឆ្នេរសមុទ្រ។ អ្នកមិនបាច់បារម្ភពីកុំម្មុយនីស្តឡើយ។ អ្នកពិនិត្យមើលលទ្ធិរ៉ូមពេលដែលវាបានរួបរួមជាមួយក្រុមជំនុំ។ គ្មានអ្វីដែលសរសេរនៅ ក្នុងខគម្ពីរពីកុំម្មុយនិស្តគ្រប់គ្រងពិភពលោកឡើយ។

416 ហើយខ្ញុំទៅតាមព្រះបន្ទូល ដោយមិនគិតពីអ្វីផ្សេងទៀតឡើយ។ វាជាព្រះបន្ទូលដែលខ្ញុំបានជឿតាម។ វាជាលទ្ធិរ៉ូមដែលក្ដោបយកពិភពលោក។ ហើយលទ្ធិរ៉ូមវាជាម្ដាយនៃអង្គភាពផ្សេងៗ។ វាមិនមានអង្គភាពណាឡើយរហូតដល់រ៉ូមហើយគ្រប់គ្នានៃពួកគេគឺកើតចេញពីវាមក។ ហើយព្រះគម្ពីរនិយាយដូច្នេះ "នាងជាម្ដាយនៃស្រីពេស្យា។" ខ្ញុំអាចនិយាយពីវាកន្លះថ្ងៃ ក៏បាន ម្ដងទៀត ប៉ុន្តែខ្ញុំគិតថាទៅមុខល្អជាង។

417 ពេលដែលពួកខ្មាំងសត្រូវវាយប្រហារយើង "អូ ខ្ញុំប្រាប់អ្នក អ្នកគួរតែចូលរួម..." តើអ្នកនឹងធ្វើយ៉ាងណា ត្រឡប់ទៅវិញចុះចូល ហើយសហការ? មិនមែនជាទាហានពិតឡើយ កុំអី។ អត់ទេលោក។

418 តើយើងធ្វើយ៉ាងណា? គំនិត "ចូរឲ្យគំនិតនៅក្នុងព្រះគ្រីស្ទ..."តើនេះជាអ្វីដែលព្រះគម្ពីរបាននិយាយឬ? [ពួកជំនុំនិយាយ "អាម៉ែន"—Ed។] "គំនិតដែលនៅ ក្នុងព្រះគ្រិស្ត ចូរឲ្យនៅជាប់ជាមួយអ្នក" តើគំនិតអ្វីដែលទ្រង់មាន? នៅជាប់ជាមួយព្រះបន្ទូល។ ហ្នឹងហើយ។ នៅជាប់ជាមួយព្រះបន្ទូល ព្រះបន្ទូលព្រះបិតានិងយក

ជ័យជំនះលើសត្រូវគ្រប់ពេល។ ឥឡូវពេលពួកខ្មាំងសត្រូវវាយប្រហារនិងព្យាយាមនិយាយថាអ្នកត្រូវធ្វើ*នេះ*និង*នោះ* តើអ្នកនឹងធ្វើអ្វី? នៅជាប់ជាមួយព្រះបន្ទូល។ ត្រូវហើយ។

419 តើបន្ទាប់មកអ្នកចង់ធ្វើអ្វី? យកព្រះបន្ទូល។ អ្វីជាព្រះបន្ទូល? ព្រះគម្ពីរបានចែងនៅត្រង់នេះ។ យើងគ្រាន់តែអានវា។ ត្បិតព្រះវិញ្ញាណនៃព្រះគឺជាព្រះបន្ទូល។ ឃើញទេ? មើលត្រង់នេះ។ "ហើយចូរយកមួកនៃសេចក្ដីសង្គ្រោះ និងដាវ ដាវនៃព្រះវិញ្ញាណ។" ដាវនៃព្រះវិញ្ញាណ! អ្វីទៅ? វិញ្ញាណដែលតាមរយៈគំនិតរបស់អ្នក និងនៅក្នុងគំនិតរបស់អ្នក ហើយដាវនៃព្រះវិញ្ញាណគឺព្រះបន្ទូលរបស់ព្រះ។

420 តើវិញ្ញាណច្បាំងជាមួយអ្វីច្បាំងជាមួយអ្វី? ឥន្ទ្រីយារម្មណ៍ អារម្មណ៍? [ក្រុមជំនុំនិយាយថា "អាម៉ែន។"] ព្រះបន្ទូល ចិត្ត! វេ៉រ! សិរីល្អ! តើអ្វីដែលប្រយុទ្ធជាមួយ អារម្មណ៍? ព្រះបន្ទូល! ព្រះបន្ទូល! ចូរនិយាយថា ព្រះបន្ទូល! ["ព្រះបន្ទូល"] ព្រះបន្ទូល! ["ព្រះបន្ទូល"] ព្រះបន្ទូលរបស់ព្រះជាអ្វីដែលវិញ្ញាណប្រយុទ្ធជាមួយ។

421 វិញ្ញាណនៃព្រះបានយាងមកទៅកាន់អារក្ខ និងមានបន្ទូលថា "មានសេចក្ដីចែងទុកមក!" អាម៉ែន "មានសេចក្ដីចែងទុកមក"ដូច្នេះ អារក្ខបានរត់ទៅឆ្ងាយ។

422 តើយើងត្រូវធ្វើអ្វី? យកដាវមក ដែលជាព្រះបន្ទូលព្រះរុញវាជាមួយ(អ្វី?) ដៃនៃសេចក្ដីជំនឿ ដៃនៃជំនឿដ៏រឹងមាំ ដាវមុខពីរ។ នៅក្នុងព្រះគម្ពីរហេព្រើ4 "វា—វាជាដាវមុខពីរ" កាត់បានទាំងសងខាង ទាំងទៅ ទាំងមក។

423 បងប្អូនអើយ តើគាត់ត្រូវធ្វើអ្វី? យកព្រះបន្ទូល។ យកព្រះវិញ្ញាណ អនុញ្ញាតឲ្យព្រះវិញ្ញាណចូលក្នុងចិត្តអ្នក។ បើកគំនិតរបស់អ្នក និយាយថា "ព្រះបន្ទូលទ្រង់ពិត" ឥឡូវអ្នកធ្វើបែបនេះបងប្អូនស្រី។ [បងប្រុសប្រាណហាំនិយាយម្ដងទៀតទៅកាន់ប្អូនស្រីដែលឈឺ—Ed។] "ព្រះបន្ទូលទ្រង់ពិត។"

424 "ព្រះអម្ចាស់ទូលបង្គំមិនយកចិត្តទុកដាក់ពីអារម្មណ៍ទូលបង្គំយ៉ាងណាឡើយទោះបីអ្នកណានិយាយអ្វីក៏ដោយ។ ទូលបង្គំឈប់។ ទូលបង្គំនឹងបំបើុងអស់អ្នកណាដែលនៅតាមផ្លូវទូលបង្គំចេញ ការបំផ្លិចបំផ្លាញនិងការសង្ស័យ និងការមិនជឿដែលធ្លាប់មាន។គ្រប់ទាំងអារម្មណ៍ដែលខ្ញុំធ្លាប់មាន គ្រប់ទាំងជំងឺ គ្រប់ការទាំងអស់ដែលខ្ញុំធ្លាប់មាន ខ្ញុំនឹងបំបើុងវាចោលទាំងអស់។ ទូលបង្គំឆ្លងកាត់

ទាំងអស់នោះ។ ទូលបង្គំចូលមកក្នុងវិញ្ញាណរបស់ទូលបង្គំ។ អូព្រះអម្ចាស់សូមយាងមក។ ទ្រង់មានបន្ទូលថា ទ្រង់ធ្វើឲ្យទូលបង្គំក្លាយជាភ្នាក់ងារ គ្រប់ពេល"

"អ្នកជា កូនប្រុសរបស់យើង។"

425 "ហ្នឹងហើយទូលបង្គំបើកចិត្ត បើកគំនិត។ សូមទ្រង់យាងមកព្រះយេស៊ូវ។"

426 ហើយចាប់យកជំនឿ ដែលជាដាវនៃជំនឿ **ព្រះបន្ទូលរបស់ព្រះអម្ចាស់។** ស្រែក "ហាលេលូយ៉ា។"អាម៉ែន។ រួចកាត់ចុះរាល់សត្រូវពីមុខអ្នក។ អាម៉ែន។ វាគឺដូច្នោះ។ កាត់អស់ទាំងខ្មាំងសត្រូវ។ បើ—វិញ្ញាណភ័យខ្លាចធ្វើឲ្យព្រឺក្បាល... កាត់វាចេញ ជាមួយព្រះបន្ទូលរបស់ព្រះ។

ប៉ុន្តែកម្លាំងរបស់យើងគឺ "អំណាររបស់ព្រះអង្គជាកម្លាំងនៃខ្ញុំ។"

427 "ចេញឲ្យឆ្ងាយពីខ្ញុំ" ចោះវា! អ្នកកាត់វាជាមួយព្រះបន្ទូល។ មិនថាវាជាជំងឺមិនថាជាមហារីក មិនថាវាជាអ្វី ចូរយកព្រះបន្ទូលនិងទាញដាវមក។ ហើយបើសិនជាអ្នកចោះវាជាលើកទីមួយ វាហាក់ដូចជាមិនទាន់មានចលនា ចោះវាម្តងទៀត ចោះវាម្តងទៀត និងវាត់វាម្តងទៀត។ ចោះរហូតដល់អ្នកកាត់វាជាប្រហោងមុខកាត់ ប្រៀបដូចជាមាន់ដែលចោះចេញមក ឬជាឥន្ទ្រី អ្នកជាអ្វី។ ចោះដោយខ្លួនអ្នកដើម្បីឆ្លងកាត់សំបកនៃជំងឺ។ កាត់ត្រាយផ្លូវរបស់អ្នកចេញ ហើយនិយាយថា "ហាលេលូយ៉ា! មួយ បន្ទាប់ទៀតនៅឯណា?" អាម៉ែន។ នោះជាទីលានប្រយុទ្ធ។ នោះជាទាហាន។ នោះជាទាហាននៃឈើឆ្កាង។ ហ្នឹងហើយ។ ផ្តួលគ្រប់ទាំងសត្រូវឲ្យចេញ។

428 ហេតុអ្វី? ហេតុអ្វី? យើងជាការកំណត់ទុកជាមុននៃខ្សែស្រឡាយអ័ប្រាហាំ។ ពេលអ័ប្រាហាំបដិសេធគ្រប់យ៉ាងដែលទាស់នឹងព្រះបន្ទូលរបស់ព្រះ គាត់បានកាប់វាត់ត្រាយផ្លូវរបស់គាត់កាត់តាមគ្រប់ទាំងឧបសគ្គរាំងដែលព្រះបានដាក់នៅពីមុខលោក។ ពួកគេនិយាយ "ប្រពន្ធរបស់អ្នកចាស់ពេកហើយ។" ទ្រង់គ្រាន់តែកាប់វាចេញពីផ្លូវនោះ។ អារក្សនិយាយ "អ្នកមិនអាចធ្វើ*ការនេះ* អ្នកមិនអាចធ្វើការ*នោះ*។" អ័ប្រាហាំកាប់វាចេញពីផ្លូវ។ គាត់វាត់វា ហើយវាត់ទៀតរហូតដល់វាត្រូវបានកាត់។

"នៅកន្លែងណាបន្ទាប់ទៀត ព្រះអម្ចាស់?"

429 "រើតង់របស់អ្នកឡើងមក*ទីនេះ*" គាត់បានឡើងទៅសង់អាសនានៅទីនោះ។

430 ទៅដល់ទីនោះហើយសាតាំងមកនិយាយថា "ឥឡូវ អញប្រាប់ឯង នេះមិនមែនជាកន្លែងត្រឹមត្រូវទេ។"

"ខ្ញុំនឹងនៅទីនេះចេញពីទីលានរបស់ខ្ញុំទៅ" គាត់និយាយថា "ហាលេលូយ៉ា។"

431 ឡុត និយាយ "អ្នកគួរតែមកទីនេះល្អជាង។ យើងមានពេលវាលាដ៏ល្អនៅក្រោមនេះ។ យើងទាំងអស់គ្នាមានអង្គការរបស់យើងនៅទីនេះ។ ហេតុអ្វីប្រពន្ធរបស់ខ្ញុំជាស្ត្រីជាមេនៃសមាគមន៍ផ្នែកអក្ខរកម្ម និងអ្វីផ្សេងទៀត ក្នុងក្រុង។ ខ្ញុំប្រាប់អ្នក អ្នកគួរតែមកទីនេះ។"

សារ៉ានិយាយ "អ័ប្រាហាំ..."

432 "បិទមាត់សារ៉ា" ហាលេលូយ៉ា! "ឈរនៅទីនេះ។ នេះជាកន្លែងដែលព្រះដាក់ខ្ញុំ។ ត្រង់នេះជាកន្លែងដែលខ្ញុំឈរ។"

433 នេះជាកន្លែងដែលព្រះដាក់ខ្ញុំ។

គ្រប់ទាំងការសាទរអំណាចនៃព្រះនាមព្រះយេស៊ូវ!
សូមឲ្យទេវតាថ្វាយបង្គំ
នាំយកមកនូវ មកុដពេជ្រ
និងបំពាក់ទ្រង់ជាព្រះអម្ចាស់លើទាំងអស់។

កាលបើព្រះគ្រិស្តជាថ្មដារឹងមាំ ខ្ញុំឈរនៅ
កន្លែងផ្សេងទៀតជាដីខ្សាច់លិចចុះ
កន្លែងផ្សេងទៀតជាដីខ្សាច់លិចចុះ។

434 ទោះជាសេចក្តីស្លាប់ផ្ទាល់អ្វីផ្សេងៗ ជាខ្សាច់ដែលលិចចុះ។ លើព្រះគ្រីស្ទ ជាថ្មដាដែលខ្ញុំឈរនៅ។

435 "ជាពូជស្តេចមកពីអ័ប្រាហាំ។" ពូជរាជវង្ស! ហេតុអ្វី ការជ្រើសរើសទាហានរបស់អង់គ្លេសភាគច្រើនគឺមកពីពូជស្តេចនៃអង់គ្លេស ជាលោហិតរាជវង្សគ្រប់យ៉ាង។ ហើយពូជនៃរាជារបស់ព្រះគ្រីស្ទគឺក្រុមជំនុំដែលបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ បំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ អ្វី? ពូជស្តេច តាមសេចក្តីសន្យា មិនមែនតាមការមានអារម្មណ៍។ ប៉ុន្តែ ដោយសេចក្តីសន្យានៃព្រះ ពួកគេឈរលើព្រះបន្ទូលរបស់ព្រះ និងត្រួសត្រាយផ្លូវតាមនោះ ស្រែកឲ្យខ្លាំងថា "ហាលេលូយ៉ា!"

ទោះជាសេចក្ដីស្លាប់មកនិងនិយាយ "វានឹងចូលមកក្នុងដៃអាវរបស់អ្នក"

436 និយាយ "ឲ្យផ្លូវខ្ញុំ ទន្លេយ័ដាន់។ ខ្ញុំនឹងឆ្លងទៅ" កាត់ផ្លូវរបស់អ្នកតាមនោះទៅកាន់ទឹកដីសន្យា។ អាម៉ែន។

437 តើមានអ្វីកើតឡើងនៅពេលដែលសង្គ្រាមបញ្ចប់? ខ្ញុំនឹងបិទឥឡូវ ប្រាកដណាស់។ពេលទីលានសង្គ្រាមបញ្ចប់ទៅហើយពួកបរិសុទ្ធបានដើរក្បួនត្រឡប់មកផ្ទះវិញខ្ញុំចង់សួរអ្នកអ្វីមួយ មានអ្វីកើតឡើង?

438 មានអ្វីកើតឡើងពេលហ៊ីត្លែរ(Hitler)បានទៅប្រទេសបារាំង? ហេតុអ្វី ពួកគេនិយាយថាគេមិនអាចមើលឃើញមេឃផង ក្នុងមួយខណៈដែលមានយន្ដហោះ។ ដំណើរជំហានទៅរបស់អាឡឺម៉ង់។ [បងប្អូនប្រុសប្រាណហាំធ្វើដំណើរទៅលើវេទិការពីរដង—Ed។] ឃើញ ពួកគេកំពុងឈរ អ្នកឆ្លងកាត់ អបអរជ័យជំនះ។

439 ពេលស្ដាលីនទៅរុស្ស៊ី ប៉ុន្មានម៉ាយពីក្រោយមានរថក្រោះ នៅពីក្រោយតៗគ្នាជាការបាញ់ក្រុងប៊ឺឡាំងរហូតដល់គ្មានអ្វីនៅសេសសល់។ នោះគឺ ដូច្នោះ។ ហើយពេលពួកគេចេញទៅហើយពួកអាឡឺម៉ង់ទាំងនេះ...ពួកទាហានរ៉ូស៊ីអបអរសាទរពួកគេចេញទៅជាមួយសេចក្ដីនោះ អ្នកដឹងហើយ រឿងកំប្លែងតូចមួយដែលពួកគេធ្វើ។ ខ្ញុំឃើញតាមរូបភាពម្ដងនៅក្រុងឡុងពួកគេមក ដោយរបៀប រូបភាពពិតនៃកន្លែងដែលមានអ្វីកើតឡើង ចូលមកប្រារព្ធ ពិធីអបអរ។ អូ ខ្ញុំអើយ!

440 នៅពេលយើងឮ នោះសង្គ្រាមបានចប់យើងស្រែក យើងផ្លុំ យើងហួច។ ពេលដែលវីរៈបុរសត្រឡប់មកវិញ យើងជួបពួកគេនៅទីនោះ។ ពួកគេស្រែក។ ពួកគេប្រកូកហៅ។ ខ្ញុំមានបងប្អូនជីដូនមួយនៅទីនេះ និយាយថា ពេលគាត់ត្រឡប់មកវិញ រាល់ចាស់...ទាហានចាស់ៗដែលពិការ ពួកគេមិនអាចចេញពីគ្រែបាន ដូច្នេះពួកគេបង្ខិលទៅខាងលើកប៉ាល់ពេលដែលពួកគេចូលមកក្នុងដើម្បីមើលរូបភាព នៃសេរីភាពដែលឈរនៅទីនោះ។និយាយ "ពួកគេជាមនុស្សអស្ចារ្យឈរនៅទីនោះ ពួកគេយំនិងធ្លាក់ចូលក្នុងភាពបែប*នោះ* ពេលពួកគេឃើញរូបសំណាកនៃសេរីភាព។" នៅឆ្ងាយពីផ្ទះរយៈពេលបួនឆ្នាំ ច្បាំងតក់ស្លុតទីលានសង្គ្រាមនិងអ្វីផ្សេងទៀត។ ប៉ុន្តែពួកគេដឹងថាប្រពន្ធ និងអ្នកដែលស្រឡាញ់ និងម្ដាយ និងឪពុក និងកូន និងអ្វីទាំងអស់ដែលគេស្រឡាញ់ នៅពីក្រោយរូបសំណាកសេរីភាពនោះ។ វាតំណាងឲ្យអ្វីដែលពួកគេច្បាំងសម្រាប់នោះ។ អូ សម្លេងហួចបន្លឺ

ហើយក្រុងញ៉ូវយ៉កក្លាយជាសម្រែកនោះជាអ្វីទាំងនោះពេលដែលពួកវីរៈបុរសមក ដោយដើរក្បួន។ នោះជារឿងតូចៗ។

441 មានពេលមួយដែលសេសា បន្ទាប់ពីចម្បាំងដ៏ធំ គាត់និយាយ "ខ្ញុំចង់ឲ្យអ្នកចម្បាំងដែលល្បីល្បាញបំផុតរបស់ខ្ញុំជិះក្បែរខ្ញុំនៅក្នុងការប្រារព្ធអបអរយ៉ាងធំនៃជ័យជំនះលើខ្មាំងសត្រូវរបស់យើង។" ហើយគ្រប់គ្នានៃមន្ត្រីកាត់តម្រឹមតុបតែងស្លាបសត្វនិងបំភ្លឺខែលរបស់គេ ហើយក៏ដើរជាក្បួនអ្នកដឹងទេរបៀបនោះ ដូចជា—ដូចជាទាហានពិតបែបនោះ។ បន្ទាប់មកមានគូកនតូចចាស់ម្នាក់មកជិតគាត់។ ខ្ញុំអើយ! គាត់មកស្វែងរកនិងចាប់ផ្ដើម ដូច*នោះ*។ សេសានិយាយ "ចាំបន្តិចចាំបន្តិចអ្នក" មិនទាំងស្លៀកពាក់ដូច—មន្ត្រីនិយាយ "មកនេះ។" គាត់និយាយថា "តើកន្លែងណាដែលអ្នកធ្វើឲ្យពួកគេខ្លាច?

គាត់និយាយថា "ចេញទៅសមរភូមិ។"

442 និយាយ "ឡើងមកទីនេះ។ អ្នកគឺជាមនុស្សខ្ញុំចង់កំណត់ដោយខ្លួនឯង។" ហេតុអ្វី? គាត់ចង់បង្ហាញថា គាត់នៅក្នុងសមរភូមិ។

443 អូ ព្រះអម្ចាស់អើយសូមសណ្ដោសបុរសដែលអាចកាត់ដៃរបស់គាត់ដោយកំប៉ុងត្រីសាឌីន ដើម្បីអាចបានការសរសើរ។ ខ្ញុំចង់បានស្លាកស្នាម—ទីលានសង្គ្រាម។ ដូចប៉ុលនិយាយ "ខ្ញុំដាក់បន្ទុកវា ក្នុងរាងកាយរបស់ខ្ញុំ ទីសម្គាល់ព្រះយេស៊ូវគ្រីស្ទ។" នោះគឺជាហេតុដែលខ្ញុំចង់ចូលទីលានប្រយុទ្ធ។

444 ថ្ងៃមួយពេលមេបញ្ជារការនឹងមក ជាអង្គដែលបំពាក់យើង ជាអង្គដែលប្រទានឲ្យគ្រឿងសាស្ត្រាវុធរបស់ព្រះ ព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យយើងនូវព្រះបន្ទូលរបស់ទ្រង់ដើម្បីច្បាំងឈរនៅទីនោះ ពេលមេបញ្ជាការជិះចូលមក ខ្ញុំចង់ឡើងទៅនិងជិះរទេះជាមួយទ្រង់ទៅផ្ទះ។ តើអ្នកមិនចង់ដូច្នេះទេឬ? [ពួកជំនុំនិយាយ "អាម៉ែន"—Ed។] រួចពេលខ្ញុំយកប្រពន្ធចាស់របស់ខ្ញុំមកក្នុងដៃ មើលជុំវិញនេះទីនេះ និងឃើញបងប្អូនរបស់ខ្ញុំនិងប្រពន្ធពួកគេ និងកូនរបស់ពួកគេ ពេលយើងដើរទៅឆ្លងកាត់អ្វីៗនៅស្ថានសួគ៌របស់ព្រះ និងទេវតាពោរពេញលើអាកាសព្រមដោយចម្រៀងភ្លេងជាតិនៅពីលើដូចនោះ និយាយពីការប្រារព្ធអបអរ!

445 ហើយពេលទីលានសង្គ្រាមបានចប់ យើងនឹងពាក់មកុដ។ អូខ្ញុំ! អូ ទាហាននៃឈើឆ្កាងនៅព្រឹកនេះ ដកដៃនៃជំនឿចេញមកទីនេះ និងចាប់កាន់យកអាវុធនេះ។

446 ចុះអ្នកវិញ? ប្អូនស្រី អ្នកត្រៀមរួចឬនៅ[បងប្អូនប្រុសប្រានហាំនិយាយម្តងទៀតទៅកាន់ប្អូនស្រីដែលឈឺ—Ed។] ដកអាវុធចេញមក និយាយ "ព្រះអង្គអើយ ទូលបង្គំមិនខ្វល់អ្វី—អ្វីដែលអារក្ខនិយាយ មកកាន់ទូលបង្គំក៏ដោយ ច្រើនប៉ុណាដែលគេនិយាយ។ នៅព្រឹកនេះទូលបង្គំជឿ"[ប្អូនស្រីនិយាយ "ខ្ញុំក៏ជឿដែរ"—Ed។] "ខ្ញុំជឿហើយ។"

447 ដូចអ្វីដែលខ្ញុំនិយាយនៅថ្ងៃមុន បន្តិច...ខ្ញុំគិតថាប្រហែលជាកាលពីប៉ុន្មានសប្តាហ៍មុនមានបុរសម្នាក់យល់សប្តិ។ គាត់យល់សប្តិថាវិញ្ញាណអាក្រក់ ជាអ្វីតូចចាស់មួយរត់តាមគាត់។ គាត់និយាយ "ប៉ូ!"ហើយវាលោតទៅវិញរួចអារក្ខចាប់ផ្តើមរីកធំជាងមុនបន្តិច។"ប៉ូ!"ហើយវាលោតត្រឡប់ទៅវិញ កាន់តែធំជាងមុន។ ទីបំផុតអារក្ខបានរីកធំដូចរូបភាពវា និងអាចយកឈ្នះគាត់។ គាត់ដឹងថាគាត់ត្រូវតែច្បាំងជាមួយវាដោយអ្វីមួយដូច្នេះគាត់សម្លឹងមើលជុំវិញ។ គាត់មិនអាចរកឃើញ អ្វីដើម្បី ច្បាំងជាមួយវាឡើយ។ គាត់ចាប់ព្រះគម្ពីរមក។ រួចអារក្ខនិយាយថា"ប៉ូ!"គាត់និយាយ"ប៉ូ!"ទៅកាន់វាវិញ ហើយអារក្ខក៏រួមតូចទៅៗ។ ហើយទីបំផុត គាត់វាយវាដល់ស្លាប់ជាមួយព្រះបន្ទូល។

448 អ្នកជាទាហាន មិនអីចឹងឬ ប្អូនស្រី? [បង ប្រុសប្រាណហាំនិយាយទៅកាន់ប្អូនស្រី—Ed។] យកព្រះបន្ទូលនោះនិងនិយាយ "មានសេចក្តីចែទុកមកថា។" អាម៉ែន។ "ខ្ញុំមិនស្លាប់ទេ។ ខ្ញុំនឹងរស់។ ខ្ញុំនឹងឈរនៅពោងឧបោសថរបស់ព្រះនិងសរសើរតម្កើងព្រះសំរាប់សេចក្តីល្អរបស់ទ្រង់ជានិងក្រុមជំនុំទាំងអស់គ្នា។"

449 តើអ្នកជឿទេ ពួកអ្នកបរិសុទ្ធ [ពួកជំនុំនិយាយ "អាម៉ែន។"—Ed។] អាម៉ែន។

ចូរឱនក្បាលរបស់យើង។

450 អូ ព្រះអម្ចាស់ ព្រះអទិករនៃស្ថានសួគ៌និងផែនដី ចូរឲ្យគេដឹងថាថ្ងៃនេះ ទ្រង់នៅតែជាព្រះ។ មិនថាទូលបង្គំអធិប្បាយច្រើនប៉ុណា ឬ និយាយច្រើនប៉ុណា ព្រះអម្ចាស់អើយ ព្រះបន្ទូលដែលចេញពីទ្រង់ទើបសំរេចបាន។

451 កូនកន្សែងទាំងនេះបានដាក់នៅទីនេះ តំណាងឲ្យអ្នកជំងឺ។ ទូលបង្គំអធិស្ឋានព្រះវរបិតាគង់នៅស្ថានសួគ៌ ដែលព្រះបន្ទូលទ្រង់និងឫទ្ធានុភាពនឹងគង់នៅលើពួកគេម្នាក់ៗកាលបើទូលបង្គំដាក់ដៃលើពួកគេ។ ព្រះអង្គអើយ ក្នុងព្រះនាមព្រះយេស៊ូវ ទូលបង្គំអធិស្ឋានដែលទ្រង់ចាក់ប្រេងតាំងកូនកន្សែង ទាំងនេះជាមួយព្រះវត្តមាន

បរិសុទ្ធនៃទ្រង់ព្រោះនេះជាសេចក្តីដែលបានកត់ទុកមកក្នុងព្រះបន្ទូល។ វាមិនមានអ្វីទាស់នឹងព្រះបន្ទូលឡើយ។ ប៉ុន្តែក៏មាននិយាយនៅក្នុងព្រះបន្ទូលថា "ពួកគេបានយកពីរាងកាយរបស់ប៉ុលជាកូនកន្សែង។ វិញ្ញាណអាក្រក់បានចេញពី មនុស្ស ហើយពួកគេ បានជាពីជំងឺផ្សេងៗ"។ ឥឡូវយើងមិនមែនជាអ្នក បរិសុទ្ធ ប៉ុលឡើយ ប៉ុន្តែទ្រង់នៅតែជាព្រះ និងទ្រង់តែជាព្រះវិញ្ញាណបរិសុទ្ធដដែល។ ទូលបង្គំដាក់ដៃលើកូនកន្សែង ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ និងសូមឲ្យទ្រង់ប្រទានពរ និងប្រោសពួកគេម្នាក់ៗឲ្យបានជា។

452 ហើយព្រះអង្គអើយមានអ្វីដែលដាក់លើគ្រែ នៅទីនេះ មិនមែនជាអ្វីក្រៅពីកូនក្មេងឡើយជាក្មេងស្រីតូចស្អាតមួយ។ នាងមិនអាចរស់បានទេព្រះអម្ចាស់។ សាតាំងបានធ្វើការអាក្រក់ចំពោះនាង។ ហើយពេទ្យជាទីស្រឡាញ់នៃផែនដីនេះព្យាយាមខំប្រឹង មិនមានការសង្ស័យឡើយ ដើម្បីសង្គ្រោះក្មេង។ ប៉ុន្តែពួកគេមិនអាចធ្វើបាន។ ពួកគេដល់ដំណាក់កាលទាល់ប្រាជ្ញាហើយ។ ពួកគេមិនដឹងថាត្រូវធ្វើអ្វីទៀតឡើយ។ ប៉ុន្តែព្រះអម្ចាស់ទូលបង្គំមានអំណាវដែលគ្មានជំពូកណាសរសេរទៀតឡើយ។ យើងខ្ញុំអាចបើកទំព័រថ្មីនិងនៅក្នុងទំព័រនេះយើងបានឃើញពេទ្យយ៉ាងអស្ចារ្យយាងមក។ ទូលបង្គំយើងខ្ញុំបានទូលយាងទ្រង់ជាទីផ្តល់ជំនួយនៅព្រឹកនេះ។

453 ឥឡូវ ព្រះអម្ចាស់ តើមិនមានការសរសេរនៅត្រង់នេះនៃព្រះបន្ទូលរបស់ទ្រង់ទេឬអីថា "ទីសម្គាល់នេះនឹងនៅជាប់អស់អ្នកដែលជឿទេឬ?" ព្រះអម្ចាស់បើទូលបង្គំមិនជឿ ចូរធ្វើឲ្យបានជាម្នាក់ដែលជឿឥឡូវ។ បើសិនជាក្មេងស្រីមិនមែនជាអ្នកជឿ ធ្វើឲ្យនាងក្លាយជាម្នាក់ដែលជឿ។ "ទីសម្គាល់ទាំងនេះនឹងកើតចំពោះអស់អ្នកដែលជឿបើសិនពួកគេដាក់ដៃលើអ្នកជំងឺគេនឹងបានជា" ក៏មាន សេចក្តីកត់ទុកមកថា "ក្នុងនាមឈ្មោះរបស់ ខ្ញុំពួកគេនឹងដេញវិញ្ញាណអារក្ខ" ព្រះអម្ចាស់ពួកវា—ពួកវាជាព្រះបន្ទូលទ្រង់។ ជារបស់ទ្រង់។ វាជាព្រះបន្ទូលទ្រង់។ និងឥឡូវដោយភាពជាអ្នកបម្រើទ្រង់...

454 ដូចដែលទ្រង់មានបន្ទូលថា "ប្រសិនបើមានពីរឬបីនាក់ជុំគ្នាទ្រង់នឹងគង់នៅកណ្តាលចំណោមនោះ ហើយបើអ្នកព្រមព្រៀងអ្វី ប៉ះអ្វីមួយ ហើយសូមអ្នកនឹងទទួលបានវា។"

455 ព្រះអង្គអើយ ក្មេងនេះប្រហែលជាឈឺខ្លាំងបំផុតនៅក្នុងអាគារនេះនៅព្រឹកនេះ ព្រោះនាងមិនអាចរស់ដោយគ្មានទ្រង់ឡើយ ជាយូមកហើយ ហើយនាងជាអ្នកឈឺធ្ងន់ជាងគេ។ ដូច្នេះទូលបង្គំទាំងអស់គ្នាយល់ព្រម ហើយដូចជាទាហានម្នាក់ៗឈរនៅទីនេះ។ ហើយនៅក្នុងក្រុមនេះឈរជារាជត្រកូលនៃអ័ប្រាហាំ។

456 យើងកំពុងតែដើរក្បួនក្នុងចំណោមសាតាំងឥឡូវ។ ហើយត្រៀមនឹងចេញទៅសាតាំង គ្រឿងសឹករបស់យើងមានអំនាច បញ្ចេញពណ៌យ៉ាងច្បាស់ មនុស្សប្រុសស្រីកាន់ដាវដើក្បួនទៅមុខទៅរកឯងសម្រាប់ក្មេងស្រីតូចនេះ។ ចេញពីនាងទៅ សាតាំង។ ចេញពីក្មេងស្រីទៅ។ ដោយគ្រឿងសឹករបស់ព្រះមានព្រះជន្មរស់យើងដេញឯង។ ចេញពីនាង ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។

457 ខ្ញុំនឹងទៅដាក់ដៃលើនាង។ ហើយសាតាំងឯងបានចងក្មេងនេះ ឯងបានធ្វើការអាក្រក់នេះ។ យើងដឹងថាឯងអាចយកឈ្នះលើមនុស្សបាន ប៉ុន្តែឯងមិនអាចឈ្នះលើ ព្រះអម្ចាស់របស់យើងឡើយ ដូច្នេះយើងមកដោយ ព្រះនាមទ្រង់។ ចេញពីនាងឯងជាវិញ្ញាណអាក្រក់។ ឯងជាវិញ្ញាណជំងឺ ចេញពី ក្មេងនេះ ហើយនាងនឹងមានសេរីភាព ពីថ្ងៃនេះតទៅ។ យើងប្រកាសការនេះ ក្នុង ព្រះនាមព្រះយេស៊ូវគ្រិស្ត។

458 ឥឡូវព្រះអម្ចាស់ជាព្រះ ទ្រង់ដែលបានប្រោសអ្នកស្លាប់ឲ្យរស់វិញនិងបង្ហាញថាទ្រង់ជាព្រះ សូមប្រោសស្ត្រីក្មេងនេះឲ្យ មានសុខភាពនិងកំលាំងដូចដើមវិញ។ ដែលនាងឈរនៅអាគារនេះ។

អារក្ខចេញពីនាង មាន—មានសេចក្តីចែងទុកមកដូច្នេះ ចូរឲ្យសម្រេចបានឥឡូវ។

459 តើមានអ្នកណាទៀតនៅទីនេះចង់លើកដៃ ហើយនិយាយថា "ខ្ញុំចង់បានការអធិស្ឋាន។ ខ្ញុំឈឺ។ ខ្ញុំត្រូវការព្រះ"? ខ្ញុំមិនដឹងថាយើងមានពេលប៉ុណ្ណាទេ។ យើងមានពេលគ្រប់គ្រាន់ឲ្យមនុស្សដើរកាត់ទីនេះ។ ខ្ញុំមានអារម្មណ៍កំសាន្តចិត្តពិតនៅព្រឹកនេះឥឡូវនេះ។ មែន មែន។ ខ្ញុំចង់ឲ្យអ្នកដើរចុះមកទីនេះ ប៊ីលី(Billy)អាចនឹងចាប់ផ្តើមត្រង់នេះចំណុច នៅខាង*នេះ*សិន។ ចាប់ពីត្រង់នេះមកមុនសិន បន្ទាប់មកចាំបន្តទៀត ចូរឡើងទៅច្រកដើរ*ទីនោះ*។ រួចយើងគ្រាន់តែយកគេបែបនោះដើម្បីមិនឲ្យគេ...

460 ហើយឥឡូវខ្ញុំចង់ឲ្យបងប្រុសនេវីលនិងបងប្អូនអ្នកដឹកនាំរបស់ខ្ញុំឈរក្បែរនោះជិតខ្ញុំ ទីនេះ ដូច្នេះអ្នកអាចយកពួកគេចុះតាមច្រកដើរម្តងទៀត។ ពិតណាស់។ ត្រឹមត្រូវហើយ។ ឥឡូវខ្ញុំ...

461 តើប៉ុន្មាននាក់បានបំពាក់គ្រឿងសឹករបស់អ្នកហើយ? [ពួកជំនុំនិយាយ "អាមែន"Ed។]

462 (វានឹងខុសប្លែកឥឡូវ។ ទៅផ្ទះដោយសេចក្តីសុខសាន្ត ល្អចុះឥឡូវ។)

463 អាម៉ែន។ អូ ខ្ញុំអើយ! ទាហានទាំងអស់ ដកដាវមក ។ ដកដាវមក ទាហាននៃឈើឆ្កាង ដើរក្បួន ដើរក្បួន។

ព្រះគ្រីស្ទ ជាថ្មដារឹងមាំ ខ្ញុំឈរ។
ទីវាលដីទៃជាខ្សាច់ដែលលិចលង់។

464 ពិតណាស់ចូលមក មកតាមខាង*នេះ*។ គ្រប់គ្នានៅក្នុងការអធិស្ឋានឥឡូវពេលពួកគេដើរកាត់។

ក្នុងព្រះនាមព្រះយេស៊ូវព្យាបាលស្ត្រីនេះ។ អាម៉ែន។

ដកដាវមក។តម្រង់ឲ្យទៅកន្លែងរបស់អ្នក ហើយស្រែក។

465 ក្នុងព្រះនាមព្រះយេស៊ូវ...?...ក្នុងព្រះនាមព្រះយេស៊ូវ...?...ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ...?...

បន្តទាហានគ្រីស្ទាន!
ដើរជាក្បួនសង្គ្រាម
ជាមួយឈើឆ្កាងព្រះយេស៊ូវ។
ដែលដើរនៅខាងមុខ។

466 "ចេញទៅសាតាំង" មិនថាមានរឿងអ្វី ទាហាន? តើឯងមិន។ គិតថាយើងអាចឈ្នះទេឬ? [ពួកជំនុំនិយាយថា "អាមែន"—Ed។] ឯងបានចាញ់ហើយ។ យើងជាអ្នកលើសជាងអ្នកមានជ័យជំនះក្នុងព្រះគ្រីស្ទយេស៊ូវ។ គ្រប់ទាំងអារក្សនឹងដេញចេញ គ្រប់អ្វីផ្សេងទៀត។ អាម៉ែន។

មកនេះ បងប្អូនអើយ!...?...

ខ្ញុំអធិស្ឋានអ្នកនឹងបានជា...?...

សូមឲ្យជា ប្អូនប្រុស ពេទ្យ ព្យាបាល ព្រះបិតា ក្នុងព្រះនាមព្រះយេស៊ូវ

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ សូមព្យាបាលស្ត្រីម្នាក់នេះ។ មក...?...

467 ឥឡូវនេះគាត់បានយក...ខ្ញុំចង់សុំបងប្រុសនៅខាងក្រោយ។ គ្រប់ទីកន្លែងព្រះអង្គម្ចាស់...?...

468 អូ ព្រះអម្ចាស់ជាព្រះ ព្រះអទិករនៃស្ថានសួគ៌និងផែនដី! ឱព្រះអង្គអើយទ្រង់ជ្រាបចិត្តរបស់នាង។ ទ្រង់ជ្រាបទាំងអស់។ ទូលបង្គំអធិស្ឋានសម្រាប់ទាំងម្ដាយនិងឪពុក។ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ទូលបង្គំសូមថ្វាយ...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ខ្ញុំ...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ខ្ញុំ...?...

469 ព្រះអង្គអើយ សូមគង់ជាមួយប្អូនស្រីម្នាក់នេះ។ យើងបានដឹងថាជាច្រើនឆ្នាំដែលលូនវារនិងសេចក្ដីស្លាប់ចង់ក្ដោបយករាងកាយរបស់ស្ត្រី។ ឥឡូវក្នុងព្រះនាមព្រះយេស៊ូវ...?...

470 ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ សូមប្រទានពរក្មេងស្រីតូចនេះ ព្រះអម្ចាស់។ ទីលានសង្គ្រាមរបស់ទូលបង្គំនៅសាលាទីនោះទូលបង្គំដឹងពីអ្វីដែលនាងឆ្លងកាត់។ ទូលបង្គំអធិស្ឋានដែលទ្រង់ប្រទានពរ។ សូមឲ្យនាងបានដកដាវព្រឹកនេះនិងដើរទៅមុខ!...?...សូមប្រទានពរដល់ក្មេងម្នាក់នេះ ព្រះអម្ចាស់អើយគាត់មកដើម្បីអំពាវនាវព្រះនាមទ្រង់ ព្រឹកនេះ ទូលបង្គំអធិស្ឋានថាទ្រង់នឹងទៅជាមួយ...?...

471 សូមព្រះប្រទានពរដល់ ប្អូនប្រុស សូមទទួលសំណើរសុំរបស់គាត់។ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ ទូលបង្គំអធិស្ឋាន!...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើងសូមថ្វាយការអធិស្ឋាន។

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើងសូមថ្វាយការអធិស្ឋាន។

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើងសូមថ្វាយការអធិស្ឋាន។

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើង...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើងសូមថ្វាយការអធិស្ឋាន។

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ សូមព្យាបាលបងប្អូនយើង។

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

472 [មានអ្នកនិយាយ "ព្រះវរបិតាបានសុគត"—Ed។] ព្រះជាម្ចាស់សូមជួយនាង ក្នុងព្រះនាមព្រះយេស៊ូវ។

ព្រះអង្គអើយ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើង...?...

ព្រះអង្គអើយ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ...?...

ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ សូមព្យាបាលបងប្អូនយើង។

ក្នុងព្រះនាមព្រះយេស៊ូវ...?...

តើអ្នកយល់ទេឥឡូវ?

ឱ ព្រះអង្គអើយ សូមឲ្យការនេះចេញឲ្យឆ្ងាយពី...?...

473 ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើងខ្ញុំសូមអធិស្ឋាន!...?...សូមទទួល ប្អូនស្រី...?...

474 អូ ព្រះ ដោយស្គាល់ម្ដាយដ៏គួឲ្យអាណិតមួយនេះ ដែលឆ្លងកាត់បញ្ហាទាំងអស់នេះ ទូលបង្គំអធិស្ឋានព្រះអង្គអើយទ្រង់នឹង...?...លើគាត់។

សូមដាកដាវ Ed ហើយដើរទៅមុខក្នុងព្រះនាមព្រះយេស៊ូវ។

475 អូ ព្រះអង្គអើយ សូមព្យាបាលស្ត្រីនេះ។ ទទួលតាមសំណើររបស់គាត់។ សូមឲ្យគាត់ដកដាវពីមុខគាត់ ក្នុងទុក្ខលំបាក។

អូ ព្រះអង្គអើយ...?...នៅព្រឹកនេះ។ ទូលបង្គំអធិស្ឋានថាទ្រង់នឹង...?...

476 ព្រះវរបិតាអើយ ទូលបង្គំអធិស្ឋានថាទ្រង់ព្យាបាលបងប្អូនប្រុសនិងប្រោសគាត់បានប្រសើរឡើង។ ហើយនៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត...?...

477 ព្រះអង្គអើយ ទូលបង្គំអធិស្ឋានសូមទ្រង់នឹងព្យាបាលប្អូនស្រីរបស់យើងប្រោសគាត់ឲ្យបានជា ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។

478 ព្រះវរបិតាទូលបង្គំអធិស្ឋានសូមទ្រង់—នឹងព្យាបាលបងប្អូនរបស់យើង។

សូមព្យាបាលបងប្អូនស្រីរបស់យើង ព្រះអម្ចាស់អើយ!...?...

ព្រះវរបិតាក្នុងព្រះនាមព្រះយេស៊ូវ សូមព្យាបាល បងប្អូនស្រី ព្រះវរបិតាអើយ

479 ព្រះបិតា...?...យើងសូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ។ ព្រះអង្គអើយសូមព្យាបាលស្ត្រីម្នាក់នេះ។

ឱព្រះអង្គអើយ ទូលបង្គំអធិស្ឋានថាទ្រង់...?...

480 អូព្រះអង្គអើយ សូមប្រទានពរដល់គាត់ ព្រះបិតាអើយ...?...ស្រលាញ់បងប្អូនចាស់ៗ នោះណាស់ព្រះអម្ចាស់។ ហើយទូលបង្គំអធិស្ឋានដែលទ្រង់នឹងទទួលសំណើររបស់គាត់!...?...

481 ព្រះវរបិតាគង់នៅស្ថានសួគ៌នៃទូលបង្គំអើយ ទូលបង្គំអធិស្ឋានដែលបងប្អូន...?...ឱព្រះអង្គអើយ...?...ឱព្រះអង្គអើយ...?...ទានហាននៃឈើឆ្កាង។ ហើយគាត់នឹងដកដាវនោះនៅព្រឹកនេះដើរទៅមុខ។

ព្រះអង្គ យើង...?...សូមទទួល អូ ព្រះអម្ចាស់ សំណើររបស់គាត់។

482 ព្រះប្រទានពរដល់បងប្អូនប្រុស...?...ទូលបង្គំអធិស្ឋានដែលទ្រង់ព្យាបាល គាត់ព្រះអម្ចាស់!...?...ប្រទានឲ្យគាត់នូវបំណងចិត្ត ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

483 អូ ព្រះវរបិតាគង់ស្ថានសួគ៌អ្នកដឹកនាំតូចនៃដំណឹងល្អបំពង់ករបស់គាត់...?...កន្លែងដែលគាត់សំអាតក្នុងផត...?...ព្រះអង្គអើយទូលបង្គំអធិស្ឋាន ដែលទ្រង់នឹង...?...ហើយកាលបើទ័ពរបស់ព្រះជាម្ចាស់កំពុងធ្វើដំណើរទៅមុខឥឡូវ ដែលមានដាវលើកឡើង សូមឲ្យនាងមានជ័យជំនះ ព្រះអម្ចាស់។ ប្តីតូចរបស់គាត់នៅទីនេះព្រះអម្ចាស់ជាអ្នកដែលបាននាំចេញពីគ្រែមហារីកដែលគាត់បានដេកនិងជិតស្លាប់ជាមួយមហារីកហើយដុកទ័របោះបង់ហើយ ពេលដែលគាត់ទៅជួប។ ហើយឥឡូវគាត់នៅទីនេះ នៅព្រឹកនេះ ជាទាហាននៃឈើឆ្កាងតូចមួយ។

សូមប្រទានកម្លាំងឲ្យគាត់ព្រះអម្ចាស់សម្រាប់ការបម្រើរបស់ទ្រង់ទូលបង្គំយើងខ្ញុំអធិស្ឋាន ក្នុងព្រះនាមព្រះយេស៊ូវ។

484 ខ្ញុំចង់ឲ្យស្ត្រីតូចមួយនោះជាមួយអ្នក អធិប្បាយនៅទីនេះ។ មកនេះបងប្រុសឃីដ(Kidd)។ បុរសម្នាក់នេះត្រូវបានបញ្ជូនពីមន្ទីរពេទ្យ ទៅផ្ទះថ្មីៗនេះដែលជិតស្លាប់ត្រូវបានលេបត្របាក់ដោយជំងឺមហារីក។ [បងប្អូនស្រីឃីដនិយាយ "មួយឆ្នាំមកហើយ"–Ed។] មួយឆ្នាំកន្លងទៅ ["ពីរ"] ពីរឆ្នាំ ជាមួយក្រពេញប្រូស្តាត។ ដុកទ័ររបស់គាត់ទុកពេលឲ្យគាត់រស់តែពីរបីថ្ងៃប៉ុណ្ណោះ។ ហើយព្រឹកមួយគាត់មកទីនោះ មុនគេ ផ្តល់ការអធិស្ឋានឲ្យគាត់ ដូចជាអ្នកដែរ ហើយពួកគេមិនអាចរកឃើញស្នាមនោះផង។ [ពួកជំនុំមានអំណរ] គាត់បានជា។ អាម៉ែន ។ គាត់—គាត់...[បងប្អូនស្រីឃីដនិយាយ "ត្រូវតែសារភាព"] គាត់ឡើងទំងន់ជាងមុន។ គាត់និងប្រពន្ធរបស់គាត់កំពុងនៅក្នុងពន្ធកិច្ចផ្សាយដំណឹងល្អ ប្រហែលមុនខ្ញុំកើតផង។ គាត់នៅទីនេះ...[បងប្អូនប្រុសឃីដនិយាយ "ហាសិបប្រាំឆ្នាំ"] ហាសិបប្រាំឆ្នាំ។ មុនខ្ញុំមកលើផែនដីផង ពួកគេបានអធិប្បាយដំណឹងល្អ។ ហើយឥឡូវគាត់នៅទីនេះបានជានៅអាយុប្រហែលចិតសិបប្រាំឆ្នាំឬ...["ប៉ែតសិបមួយ"] ប៉ែតសិបមួយ [បងប្អូនប្រុសឃីដនិយាយ "យើងមានប្រជុំចលនាផុសផុលពីរសប្តាហ៍ អធិប្បាយរៀងរាល់យប់"] ការផុសផុលពីរសប្តាហ៍ មានត្រឹមតែការផុសផុលពីសប្តាហ៍ និងអធិប្បាយរាល់យប់។ បុរសប៉ែតសិបមួយឆ្នាំបានជាពីជំងឺមហារីកពេលគាត់ចាស់។

485 ពិតហើយ បងប្អូនស្រីវាជាពេលសម្រាប់អ្នកឥឡូវ។ អ្នកជឿទេ? [ពួកជំនុំមានអំណរនិងនិយាយ "អាមែន"Ed។] *បន្តទាហានគ្រីស្ទាន*។ ត្រូវហើយ បងប្អូនស្រី។ អ្នក អ្នកគ្រប់គ្នា តើយើងនឹងធ្វើអ្វី? នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ តើយើងធ្វើអ្វី នៅឯរោទីនេះ?

486 សាតាំងឯងចាញ់ហើយ។ យើងបានឈ្នះឥឡូវ។ យើងដើរជាក្បួនទៅកាន់ទឹកដីសន្យា។ នោះជាអ្វី? "ភ្នំនេះជាអ្វី នៅពីមុខសេរ៉ូបាបិល? តើនរណានេះឈរនៅទីនោះ? ឯងនឹងរាប។" ហេតុអ្វី? ជាមួយនិងដាវមុខ២យើងនឹងកាត់វាទៅលើដីត្រូវហើយ។ ហ្នឹងហើយ។

ចូរទៅមុខទាហានគ្រីស្ទាន
ដើរជាក្បួនសង្គ្រាម
ជាមួយឈើឆ្កាងព្រះយេស៊ូវ
កំពុងនៅខាងមុខ
ព្រះគ្រីស្ទ ម្ចាស់ស្ថានសួគ៌
នាំទៅប្រឆាំងនឹងសត្រូវ(ដោយព្រះបន្ទូល)
ឆ្ពោះទៅកាន់សមរភូមិ
មើល ទង់ជ័យទ្រង់ទៅ!

ចូរទៅមុខទាហានគ្រីស្ទាន!
ដើរជាក្បួនសង្គ្រាម
ដោយឈើឆ្កាងព្រះយេស៊ូវ
កំពុងនាំទៅមុខ។

487 ហាលេលូយ៉ា! តើពួកគេបានធ្វើអ្វី? រឿងដំបូងដែលគេត្រូវធ្វើក្នុងសង្គ្រាម សំរាប់អ៊ីស្រាអ៊ែល តើអ្វីដែលដំបូងនោះ? អ្នកចម្រៀងដើទៅមុខមុន។ តើអ្វីដើរតាមក្រោយ? ហិបសញ្ញា។ បន្ទាប់មកក្បួនកងទ័ព។ត្រូវហើយ។ តើអ្នកជឿទេឥឡូវ? [ពួកជំនុំនិយាយ"អាម៉ែន"—Ed។]យើងច្រៀង*ចូរទៅមុខទាហានគ្រីស្ទាន*។ យើងរុញរាល់ការសង្ស័យ។ ឈរឡើងឥឡូវ យើងដើរក្បួនទៅកាន់ទីលានសង្គ្រាម។

ចូរយើងក្រោកឈរឡើង ឥឡូវ។

ចូរទៅមុខទាហានគ្រីស្ទាន
ដើរជាក្បួនសង្គ្រាម
ជាមួយឈើឆ្កាងព្រះយេស៊ូវ
កំពុងនៅខាងមុខ
ព្រះគ្រីស្ទ ម្ចាស់ស្ថានសួគ៌
នាំទៅប្រឆាំងនឹងសត្រូវ

តើយើងអាចយកឈ្នះវាដោយរបៀបណា? ដោយព្រះបន្ទូល។

នាំទៅក្នុងសមរភូមិ
មើលទង់ជ័យទ្រង់ទៅ!

ចូរទៅមុខទាហានគ្រីស្ទាន!
ដើរជាក្បួនសង្គ្រាម
ជាមួយឈើឆ្កាងព្រះយេស៊ូវ
កំពុងនៅខាងមុខ

យើងមិនបែកខ្ញែកគ្នាឡើយ
ជារូបកាយតែមួយ
ក្នុងក្តីសង្ឃឹមនិងជំនឿ
និងក្នុងក្តីស្រលាញ់។

488 អ្នកជឿទាំងអស់ឥឡូវនិយាយថា "អាម៉ែន"[ពួកជំនុំនិយាយ "អាម៉ែន"—Ed។] ហាលេលូយ៉ា! តើអ្នកជឿទេ? ["អាម៉ែន"] យើងជាអ្នកមានជ័យជំនះ។ ឯណាទៅខ្មាំងសត្រូវទាំងឡាយ? នៅក្រោមបាតជើងរបស់យើង។ តើយើងជាអ្វីសព្វថ្ងៃនេះ? ងើបឡើងជាមួយក្នុងព្រះគ្រីស្ទ!

489 ឥឡូវ វាចប់ហើយ ប្អូនស្រី [បងប្អូនប្រុសប្រានហាំនិយាយទៅកាន់បងប្អូនស្រីម្តងទៀតដែលជាអ្នកមានជំងឺ—Ed។] តើអ្នកជឿទេ? ចូរទៅផ្ទះញឥឡូវ។ តើអ្នកមមានអារម្មណ៍ថាប្រសើរខ្លះទេ? នាងនិយាយថា នាងគ្រាន់បើហើយឥឡូវ។ គ្រប់កន្លែងគឺប្រសើរហើយ។

490 តើប៉ុន្មាននាក់នៅទីនោះមានអារម្មណ៍ថាគ្រាន់បើហើយ? [ពួកជំនុំរីករាយនិងនិយាយ "អាម៉ែន"—Ed។] ហើយពេលពួកគេស្រែក ជញ្ជាំងក៏បាក់ធ្លាក់ចុះ។ អាម៉ែន និងពួកគេចាប់យក។ អាម៉ែន។ ពួកគេចាប់យកក្រុង។ អាម៉ែន! អាម៉ែន! តើអ្នកជឿទ្រង់ទេ? ["អាម៉ែន"]

491 ឥឡូវកុំភ្លេចកម្មវិធីយប់នេះ។ បងប្អូនប្រុសនេវីលនឹងនៅទីនេះ យប់នេះ និងនាំសារល្អមកយើង។ ហើយថ្ងៃអាទិត្យ ថ្ងៃអាទិត្យក្រោយ ព្រះហឫទ័យព្រះអម្ចាស់ ចូរនៅទីនេះ។

492 ឥឡូវចូរទៅ ដូចយើងធ្វើចលនា។ ហើយឥឡូវ ចេញពីអាគារ ចូរចេញទៅច្រៀង *ចូរទៅមុខ ទាហានគ្រីស្ទាន*។ ហើយពីថ្ងៃនេះ តទៅ កុំទុកដាវក្នុងស្រោមទៀត។ ដកវាចេញមក។ ចូរយកឈ្នះ។ "ពួកគេចេញទៅប្រយុទ្ធនិងឈ្នះទៀត" ត្រូវហើយ ម្តងទៀត នៅជួរដំបូង។

ចូរទៅមុខទាហានគ្រីស្ទាន
ដើរជាក្បួនសង្គ្រាម
ជាមួយឈើឆ្កាងព្រះយេស៊ូវ
កំពុងនៅខាងមុខ។

## សមរភូមិធំបំផុតដែលមិនធ្លាប់ជួប KHM62-0311

(The Greatest Battle Ever Fought)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹកថ្ងៃអាទិត្យ ថ្ងៃទី 11 មិនា 1962 នៅរោងឧបោសថ Branham, Jeffersonville, Indiana, U.S.A.។ រាល់ការខិតខំត្រូវបានធ្វើឡើង ដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លងនិង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារ ខ្មែរនេះ គឺត្រូវបោះពុម្ពនិង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

# ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG